# សាមណេរវិន័យ

## បញ្ហា

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# សាមណេរវិនយបញ្ហា

# ពាក្យនមស្សការ

ចបលាធន្ទ

បណាមាមិ លោកនាថំ.

វិនាយកំ ទសពលំ ប អហំ,

វរធម្ម់ តេន វុត្តំ

អនុត្តរំ បវរសង្ឃគណំ ។

*« ខ្ញុំសូមលើកករប្រណម្យ ចំពោះព្រះទសពល ព្រះអង្គជាទីពំនាក់របស់សត្វលោក, ព្រះអង្គជាអ្នកណែនាំសត្វឲ្យទៅកាន់ទីរលត់ទុក្ខ,*

*ចំពោះព្រះធម៌ទាំងពីរប្រការដែលព្រះអង្គបានសំដែងហើយ;*

*ចំពោះព្រះអរិយសង្ឃទាំង៨ពួក;*

*ដែលជាពួកឥតមានគុណជាតដទៃប្រសើរជាង ជាពួកដ៏ប្រសើរ » ។*

# ឧបោគ្ឃាតកថា

សៀវភៅនេះខ្ញុំបានចាប់ផ្ដើមរៀបរៀងឡើង តាំងពីថ្ងៃ ចន្ទ ៤ កើតខែអាសាធ ឆ្នាំជូតអដ្ឋស័ក ព្រះពុទ្ធសករាជ ២៤៧៩ ត្រូវនឹងថ្ងៃទី ៦ កក្កដា (សូរយគតិ) ឆ្នាំ ១៩៣៦, ហើយស្រេចនៅថ្ងៃសៅរ៍ ៦ កើតខែស្រាពណ៍ឆ្នាំដដែល ត្រូវនឹងថ្ងៃ ២៥ កក្កដា ឆ្នាំដដែល ។

ដំណើរដែលដឹកនាំឲ្យខ្ញុំមានព្យាយាម អត់ទ្រាំពុំបានខំធ្វើជាសៀវភៅនេះឡើងនោះ **ដោយហេតុ ៣ យ៉ាង ៖**

១– ដោយយល់ឃើញថា ព្រះវិន័យជាអាយុជាឫសគល់ព្រះពុទ្ធសាសនា បើព្រះវិន័យស្ថិតនៅ មានភិក្ខុសាមណេរ សិក្សារៀនសូត្រចេះដឹង ប្រតិបត្តិតាមដោយប្រពៃត្រឹមណា ព្រះពុទ្ធសាសនាក៏ឈ្មោះថាស្ថិតនៅត្រឹមនោះ , ព្រះពុទ្ធសាសនាដែលនឹងរុងរឿងឡើងនោះ អាស្រ័យពីអ្នកសិក្សាប្រតិបត្តិតាមដោយល្អ ។

២– ដោយសម័យនេះសាលាបាលីរងវត្តលង្កា មានបង្កើតឲ្យប្រឡងយកកម្មការកេសឡដីកា ទាំងភិក្ខុទាំងសាមណេរ ហើយសៀវភៅប្រស្នាវិន័យសម្រាប់ប្រឡងនោះ ពុំទាន់មានគ្រប់គ្រាន់នៅឡើយ ភិក្ខុសាមណេររូបណាដែលមានប្រាជ្ញាវាងវៃ ក៏គ្រាន់តែសិក្សាតាមបាតិមោក្ខសង្ខេបនិងសាមណេរវិន័យប៉ុណ្ណោះ ក៏អាចនឹងយល់ឆ្ងាយទូលាយទៅបានពុំសូវទើសទាល់, បើរូបណាដែលមិនសូវឈ្លាសវៃទេ ក៏គ្រាន់តែទន្ទេញចាំប៉ុណ្ណោះ, ហើយមិនសូវដឹងសេចក្ដីអធិប្បាយច្រើន, លុះ

ដល់វេលាដែលបង្គាប់ឲ្យប្រឡងម្ដងៗ ឡើង គឺលំបាកនឹងតបប្រស្នានោះ ឲ្យបានស្រួលឡើង ។

៣– ដោយសេចក្ដីប្រារព្ធចំពោះគុណូបការៈនៃមាតាបិតា ដែលលោកជាអ្នកចែកផ្សាយនូវធម៌ព្រហ្មវិហារ គឺ មេត្តា ករុណា មុទិតា ឧបេក្ខាមកលើខ្លួនខ្ញុំដោយសេចក្ដីព្យាយាមយ៉ាងថ្លៃថ្លា យ៉ាងល្អិតអស់ពីចិត្តរបស់លោកនោះផង ។

គុណសម្បត្តិទាំង ៣ យ៉ាងនេះ មូលមកជួបជុំគ្នាវេលាណា ក៏បណ្ដាលចិត្តខ្ញុំ ឲ្យមានព្យាយាមរៀបចំធ្វើជាសៀវភៅនេះឡើងដរាបដល់ចប់ ក្រោយសេចក្ដីហត់នឿយព្រួយលំបាកក្នុងការនេះ ។

វិធីដែលនឹងរៀបចំធ្វើជាសៀវភៅនេះឡើងនោះ ខ្ញុំបានយកសាមណេរវិន័យ, វិន័យបិដក, មង្គលត្ថទីបនី, បព្វជ្ជាខន្ធកសង្ខេប និងប្រស្នាដែលលោករៀបរៀងមុនខ្លះ មកទុកជាគ្រឿងជួយកំឡាំងក្នុងការរៀបចំធ្វើសៀវភៅនេះដរាបដល់ចប់ ។

កាលដែលបានរៀបរៀងហើយ បានយកទៅប្រគេនព្រះតេជព្រះគុណ ព្រះសិរីសម្មតិវង្ស សីវ៉ាលីយេរ ដឺឡាឡេស្យុងដូណើរ ចាងហ្វាងសាលាបាលីជាន់ខ្ពស់ អធិបតី ក្រុមជំនុំប្រែព្រះត្រៃបិដក, ព្រះតេជព្រះគុណព្រះគ្រូញាណសំវរ (ឈឺន) ក្រុមជំនុំប្រែព្រះត្រៃបិដក, ព្រះអាចារ្យ (ឌុំ) ព្រះអាចារ្យសុមន៍ ក្រុមជំនុំប្រែព្រះត្រៃបិដក, សូមឲ្យ

លោកពិនិត្យផ្ទៀងផ្ទាត់ឲ្យ ។

ទីបំផុតនេះ, សូមផ្សាយកុសលរាសីដែលបានកើតឡើងដោយសារការរៀបរៀងសៀវភៅនេះ ដល់ប្រជានិករគ្រប់ពួក ។

## ម្យ៉ាងទៀត

សូមឲ្យពួកលោកអ្នកសិក្សា សម្រេចវិជ្ជាបានគ្រប់យ៉ាងផ្លូវលោក ផ្លូវធម៌ទាំងសងខាង ប្រើបានគ្រប់យ៉ាងក្នុងស្រុកខ្មែរ ។

អាកាសដ្ឋា ច ភូមដ្ឋា ទេវា នាគា មហិទ្ធិកា
បុញ្ញំ មេ អនុមោទិត្វា ចិរំ រក្ខន្តុ សាសនំ ។

វត្តលង្កា ឃុំលេខ ៦ ក្រុងភ្នំពេញ

នៅថ្ងៃសៅរ៍ ៦ កើត ខែស្រាពណ៍ ឆ្នាំជូតអដ្ឋស័ក

ព្រះពុទ្ធសករាជ ២៤៧៩

ត្រូវនឹងថ្ងៃ ២៥ សូយេត គ្រិស្តសករាជ ១៩៣៦

អ. ក្រុមវិជ្ជាញាណាកយវង្ស

# សាមណេរវិនយបញ្ហា

ព្រះអ៊ុក - ជា វជិរញ្ញាណាភយវង្ស
ក្រុមជំនុំប្រែព្រះត្រៃបិដក នៅក្រសួងពុទ្ធសាសនបណ្ឌិត្យ ក្រុងភ្នំពេញ
រៀបរៀង

ព្រះសិរីសម្មតិវង្ស (អែម)
សឺវ៉ាលីយេរដឺឡាឡេស្យុងដូណើរ ចាងហ្វាងសាលាបាលីជាន់ខ្ពស់
អធិបតីក្រុមជំនុំប្រែព្រះត្រៃបិដក បានពិនិត្យផ្ទៀងផ្ទាត់

កុង្ស៊ីយ៍សេនាបតីបានអនុញ្ញាតហើយ
សម្ដេចសង្ឃនាយកទាំងពីរគណៈយល់ព្រម

ការផ្សាយរបស់ បណ្ណាគារ គីម-សេង
លេខ ១២២ រុក្ខវិថីខេមរភូមិន្ទ ភ្នំពេញ
ព. ស. ២៥០០ . គ. [redacted]

# សាមណេរវិន័យបញ្ហា

## វគ្គទី ១

## សាមណេរុប្បត្យាទិ

១– ប្រ. សាមណេរ នឹង លោកនេន ដូចគ្នា ឬ ផ្សេងគ្នា? បើផ្សេងគ្នាក៏ហើយទៅ បើដូចគ្នាទេ ហេតុអ្វីក៏អ្នកអានអ្នកហៅៗ ឲ្យប្លែកគ្នាដូច្នោះ? ហៅតាមអ្នកណា ឬអ្វី? ឬហៅក្លាយពីភាសាអ្វីមក? ចូរនិយាយរៀបរាប់ឲ្យសព្វគ្រប់ ។

១– វិ. ដូចគ្នា ឥតមានផ្សេងគ្នាទេ, បើនិយាយតាមរូបៈសព្ទដើម មកពី សម (ធាតុ) ប្រែថា "រម្ងាប់, ស្ងប់", សម្រេចរូបបាន ជាសមណៈ ប្រែថា "អ្នកមានចិត្តស្ងប់រម្ងាប់"; កូន, ចៅ, ឬពូជពង្សរបស់អ្នកមានចិត្តស្ងប់រម្ងាប់នោះឯងលោកហៅថា "សាមណេរ" ប្រែថា "កូន....របស់សមណៈ", បានជាថាមិនផ្សេងគ្នាដូច្នោះ ព្រោះក្នុងស្យាមភាសាលោកកាត់ "សាម" ចោល ទុកត្រឹម "ណេរ", ក្នុងភាសានុះ អក្សរ "រ, ល, ឡ" ប្រកបខាងចុង ត្រូវអានដូច "ន, ណ" ប្រកបដែរ បានជាពាក្យថា "ណេរ" នោះលោកអានថា "ណេន" ក្លាយពីពាក្យថា "ណេន" នោះមកថា "នេន"; បានជាហៅជាប់មកដល់សព្វថ្ងៃនេះថា "នេនៗ" គឺហៅតាមសៀម; សំដីនេះក្លាយពីភាសាសៀមមក; ព្រោះហេតុនោះបានជាថា ពាក្យ

ទាំងពីរមាត់នេះផ្សេងគ្នាតែពាក្យហៅ ត្រង់រូបមនុស្សនឹងមិសម្រាប់ប្រព្រឹត្តមិនផ្សេងគ្នា ។

៤– ឬ. សាមណេរមានពីត្រឹមណាមក? លោកណាដែលបានបួសមុនគេ? ចូរសំដែងរឿងរ៉ាវរបស់លោកនោះមកមើល? ។

៤– វិ. សាមណេរមានពីត្រឹមសម័យព្រះបរមគ្រូ បានត្រាស់ដឹងឡើងក្នុងលោក, លោកដែលបានបួសមុនគេនោះគឺព្រះរាហុលកុមារជាឱរសរបស់ព្រះសម្មាសម្ពុទ្ធ; រឿងរ៉ាវរបស់លោកនោះថា: កាលដែលព្រះជិនវង្សទ្រង់គង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលវត្ថុដែនសក្កៈនោះ សម័យនោះឯង ព្រះអង្គទ្រង់ស្បង់ទ្រង់បាត្រចីវរ ហើយស្ដេចចូលទៅកាន់ដំណាក់ព្រះបាទសុទ្ធោទនសក្យរាជក្នុងវេលាព្រឹក លុះស្ដេចចូលទៅដល់ហើយទ្រង់គង់លើអាសនៈដែលគេរៀបចំថ្វាយ, គ្រានោះព្រះនាងទេវីជាមាតារាហុល មានព្រះបន្ទូលទៅនឹងព្រះរាហុលកុមារថា «ម្នាលរាហុល ព្រះសមណៈនេះជាបិតារបស់បាហើយ បាឯងចូរទៅសូមទ្រព្យមត៌ករបស់បិតាបាចុះ», លំដាប់នោះរាហុលកុមារ ក៏ចូលទៅរកព្រះដ៏មានព្រះភាគដល់ហើយក៏ឈរចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគ ហើយក្រាបទូលថា "បពិត្រព្រះសមណៈ! ម្លប់ (បុណ្យ) របស់ព្រះអង្គសុខស្រួលណាស់, ព្រះសាស្ដាក៏ទ្រង់ក្រោកចាកអាសនៈហើយយាងចេញទៅ ។

ឯព្រះរាហុលកុមារ ក៏ទៅតាមព្រះអង្គបែកតិចៗខាងក្រោយៗ ហើយ

ក្រាបទូលថា “ បពិត្រព្រះសមណៈ! សូមព្រះអង្គទ្រង់ប្រទានទ្រព្យមត៌កដល់ខ្ញុំ”, លំដាប់នោះព្រះដ៏មានព្រះភាគទ្រង់ហៅព្រះសារីបុត្រដ៏មានអាយុមក ហើយត្រាស់ថា: “ម្នាលសារីបុត្រ! បើដូច្នោះអ្នកចូរបំបួសរាហុលកុមារចុះ”, រឿងរ៉ាវរបស់លោកយ៉ាងសង្ខេបប៉ុណ្ណេះ ។

៣– ប្រ. បព្វជ្ជា និង ឧបសម្បទា ប្លែកគ្នាយ៉ាងណា? ចូរអធិប្បាយ?

៣– ឆ្លើ. ប្លែកគ្នា យ៉ាងនេះ បព្វជ្ជាបានដល់ការបួសជាសាមណេរ, ឧបសម្បទាបានដល់ការដែលកាន់យកភេទដ៏ខាងលើ គឺបួសជាភិក្ខុ ដូចមានសព្វថ្ងៃនេះ ។

៤– ប្រ. បព្វជ្ជាប្រែថាម៉េច? បានដល់កុលបុត្រពួកណា ? ។

៤– ឆ្លើ. បព្វជ្ជាក្នុងទីនេះ ប្រែថា “សេចក្ដីព្យាយាមដុតបំផ្លាញបាប” ឬប្រែថា “ការប្រព្រឹត្តព្រហ្មចរិយខាងព្រះពុទ្ធសាសនា” ប្រែថា “ការវៀរចាកមេថុនធម្មជាដំបូង” ដូចមានបាលីថា: បឋមំ វេរំ វជ្ជិតព្វំ បព្វជ្ជា ការវៀរចាកទោស (មេថុនធម្ម) ជាដំបូង ឈ្មោះថា បព្វជ្ជា ។ បានដល់កុលបុត្រដែលចូលមកបួសជាសាមណេរនោះឯង ។

៥– ប្រ. ការបំបួសជាសាមណេរនោះ កុលបុត្រដូចម្ដេចទ្រង់អនុញ្ញាតឲ្យបួស ? ដូចម្ដេចទ្រង់បញ្ញត្តមិនឲ្យបួស? ឬឥតមានហាមទេ ? ចូរឆ្លើយតាមសេចក្ដីយល់? ។

៥– ឆ្លើ. មានហាមដែរ, កុលបុត្រ ៣៤ ពពួក គឺ·

១- ហត្ថច្ឆិន្ន « មនុស្សកំបុតដៃ » ២- បាទច្ឆិន្ន " មនុស្សកំបុតជើង », ៣- ហត្ថបាទច្ឆិន្ន " មនុស្សកំបុតទាំងដៃទាំងជើង », ៤- កណ្ណច្ឆិន្ន " មនុស្សកំបុតត្រចៀក », ៥- នាសច្ឆិន្ន "មនុស្សកំបុតច្រមុះ » ៦- កណ្ណនាសច្ឆិន្ន " មនុស្សកំបុតទាំងត្រចៀកទាំងច្រមុះ » ៧- អង្គុលិច្ឆិន្ន " មនុស្សកំបុតម្រាមដៃ » ៨- អឡច្ឆិន្ន " មនុស្សកំបុតមេដៃមេជើង », ៩- កណ្ឌរច្ឆិន្ន " មនុស្សដាច់សរសៃធំ », ១០- ផណហត្ថក " មនុស្សមានម្រាមដៃជាប់គ្នា », ១១- ខុជ្ជ " មនុស្សគម », ១២- វាមន " មនុស្សតឿ », ១៣- គលគណ្ឌិក " មនុស្សពកក », ១៤- លក្ខណាហត " មនុស្សដែលគេបៀតបៀនឲ្យមានស្នាកស្នាម », ១៥- កសាហត មនុស្សដែលគេវាយដោយរំពាត់ », ១៦- លិខិតក « មនុស្សដែលរាជការគត់ឈ្មោះទុក ( ព្យួរទោសទុក ) », ១៧- សិបទី " មនុស្សជើងស្អុក », ១៨- បាបរោគី " មនុស្សមានរោគអាក្រក់ », ១៩- បរិសទូសក " មនុស្សទ្រុស្តបរិស័ទ », ២០- កាណ " មនុស្សទើបនឹងខ្វាក់ », ២១- កុណី " មនុស្សក្ងិនដៃក្ងិនជើង », ២២- ខញ្ជ « មនុស្សខ្វក », ២៣- បក្ខហត « មនុស្សស្លាប់កាយម្ខាង », ២៤- ឆិន្នឥរិយាបថ " មនុស្សខ្វិន », ២៥- ជរា

ទុព្ពល "មនុស្សមានកំឡាំងថយព្រោះជរា", ២៦– អន្ធៈមនុស្ស ខ្វាក់ពីកំណើត" ២៧– មូគ "មនុស្សគ", ២៨– ពធិរ មនុស្សថ្លង់", ២៩– អន្ធមូគ "មនុស្សទាំងខ្វាក់ទាំងគ", ៣០– អន្ធពធិរ "មនុស្សទាំងខ្វាក់ទាំងថ្លង់", ៣១– មូគពធិរ "មនុស្សទាំងគទាំងថ្លង់" ៣២ អន្ធមូគពធិរ "មនុស្សទាំងខ្វាក់ទាំងគទាំងថ្លង់"; កុលបុត្រទាំង ៣២ ពពួកនេះទ្រង់ហាម, ក្រៅពីនោះ បំបួសបានមិនមានហាម ។

៦– ប្រ. ត្រង់ពាក្យថាហាមមិនឲ្យបួសនោះ បើគេហ៊ានចេះតែ បំបួសទៅតើនឹងឡើងពេញជាសាមណេរឬទេ ឬក៏យ៉ាងម៉េចទៅវិញ? ចូរថាមកមើល? ។

៦– វិ. បើចេះតែបះបោសបំបួសទៅឡើងជាសាមណេរដែរ ប៉ុន្តែ លោកអ្នកបំបួសត្រូវអាបត្តិទុក្កដ ។

៧– ប្រ. មានកំណត់អាយុថាប៉ុន្មានៗ ដែរឬអី ការបួសជាសាមណេរនោះ? ចូរនឹករកពុទ្ធប្បញ្ញត្តិនិងពុទ្ធានុញ្ញាតឲ្យសព្វគ្រប់មកមើល?។

៧– វិ. តាមទំនងដើមមានកំណត់ដែរៈ សេចក្ដីថាសម័យនោះ ឯង មានត្រកូលមួយ ធ្វើមរណកាលស្លាប់ទៅ ដោយអហិវាតរោគ ត្រកូលនោះ នៅសល់តែបិតានឹងបុត្រតូច អ្នកទាំងពីរនាក់នោះ បាន ទៅបួសក្នុងសំណាក់ភិក្ខុទាំងឡាយ ហើយទៅបិណ្ឌបាតជាមួយគ្នា ។

ឯទារកនោះ កាលបើមានគេឲ្យបាយដល់បិតា ក៏ស្ទុះចូលទៅជិត ហើយនិយាយថា នែអាពុកចូរឲ្យខ្ញុំផង ! ពួកមនុស្សក៏ពោលពាក្យបន្តុះបង្អាប់ ; ដំណើរនេះ ក៏ជ្រាបដល់ព្រះជិនវង្ស ព្រះអង្គក៏ទ្រង់បញ្ញត្តថា:

ន ភិក្ខវេ ឩនបណ្ណរសវស្សោ ទារកោ បព្វាជេតព្វោ យោ បព្វាជេយ្យ អាបត្តិ ទុក្កដស្ស «ម្នាលភិក្ខុទាំងឡាយ! ភិក្ខុមិនត្រូវបំបួសទារកដែលមានអាយុថយអំពី ១៥ ឆ្នាំ ភិក្ខុណាបំបួសត្រូវអាបត្តិទុក្កដ» ។

សម័យក្រោយ ត្រកូលឧបដ្ឋាករបស់ព្រះអានន្ទដ៏មានអាយុ ជាត្រកូលមានសទ្ធាដ៏ជ្រះថ្លា ធ្វើមរណកាលដោយអហិវាតរោគ នៅសល់តែទារកពីរនាក់, ទារកទាំងនោះ បានឃើញពួកភិក្ខុ ដោយធ្លាប់ស្គាល់មកពីដើម ក៏ស្ទុះចូលទៅជិត ភិក្ខុទាំងនោះក៏បណ្ដេញចេញ ទារកទាំងនោះក៏យំ, ព្រះអានន្ទដ៏មានអាយុ បានរិះគិតយ៉ាងនេះថា "ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា ទារកដែលមានអាយុថយពី ១៥ ឆ្នាំ ភិក្ខុមិនត្រូវបំបួស ក៏ឥឡូវនេះទារកទាំងនេះមានអាយុថយពី ១៥ ឆ្នាំដោយទំនងដូចម្ដេចហ៎ ! ទើបបានទារកទាំងនេះ មិនបានសាបសូន្យបាត់ផង» លោកក៏ក្រាបទូលសេចក្ដីនោះចំពោះព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ត្រាស់សួរថា «ម្នាលអានន្ទ! ចុះទារកទាំងនោះ អាចនឹងដេញបន្លាលក្អែកឲ្យហើរទៅបានដែរឬទេ ?» លោកក្រាបទូលថា

"សូមទ្រង់ព្រះមេត្តាប្រោស។ អាចបោលបង្អើលបាន„ ព្រះអង្គក៏ទ្រង់អនុញ្ញាតថា: អនុជានាមិ ភិក្ខវេ ឩនបណ្ណរសវស្សំ ទារកំ កាកុដ្ឋេបកំ បព្វាជេតុំ "ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតឲ្យភិក្ខុបំបួសទារកមានអាយុថយអំពី ១៥ ឆ្នាំ ដែលអាចបោលបង្អើលក្អែកឲ្យហើរទៅបាន"; បើតាមដំណើរខាងចុងនេះ ឥតមានកំណត់អាយុទេ ហើយយើងក៏ត្រូវកាន់យកតាមសេចក្ដីខាងចុងនេះ ។

៨ -- ប្រ.ចូរនិយាយអំពីវិធីបួស ជាសាមណេរមុនដំបូងមកមើល. កុលបុត្រនោះ ត្រូវធ្វើដូចម្ដេចក្នុងពេលដែលចូលទៅជាបឋម ?

៨– វិ· កុលបុត្រដែលនឹងចូលទៅបួស ជាសាមណេរមុនដំបូងនោះ គប្បីឲ្យគេកោរសក់ និងពុកមាត់ពុកចង្កា កាត់ក្រចកឲ្យត្រឹមត្រូវតាមវិនយបញ្ញត្តិ ហើយស្លៀកដណ្ដប់តាមបែបបទយកជាស ហើយកាន់គ្រឿងសក្ការបូជាមានទៀនធូបជាដើម ដែលជារបស់គួរបូជាក្នុងវេលានោះ ចូលទៅបូជាព្រះពុទ្ធរូបក្នុងវណ្ណសីមា ធ្វើកាយបណាម វចីបណាម ដោយគោរព រួចហើយកាន់សំពត់កាសាវៈ បីទ្រចូលទៅកាន់សំណាក់ព្រះឧបជ្ឈាយ៍ លុះដល់ហើយបង្អោនគ្រឿងសក្ការៈមានទៀនធូបជាដើម ប្រគេនទៅឧបជ្ឈាយ៍ឬបព្វជ្ជាចារ្យនោះ ហើយដាក់សំពត់កាសាវៈ ចុះទៀបទីដែលខ្លួនអង្គុយនោះ ហើយថ្វាយបង្គំដោយបញ្ចាង្គប្រតិស្ឋាន ហើយក្រោកឈរឡើងប្រណម្យអញ្ជលី ធ្វើវចីបណាម

ដោយបើគេទថា: ឱកាស វន្ទាមិ ភន្តេ ។ល។ អនុមោទាមិ ហើយពោលដូច្នេះតទៅទៀតថា ឱកាស ការុញ្ញំ កត្វា បព្វជ្ជំ ទេថ មេ ភន្តេ រួចហើយអង្គុយច្រហោងលើកដៃឡើងប្រណម្យ ពោលដូច្នេះថា អហំ ភន្តេ បព្វជ្ជំ យាចាមិ ទុ: ត. } តិយម្បិ អហំ ភន្តេ បព្វជ្ជំ យាចាមិ ហើយពោលដូច្នេះតទៅទៀតថា: សព្វទុក្ខនិស្សរណនិព្វានសច្ឆិករណត្ថាយ ឥមំ កាសាវំ គហេត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ ។

លុះបព្វជ្ជាបេក្ខៈពោលដូច្នេះ៣ដងរួចហើយ ព្រះឧបជ្ឈាយ៍ត្រូវទទួលសំពត់កាសាវៈនោះពីដៃបព្វជ្ជាបេក្ខៈ ហើយទើបបព្វជ្ជាបេក្ខៈពោលដូច្នេះ៣ដងតទៅទៀតថា: សព្វទុក្ខនិស្សរណនិព្វានសច្ឆិករណត្ថាយ ឯតំ កាសាវំ ទត្វា បព្វាជេថ មំ ភន្តេ អនុកម្បំ ឧបាទាយ ។

កាលបើបព្វជ្ជាបេក្ខពោលដូច្នេះ ៣ ដងរួចហើយ ទើបព្រះឧបជ្ឈាយ៍ ប្រគល់នូវសំពត់កាសាវៈនោះឲ្យមកវិញ ហើយប្រាប់តចបញ្ចកកម្មដ្ឋានជាអនុលោមបដិលោម (បរេណ្ណកាយប្រាស) ។

៩– ប្រ. កាលដែលបព្វជ្ជាបេក្ខៈចូលមក សូមផ្នួសជាសាមណេរនោះ លោកអាចារ្យ ឬ ឧបជ្ឈាយ៍ លោកឲ្យធម៌អ្វីជាមុន? ធម៌នោះឈ្មោះដូចម្តេច? មានប៉ុន្មានយ៉ាងគឺអ្វីខ្លះ?

៩– វិ. លោកឲ្យធម៌កម្មដ្ឋានជាមុន, ឈ្មោះតចបញ្ចកកម្មដ្ឋានមាន ៥ យ៉ាងគឺ កេសា «សក់» លោមា «រោម» នខា «ក្រចក» ទន្តា «ធ្មេញ» តចោ «ស្បែក» ជាអនុលោមបដិលោម (ច្រាសបណ្តោយ) ដើម្បីឲ្យពិចារណាឲ្យឃើញថាជារបស់បដិកូលគួរខ្ពើមរអើម ។

១០ – ប្រ. បើឧបជ្ឈាយ៍លោកឲ្យតែកម្មដ្ឋានប៉ុណ្ណោះ ហើយទឹងបានឡើងពេញជាសាមណេរបរិបូណ៌ ឬនៅខ្វះអ្វីទៀត?

១០– វិ. មិនទាន់ឡើងពេញជាសាមណេរទេ ព្រោះនៅខ្វះកិច្ចឯទៀតច្រើន ដូចមានពុទ្ធានុញ្ញាតថា: អនុជានាមិ ភិក្ខវេ តីហិ សរណគមនេហិ បព្វជ្ជំ «ម្នាលភិក្ខុទាំងឡាយ! តថាគតអនុញ្ញាតនូវបព្វជ្ជាដោយសរណគមន៍ទាំងឡាយ ៣» ដំណើរនេះ បានជាថាមិនទាន់ពេញជាសាមណេរ ។

១១– ប្រ. បើបព្វជ្ជាបេក្ខៈទទួលតែត្រៃសរណគមន៍ដូចពុទ្ធានុញ្ញាត ប៉ុន្តែមិនមានស្បង់ចីពរសព្វគ្រប់ មិនទាន់កោរសក់ ទឹងបានពេញជាសាមណេរឬទេ? ព្រោះហេតុអ្វី?

១១ –វិ. មិនបានពេញទេ ព្រោះមិនទាន់គ្រប់អង្គ មិនសមតាមពុទ្ធានុញ្ញាត ដូចមានក្នុងបាលីទីឯអដ្ឋកថាថា: កេសច្ឆេទនំ កាសាយអច្ឆាទនំ សរណទានន្តិ ឥមានិ តីណិ អង្គានិ ករោន្តោ បព្វាជេតីតិ វុច្ចតិ «កាលបើអាចារ្យឬឧបជ្ឈាយ៍ ធ្វើអង្គទាំង៣គឺឲ្យកោរ

សក់ ១ ឲ្យស្មៀកសំពត់កាសាយៈ ១, ឲ្យត្រៃសរណគមន៍ ១, ប្រកប ដោយអង្គទាំង ៣ នេះ ទើបឡើងជាសាមណេរបាន ។

១៤– ប្រ. បើបព្វជ្ជាបេក្ខៈ មិនវាងវៃក្នុងវិធីអក្ខរៈ ទាំងលោក អ្នកបំបួសក៏មិនស្ទាត់ជំនាញក្នុងវិធីអក្ខរៈដែរ ចុះសរណគមន៍ដែលលោក ទាំងនោះ សូត្រមិនត្រឹមត្រូវច្បាស់លាស់ដូច្នោះ នឹងឡើងជាសាមណេរ បានឬទេ? ព្រោះហេតុអ្វី?

១៤– វិ. មិនបានឡើងទេ, កុំថាតែបព្វជ្ជាបេក្ខៈមិនស្ទាត់ជំនាញ នោះឡើយ បើទុកជាអាចារ្យអ្នកឲ្យត្រៃសរណគមន៍នោះស្ទាត់ជំនាញ សូត្រត្រឹមត្រូវ ប៉ុន្តែបព្វជ្ជាបេក្ខៈសូត្រតាមមិនត្រឹមត្រូវ សរណគមន៍ក៏ មិនឡើងដែរ លុះតែអាចារ្យនឹងសិស្សទាំងពីរនាក់ សូត្រត្រឹមត្រូវដូច គ្នាទើបសរណគមន៍ឡើង, ព្រោះកិច្ចបព្វជ្ជាជាឧភតោសុទ្ធិ ស្អាតបរិសុទ្ធ ទាំងសងខាង, មិនមែនជាឯកតោសុទ្ធិ ស្អាតបរិសុទ្ធតែខាងអាចារ្យក៏ បានដែរដូច្នោះទេ ហើយទាំងមិនសមតាមបាលីនឹងអដ្ឋកថាជាដូច្នេះផង ឧបសម្បទា ឯកតោ សុទ្ធិយា វដ្ដតិ, សាមណេរបព្វជ្ជា បន ឧភតោ សុទ្ធិយា វដ្ដតិ, នោ ឯកតោ សុទ្ធិយា សេចក្ដីថា: "ឧបសម្បទា ជាឯកតោសុទ្ធិ ស្អាតបរិសុទ្ធតែខាងអាចារ្យក៏បាន; ឯសាមណេរបព្វជ្ជា ជា ឧភតោសុទ្ធិ លុះតែស្អាតបរិសុទ្ធទាំងអាចារ្យ ទាំងសិស្សទើបបាន; មិនមែនជាឯកតោសុទ្ធិទេ" ។

ប្រ. ហេតុដូចម្តេចសាមណេរបព្វជ្ជា បានជាហៅថាឧភតោសុទ្ធិ?

វិ. សាមណេរបព្វជ្ជាបានជាហៅថាឧភតោសុទ្ធិ ព្រោះថាត្រូវធ្វើឲ្យបរិសុទ្ធទាំងពីរខាង គឺបរិសុទ្ធអំពីអ្នកឲ្យនិងអ្នកទទួលបានពោលសរណគមន៍ ឲ្យត្រូវតាមលំដាប់ឋានករណរបស់ព្យញ្ជនៈទាំងឡាយ និងសូត្រថាត្រូវតាមលំដាប់បទ និងលំដាប់អក្ខរៈ ដូចគ្នាទាំងពីររូប ។

បើអ្នកឲ្យឬអ្នកទទួលថាមិនត្រូវតាមឋានករណៈរបស់អក្ខរៈណាមួយ ឬថាឲ្យភ្លាត់ហើយ មិនត្រឡប់ថាថែមទៀតឲ្យត្រូវ នោះសាមណេរបព្វជ្ជាមិនឡើងឡើយ ។

ប្រ. សរណគមន៍ជាកម្មអ្វីរបស់បព្វជ្ជាបេក្ខៈ ចូរអធិប្បាយ ?

វិ. សរណគមន៍ជាគរុកម្ម គឺកម្មមានទម្ងន់របស់បព្វជ្ជាបេក្ខៈ, ព្រះឧបជ្ឈាយ៍ឬអាចារ្យគប្បីឲ្យព្រះត្រៃសរណគមន៍ដល់បព្វជ្ជាបេក្ខៈ ឬដល់សាមណេរដែលដាច់សីល ក្នុងពេលម្តងៗ បានតែត្រឹម១រូប មិនត្រូវឲ្យក្នុងខណៈម្តងៗច្រើនរូបទេ បើឲ្យច្រើនរូបតាំងពី២-៣-៤រូបជាដើមឡើងទៅ នោះសាមណេរបព្វជ្ជាមិនឡើងឡើយ, លុះអ្នកឲ្យតែម្នាក់អ្នកទទួលតែម្នាក់ដូចគ្នា ហើយពោលត្រឹមត្រូវបរិបូណ៌ដោយឋានករណៈរបស់អក្ខរៈប្រកបដោយ ចតុរស្ស មានជ្រុង៤ ដូចបទថា: ពុទ្ធំ សរណំ គច្ឆាមិ ជាដើម ។

(ចូរមើលបព្វជ្ជាខន្ធកសង្ខេប ទំព័រ ៦៩)

ប្រ. សរណគមន៍នោះ បើបព្វជ្ជាបេក្ខៈទទួលដោយការសាដទៃក្រៅពីមគ្គគការសាបានឬទេ ?

វិ. សរណគមន៍នោះនឹងទទួលដោយការសាដទៃក្រៅពីមគ្គគការសាពុំបានឡើយ, ព្រោះបព្វជ្ជាបេក្ខៈនេះ សម្រេចឡើងបានតែដោយសរណគមន៍ មិនមែនសម្រេចដោយសិក្ខាបទទេ ។

១៣– ប្រ. បើគ្រាន់តែបួសជាសាមណេរប៉ុណ្ណោះ កុំចាំបាច់មានឧបជ្ឈាយ៍នឹងកើតឬទេ ព្រោះហេតុអ្វី ?

១៣ – វិ. មិនកើតទេ, ព្រោះហេតុថា កិច្ចបព្វជ្ជាជាសាមណេរក្តី កិច្ចឧបសម្បទាជាភិក្ខុក្តី កិច្ចទាំងពីរនេះ លុះតែអាស្រ័យនឹងឧបជ្ឈាយ៍ទាំងអស់ទើបកើត, ដូចមានបាលីក្នុងគម្ពីរតតិយសមន្តអដ្ឋកថាមហាវគ្គថា យស្មា បន ឧបជ្ឈាយមូលកា បព្វជ្ជូបសម្បទា, ឧបជ្ឈាយោវ តត្ថ ឥស្សរោ, ន អាចរិយោ; តស្មា វុត្តំ "អថខោ អាយស្មា សារីបុត្តោ រាហុលកុមារំ បព្វាជេសី"តិ" "បព្វជ្ជាក្តី ឧបសម្បទាក្តី មានឧបជ្ឈាយ៍ជាឫស, ព្រោះឧបជ្ឈាយ៍ជាឥស្សរៈ ក្នុងបព្វជ្ជានឹងឧបសម្បទានោះ, ឯអាចារ្យមិនមែនជាឥស្សរៈក្នុងបព្វជ្ជានឹងឧបសម្បទានោះទេ; ព្រោះហេតុដូច្នោះ បានជាព្រះសង្គីតិកាចារ្យលោកពោលទុកក្នុងគម្ពីរមហាវគ្គថា : គ្រានោះឯង ព្រះសារីបុត្រដ៏មានអាយុបំបួសរាហុលកុមារ» ។

១៤– ប្ញ. បើគ្រហស្ថគេស្គាល់ក្នុងវិធីបព្វជ្ជាសព្វគ្រប់ គេនឹងឲ្យត្រៃសរណគមន៍ដល់បព្វជ្ជាបេក្ខៈនោះ បានឬទេ? ព្រោះហេតុអ្វី?

១៤– វិ. មិនបានទេ, ព្រោះមានបាលីក្នុងគម្ពីរតតិយសមន្តថា: ឯវំ ភិក្ខវេ បព្វជិតោ ហោតិ, បរិសំ ហិ ភិក្ខុតោ អញ្ញោ បព្វាជេតុំ ន លភតិ, "កុលបុត្រត្រូវតែភិក្ខុបំបួស (ទើបគួរ); ឯបុគ្គលដទៃក្រៅពីភិក្ខុមិនគួរនឹងបំបួសបរិស័ទទេ"; បើព្រះឧបជ្ឈាយ៍លោកបង្គាប់ឲ្យស្លៀកដណ្តប់សំពត់កាសាវៈឲ្យតែប៉ុណ្ណោះបាន, ឯចំណែកត្រៃសរណគមន៍នោះ ត្រូវអាចារ្យឬឧបជ្ឈាយ៍ឲ្យទើបបាន ។

១៥– ប្ញ. ក្នុងបាលីមហាវគ្គ ព្រមទាំងអដ្ឋកថា មានពុទ្ធានុញ្ញាតនឹងពុទ្ធប្បញ្ញត្តិ សំដែងពីការបព្វជ្ជាល្អិតណាស់, ចង្អៀតណាស់, ពិស្តារណាស់ បើបំប្រួញចូលមក តើសេចក្តីវិសេសនៅត្រង់ណា ទើបជាការដឹងបានដោយងាយ?

១៥– វិ. បើបំប្រួញចូលមក មានសេចក្តីវិសេសត្រង់ទទួលយកត្រៃសរណគមន៍នោះ ជាការមាំមួនខានមិនបាន ។

១៦– ប្ញ. បើលោកអ្នកឲ្យត្រៃសរណគមន៍ ជាត្រូវតាមវិធីអក្ខរៈឥតមានខុស ទាំងអ្នកបព្វជ្ជាសោត ក៏ពោលត្រូវតាមឥតមានភ្លាត់, តែអ្នកទទួលនោះតាំងចេតនាខុសពីពាក្យដែលខ្លួនថា ដូចជាទទួលថា: "ពុទ្ធំ សរណំ គច្ឆាមិ" តាំងចិត្តថា "ថ្ងៃស្អែកនេះ អញនឹងទៅ

នេសាទត្រី » យ៉ាងនេះជាដើម តើឡើងជាត្រៃសរណគមន៍ឬទេ? ព្រោះហេតុអ្វី?

១៦– វិ. ឡើងជាត្រៃសរណគមន៍, ព្រោះកិច្ចសង្គ្រហ គ្រប់យ៉ាង លោកសំដៅយករតីភេទជាប្រមាណ តាំងចិត្តយ៉ាងណាក៏ដោយឲ្យតែជាត្រូវ សុទ្ធតែឡើងគ្រប់សង្គ្រហ ; ឯបព្វជ្ជាបេក្ខៈនេះ បើពោលត្រូវច្បាស់តាំងសងខាងហើយ ក៏ទុកជាត្រូវ សរណគមន៍ក៏ឡើង ៗ

សាមណេរុប្បត្តិ

វគ្គទី ១ ចប់

## អាចរិយវគ្គទី ២

១៧– បុ. មនុស្សយ៉ាងម៉េចដែលហៅថា អាចារ្យ? បើប្រែតាមអត្ថតើបានប៉ុន្មានយ៉ាង ។ ណាខ្លះ?

១៧– វិ. មនុស្សដែលមានព្យាយាមបង្ហាត់ខ្លួនឯងជាមុន ហើយបង្ហាត់បង្ហាញគេជាខាងក្រោយ ឬអ្នកដែលជាធំជាងសិស្សានុសិស្ស ឬអ្នកដែលបេះដូងគួរគេសេពគប់ហៅថាអាចារ្យ; បើប្រែតាមអត្ថបាន៤យ៉ាងគឺ ១អ្នកដែលសិស្សានុសិស្សគប្បីប្រព្រឹត្តតាមដោយគោរពៈ អាទរេន-បរិចរិយ្យោ'តិ អាចរិយោ (ជនោ) ៗ ២ អ្នកសន្សំនូវសេចក្ដីចំរើនដល់សិស្សានុសិស្សៈ សិស្សានំ-ហិតំ អាចរតី'តិ អាចរិយោ (ជនោ) ៗ ៣ អ្នកប្រព្រឹត្តប្រយោជន៍ ឲ្យសិស្សានុសិស្សដោយមាត់: អន្តេវាសិកានំ-ហិតំ

មុខេន-អាចរតិ: បវិត្តតិ' តិ អាចរិយោ(ជិនោ) ។ ៤ អ្នកដែលសិស្សនុសិស្សត្រូវតែបំរើតាំងតែអំពីដើម : អាទិតោ-បដ្ឋាយ បរិតព្វោ ឧបដ្ឋាតព្វោ'តិ អាចរិយោ (ជិនោ) ។

× ១៨– បុ. អាចារ្យមានប៉ុន្មានពួកគឺអ្វីខ្លះ? ចូររាប់ឲ្យត្រូវតាមរបៀបវិន័យ ហើយអធិប្បាយមកមើល ។

១៨– វិ. អាចារ្យមាន ៤ ពួក គឺបព្វជ្ជាចារ្យ ១, និស្សយាចារ្យ ១ ឧបសម្បទាចារ្យ ១, ឧទ្ទេសាចារ្យឬធម្មាចារ្យ ១។ លោកអង្គណាជាអ្នកឲ្យត្រៃសរណគមន៍នឹងសិក្ខាបទដល់សាមណេរ លោកអង្គនោះឈ្មោះជាបព្វជ្ជាចារ្យ គឺអាចារ្យឬគ្រូជាអ្នកបំបួសសាមណេរ; ភិក្ខុសាមណេរមកអង្គុយច្រហោងក្នុងទីចំពោះមុខ ហើយសុំនិស្ស័យដោយពាក្យថា: អាចរិយោ មេ ភន្តេ ហោហិ អាយស្មតោ និស្សាយ វច្ឆាមិ " បពិត្រព្រះករុណាដ៏ចំរើន! សូមព្រះករុណាជាអាចារ្យនៃខ្ញុំ ខ្ញុំសូមនៅអាស្រ័យនឹងព្រះករុណាដ៏មានអាយុ " ពោលដូច្នេះ ៣ ដង ក្នុងសំណាក់លោកអង្គណា លោកអង្គនោះព្រមទទួលជាអាចារ្យ ហើយសំដែងឲ្យដឹងដោយអាការ ឬវាចា លោកអង្គនោះឈ្មោះនិស្សយាចារ្យ ឬគ្រូអ្នកឲ្យនិស្ស័យ ; លោកអង្គណាជាអ្នកពោលនូវកម្មវាចា ឬ លោកអ្នកឲ្យនូវឧបសម្បទាជាភិក្ខុ លោកអង្គនោះឈ្មោះឧបសម្បទាចារ្យ គឺអាចារ្យក្នុងឧបសម្បទ ឬគ្រូសូត្រ ; លោកអង្គណាជាអ្នកបង្ហាត់បង្ហាញ

នូវបាលីក្តី អដ្ឋកថាក្តី ឬពន្យល់ប្រាប់នូវបទធម៌ណាមួយ លោកអង្គនោះឈ្មោះថា ឧទ្ទេសាចារ្យ ឬធម្មាចារ្យ គឺអាចារ្យឬគ្រូជាអ្នកបង្រៀនធម៌អាថ៌ ។

១៩- ប្រ. អាចារ្យមានដល់ទៅ ៤ ពួក, ចុះកូនសិស្សមានប៉ុន្មានដែរ?

១៩- វិ. ចំណែកខាងសិស្សក៏មាន ៤ ពួកដូចគ្នា គឺសិស្សទី១ ឈ្មោះបព្វជ្ជន្តេវាសិក គឺជាសិស្សនៃបព្វជ្ជាចារ្យ , សិស្សទី ២ ឈ្មោះនិស្សយន្តេវាសិក គឺជាសិស្សនៃនិស្សយាចារ្យ , សិស្សទី ៣ ឈ្មោះឧបសម្បទន្តេវាសិក គឺជាសិស្សនៃឧបសម្បទាចារ្យ, សិស្សទី ៤ ឈ្មោះឧទ្ទេសន្តេវាសិក ឬ ធម្មន្តេវាសិក គឺជាសិស្សនៃឧទ្ទេសាចារ្យ ឬធម្មាចារ្យ ។

២០- ប្រ. ចុះ ឧបជ្ឈាយ៍នោះមានសេចក្តីអធិប្បាយយ៉ាងណា? ថ្លែកពីអាចារ្យដូចម្តេច? នឹងសិស្សរបស់លោកនោះហៅយ៉ាងណាទៅវិញ?

២០- វិ. ឧបជ្ឈាយ៍នោះ មានសេចក្តីអធិប្បាយយ៉ាងនេះថា: សាមណេរក្តី ភិក្ខុក្តី ដែលពោលពាក្យសូមនូវនិស្ស័យ គឺសូមទីនៅអាស្រ័យដោយពាក្យថា: ឧបជ្ឈាយោ មេ ភន្តេ ហោហិ "បពិត្រព្រះករុណាដ៏ចំរើន! សូមព្រះករុណាជាឧបជ្ឈាយ៍នៃខ្ញុំ" ដូច្នេះចំពោះនឹងភិក្ខុអង្គណា

ភិក្ខុសង្ឃនោះ ឈ្មោះថាឧបជ្ឈាយ៍, ប្លែកពីអាចារ្យយ៉ាងនេះគឺ: អាចារ្យទាំង៤ពួកហៅតាមក្រសួងដែលលោកទាំងនោះត្រូវធ្វើ, ឯឧបជ្ឈាយ៍ហៅតាមអានុភាពដែលលោកជាធំ ជាអធិបតីលើអាចារ្យទាំងនោះ ឬលោកនឹងធ្វើការបំបួសជាដើម ផ្ទាល់ខ្លួនលោកក៏បាន ព្រោះលោកសម្រេចកិច្ចគ្រប់ជំពូកក្នុងការបំបួស, ព្រោះហេតុនោះបានជាព្រះដីកាចារ្យលោកចងជាបទវិគ្គហៈថា: អន្តេវាសិកសទ្ធិវិហារិកានំ - វជ្ជាវជ្ជំ- ឧបនិជ្ឈាយតី តិ ឧបជ្ឈាយោ (បើរៀ) «ព្រះថេរៈអង្គណាចូលទៅសំឡឹងមើលនូវទោសតូចនិងទោសធំ របស់អន្តេវាសិកនិងសទ្ធិវិហារិកទាំងឡាយ ព្រះថេរៈអង្គនោះឈ្មោះថាឧបជ្ឈាយ៍;ឯសិស្សរបស់លោកហៅថាសទ្ធិវិហារិកៗ

អាចារិយវគ្គទី ២ ចប់

---

# វិនយវគ្គ ទី ៣

៤១– ប្រ. វិន័យបានសេចក្ដីថាម៉េច? អ្វីហៅថាវិន័យ? ចូរអធិប្បាយហើយចងវិគ្គហៈមកមើល ?

៤១– វិ. វិន័យបានសេចក្ដីច្រើនយ៉ាង បើប្រែតាមរូបសព្ទថា «នាំទៅដោយវិសេស»; បើប្រែតាមអត្ថថា "ធម៌សម្រាប់ទូន្មាននូវកាយនិងវាចា»; ព្រះពុទ្ធបញ្ញត្តិនិងអភិសមាចារ រួមហៅថាវិន័យ; វិគ្គហៈថា: កាយវាចាយោ-វិនេតិ-ទមេតី'តិ វិនយោ(ធម្មោ) ឬថា «ធម៌សម្រាប់ទូន្មាន ឬជាទីនាំទៅដោយវិសេស នូវសត្វទាំងឡាយរបស់ព្រះដ៏មាន

ព្រះភាគ" វិគ្គហៈ ថា: វិនេតិ តេនា'តិ វិនយោ (ធម្មោ); វិនេតិ តស្មិ'ន្តិ វិនយោ (ធម្មោ) រូបទាំងអស់នេះបានសេចក្ដីថា: "សេចក្ដីរៀនប្រដៅកាយវាចា, ឬច្បាប់ទំលាប់សម្រាប់ប្រដៅ" ។

២២– បុ. វិន័យមានតាំងពីព្រះអង្គបានត្រាស់ជាដំបូងមកឬអ្វី ? ហេតុអ្វីបានជាទ្រង់បញ្ញត្តិវិន័យទុកមក ? ចូរនិយាយរៀបរាប់ពីទំនៀមទំលាប់របស់អ្នកទាំងពួងមកមើល ។

២២– វិ. មិនមែនមានតាំងពីមុនដំបូងមកទេ, ព្រោះថាក្នុងពេលដែលមានភិក្ខុសង្ឃតិចនៅឡើយ, ការគ្រប់គ្រងអភិបាលរក្សាមិនសូវជាទឹងត្រូវការប៉ុន្មានដែរ; សាវកទាំងពួង បាននាំគ្នាប្រព្រឹត្តតាមតែបដិបទារបស់ព្រះបរមគ្រូ ទឹងលោកទាំងនោះ បានជ្រាបពាក្យប្រៀនប្រដៅរបស់ព្រះអង្គទូទៅច្រើន; លុះដល់ពេលខាងក្រោយដែលមានភិក្ខុសង្ឃចំរើនច្រើនឡើងតាមលំដាប់កាល ហើយថែមទាំងបែកខ្ញែកគ្នាមិនបាននៅរួបរួមជាពួកជាមួយគ្នា ម្ល៉ោះហើយការគ្រប់គ្រងអភិបាលរក្សាក៏ត្រូវការច្រើនឡើងតាមនោះទៅ, មនុស្សយើងដែលនៅជាពួកជាបនៈនោះ ទឹងនៅតាមទំនើងខ្លួនឯងគ្រប់ ៗ គ្នាទៅមិនបាន ព្រោះសុទ្ធតែមានអធ្យាស្រ័យផ្សេងៗ គ្នា, មានកំឡាំងមិនស្មើគ្នា; អ្នកដែលមានអធ្យាស្រ័យអាក្រក់ទឹងមានកំឡាំងច្រើន មុខជាទឹងកំហែងធ្វើបាបធ្វើទោសអ្នកផងដោយឥតញញើត, ឯមនុស្សដែលមានអធ្យាស្រ័យស៊ីភាពរាបសារ

នឹងអ្នកដែលមានកំឡាំងតិច ក៏មុខជានឹងមិនបានសេចក្ដីសុខសប្បាយឡើយ; ព្រោះហេតុនោះបានជាព្រះបរមក្សត្រម្ចាស់ផែនដី តាំងច្បាប់ទំលាប់ឡើង ហាមប្រាមមិនឲ្យមនុស្សប្រព្រឹត្តនូវទុច្ចរិត ហើយមានតាំងដាក់ទោសអ្នកដែលប្រព្រឹត្តល្មើសទុកថែមទៀតផង ។ ក្រៅពីនេះក្នុងពួកក្រុមនិមួយៗ គេក៏ត្រូវមានទំនៀមទំលាប់ទុកសម្រាប់ប្រព្រឹត្តផងដែរ, ដូចយ៉ាងត្រកូលអ្នករម្យទមណ្ឌ គេតែងមានទំនៀមទម្លាប់សម្រាប់មនុស្សក្នុងត្រកូលនោះ; ឯពួកភិក្ខុក៏ត្រូវមានច្បាប់នឹងទំនៀមទម្លាប់សម្រាប់ការពារសេចក្ដីអន្តរាយ នឹងពន្យល់ណែនាំឲ្យប្រព្រឹត្តត្រឹមត្រូវដូចគ្នា ។ ព្រះបរមគ្រូជាម្ចាស់នៃយើង ព្រះអង្គទ្រង់តាំងនៅក្នុងទីជាព្រះធម្មរាជា ជាអ្នកគ្រប់គ្រងនឹងទ្រង់តាំងនៅក្នុងទីជាសង្ឃបិតា អ្នកមើលថែទាំភិក្ខុសង្ឃ បានជាព្រះអង្គទ្រង់ធ្វើកិច្ចទាំងពីរយ៉ាងនោះ; គឺទ្រង់តាំងព្រះពុទ្ធបញ្ញត្តិ ដើម្បីការពារសេចក្ដីប្រព្រឹត្តអាក្រក់នាំអន្តរាយ នឹងដាក់ទោសដល់ភិក្ខុដែលប្រព្រឹត្តល្មើស ដោយច្បាប់អាបត្តិ ធ្ងន់ខ្លះ, ស្រាលខ្លះ ដូចគ្នានឹងម្ចាស់ផែនដីដែលតាំងព្រះរាជបញ្ញត្តិ ; ម្យ៉ាងទៀតទ្រង់តែងតាំងទំនៀមទម្លាប់ដែលហៅថា អភិសមាចារៈ ដើម្បីដឹកនាំសេចក្ដីប្រព្រឹត្តរបស់ភិក្ខុសង្ឃឲ្យបានត្រឹមត្រូវដូចបិតាដែលជាធំក្នុងត្រកូល តែងបង្វឹកបង្ហាត់បុត្រធីតារបស់ខ្លួន ក្នុងទំនៀមទម្លាប់របស់ត្រកូលនោះដូច្នោះៗ ព្រះពុទ្ធបញ្ញត្តិនឹងអភិសមាចារៈទាំងពីរនេះ រួមហៅថាវិន័យ ។ វិន័យនេះឯង

លោកប្រៀបដូចចេស ឬ អម្បោះសម្រាប់ក្រងផ្កា, ចេស ឬ អម្បោះអាចនឹងរួបរឹតព័ន្ធព័ទ្ធផ្កាឈើដែលគេក្រងហើយ នោះមិនឲ្យផ្កាបែករោយខ្ចាត់ខ្ចាយចេញពីគ្នា ; ព្រោះហេតុថា អាចនឹងរក្សាផ្គុំឲ្យតាំងនៅដោយល្អបាន ។ ម្យ៉ាងទៀតមនុស្សដែលចេញមកពីត្រកូលផ្សេង ៗ ចូលមកបួសជាភិក្ខុសាមណេរនោះ ខ្ពស់ខ្លះ កណ្ដាលខ្លះ ទាបខ្លះ មានគោត្រពូជពង្សផ្សេងគ្នាមកពីដើម មានចិត្តគំនិតប្លែកៗគ្នា, យ៉ាងនេះ, បើប្រសិនណាជាមិនមានវិន័យគ្រប់គ្រង ឬ មិនប្រព្រឹត្តតាមវិន័យទេ មុខជានឹងក្លាយទៅជាភិក្ខុពោកពាបឥតរបៀប មិនជាទីតាំងនៃសទ្ធានិងសេចក្ដីជ្រះថ្លាឡើយ; បើផ្សេងតែរូបតែបានប្រព្រឹត្តតាមវិន័យហើយ ក៏នឹងបានជាពួកភិក្ខុយ៉ាងថ្លៃថ្លា នាំឲ្យកើតសទ្ធានិងសេចក្ដីជ្រះថ្លា; ដូចផ្កាឈើមានឈ្មោះផ្សេងគ្នា ប្រមូលមកច្របល់គ្នាក្នុងភាជន៍ បើទុកណាជាផ្កាខ្លះ មានពណ៌សណ្ឋានល្អមានក្លិនក្រអូប យ៉ាងណាក៏ដោយ, ព្រោះតែទោសដែលច្របូកច្របល់គ្នានោះឯង ក៏ក្លាយទៅជារបស់មិនគួរមើលមិនគួររីករាយឡើយ; ផ្កាទាំងនោះ បើប្រសិនជានាយមាលាការអ្នកឆ្លាតវៃ បេះដាក់ក្រងឲ្យចូលជារបៀបដោតធ្លាស់ចុះធ្លាស់ឡើងក្នុងកញ្ចុំនោះ ក៏ត្រឡប់ទៅជារបស់គួរពិតពិលរមិលមើលគួរជ្រះថ្លាបាន, កុំថាតែផ្កាដែលល្អនោះឡើយ សូម្បីតែផ្កាដែលមិនល្អក៏គង់ក្លាយទៅជារបស់ល្អវិញបាន គឺរបៀបនោះឯងដែលធ្វើឲ្យទៅជារបស់ល្អ ។

៦៣- បុ. ព្រះបរមគ្រូជាម្ចាស់នៃយើងទ្រង់បញ្ញត្តវិន័យព្រោះទ្រង់យល់ប្រយោជន៍ដូចម្ដេចខ្លះ មានប៉ុន្មានយ៉ាង? ចូរពប់នឹងអធិប្បាយមកមើល ។

៦៣- វិ. ព្រះបរមគ្រូទ្រង់បញ្ញត្តវិន័យព្រោះទ្រង់អាស្រ័យអំណាចប្រយោជន៍ ១០ យ៉ាងគឺ សង្ឃសុដ្ឋុតាយ ដើម្បីសេចក្ដីល្អដល់សង្ឃ ១, សង្ឃផាសុតាយ ដើម្បីការស្រួលដល់សង្ឃ ១, ទុម្មង្កូនំ ភិក្ខូនំ និគ្គហាយ ដើម្បីញាំញីពួកភិក្ខុ ដែលទ្រុស្ដសីល ១, បេស-លានំ ភិក្ខូនំ ផាសុវិហារាយ ដើម្បីនៅជាសុខដល់ពួកភិក្ខុ ដែលមានសីលជាទីស្រឡាញ់ ១, ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបច្ចុប្បន្ន ១, សម្បរាយិកានំ អាសវានំ បដិឃាតាយ ដើម្បីឃាត់នូវអាសវធម៌ទាំងឡាយក្នុងបរលោក ១, អប្បសន្នានំ បសាទាយ ដើម្បីញាំងពួកជនដែលមិនទាន់ជ្រះថ្លាឲ្យជ្រះថ្លា ១, បសន្នានំ ភិយ្យោភាវាយ ដើម្បីញាំងពួកជនដែលជ្រះថ្លាហើយ ឲ្យរឹតតែជ្រះថ្លាឡើង ១, សទ្ធម្មដ្ឋិតិយា ដើម្បីញាំងព្រះសទ្ធម្មឲ្យស្ថិតស្ថេរ ១, វិនយានុគ្គហាយ ដើម្បីអនុគ្រោះដល់ព្រះវិន័យ ( ៤ យ៉ាង មានសំវរវិន័យជាដើម ) ១ ។

២៤– ប្រ. វិន័យមានប្រយោជន៍ដូចម្តេចខ្លះ? បើអ្នកមិនចេះវិន័យនឹងដូចម្តេចទៅ? ចូរនិយាយរៀបរាប់មកមើល ។

២៤– វិ. វិន័យមានប្រយោជន៍ដ៏ធំ អាចនាំមកនូវសេចក្តីសុខដល់ភិក្ខុមានសីលជាទីស្រឡាញ់ទាំងឡាយ ជាសារៈទ្រទ្រង់ទុកនូវសាសនាផង ជាទីគោចររបស់ព្រះជិនស្រីជាសព្វញ្ញូផង មិនមែនជាវិស័យនៃបុគ្គលដទៃ ជាទីក្សេមក្សាន្តដែលព្រះដ៏មានព្រះភាគទ្រង់បញ្ញត្តហើយដោយប្រពៃ ដើម្បីសង្កត់សង្កិននូវពួកភិក្ខុ ដែលមានសេចក្តីប្រាថ្នាលាមកផង ដើម្បីដំកុំដំកើងនូវពួកភិក្ខុដែលមានសេចក្តីខ្មាសផង ដោយឥតសង្ស័យ លោកអ្នកប្រាជ្ញដែលមានប្រក្រតីធ្វើនូវប្រយោជន៍ដ៏សមគួរតែងប្រតិបត្តិក្នុងវិន័យនោះ ។

បុគ្គលណាមិនស្គាល់គោ បុគ្គលនោះនឹងរក្សាហ្វូងគោដូចម្តេចបានយ៉ាងណាវិញ; អ្នកឯណាមិនស្គាល់សីលអ្នកនោះនឹងរក្សាសេចក្តីសង្រួមក្នុងសីលដូចម្តេចបាន យ៉ាងនោះដែរ ។ អ្នកដែលមិនចេះវិន័យ ដូចអ្នកដែលឃ្វាលគោ ហើយមិនស្គាល់គោនោះឯង ។

ម្យ៉ាងទៀត បើទុកជាព្រះសូត្រនឹងព្រះអភិធម្មសាបសូន្យអស់ទៅហើយ តែបើព្រះវិន័យនៅមិនទាន់វិនាសនៅឡើយទេ ព្រះសាសនាឈ្មោះថាស្ថិតស្ថេរតទៅទៀតបាន ។

២៥–ប្រ. អ្នកប្រព្រឹត្តប្រតិបត្តិត្រឹមត្រូវតាមព្រះវិន័យហើយ នឹង

បានអានិសង្សយ៉ាងណាខ្លះ ?

២៤–វិ· ព្រះវិន័យនោះ បើអ្នកណាបានប្រតិបត្តិតាមដោយត្រឹមត្រូវហើយ រមែងបានអានិសង្សគឺសេចក្ដីមិនក្ដៅក្រហាយចិត្ត មិនបង្អៀតបង្អល់ចិត្ត ដែលហៅថាអវិប្បដិសារៈ ។ ភិក្ខុអ្នកប្រព្រឹត្តបន្ធូរបន្ថយខាងផ្លូវវិន័យរមែងបានទទួលវិប្បដិសារៈ , ព្រោះធ្វើអាកប្បកិរិយាឬកមារយាទមិនស្រួលខុសច្បាប់សម្រាប់ប្រទេស ត្រូវគេចាប់ចងដាក់គុកដាក់ច្រវាក់ខ្នោះឃ្នាងក៏មាន ត្រូវគេប្រមាថមើលងាយក៏មាន ឥតមានអ្នកណារាប់អានក៏មាន បើនឹងចូលទៅក្នុងពួកភិក្ខុដែលមានសីល ក៏ស្លុតរន្ធត់ខ្លាចគេចោទប្រកាន់ បើខុសណាជាឥតមានអ្នកណាថាអ្វីឲ្យ ក៏ចេះតែមានចិត្តអៀនអន់ខ្មាសខ្លួនឯង កាលបើបាននឹកឡើងមកដល់ខ្លួន ក៏តិះដៀលខ្លួនឯងបាន ឥតដែលមានសេចក្ដីត្រេកអររីករាយដល់ម្ដងឡើយ អានិសង្សរបស់ភិក្ខុអ្នកទ្រទ្រង់វិន័យនេះ បើរាប់ជាមាតិកាមាន ៥ យ៉ាងគឺ

១– អត្តនោ សីលក្ខន្ធោ សុគុត្តោ ហោតិ សុរក្ខិតោ វិនយធរភិក្ខុមានសីលក្ខន្ធរបស់ខ្លួនគ្រប់គ្រងល្អហើយ រក្សាត្រឹមត្រូវហើយ គឺថាមិនបានត្រូវនូវអាបត្តិតូចធំដោយអាការ៦ យ៉ាង ដូចភិក្ខុដទៃឡើយ ។

២– កុក្កុច្ចបកតានំ បដិសរណំ ហោតិ វិនយធរភិក្ខុនឹងបានជាទីពឹងនៃកុលបុត្រទាំងឡាយ ដែលកើតមានសេចក្ដីសង្ស័យ ។

៣– វិសារទោ សង្ឃមជ្ឈេ វោហរតិ វិនយធរភិក្ខុនឹងក្លៀវ

ក្លានិយាយវិន័យក្នុងកណ្តាលជំនុំសង្ឃ ដោយឥតមានសេចក្តីកោត
ញរញើតឬរួញរាភ័យតក់ស្លុត ។

៤– បព្វតិកេ សហធម្មេន សុនិគ្គហិតំ និគ្គណ្ហាតិ
វិនយធរភិក្ខុ អាចនឹងសង្កត់សង្កិននូវបុគ្គលដែលជាសត្រូវក្នុងសាសនា
ដោយសហធម៌គឺពាក្យប្រកបដោយហេតុបាន ។

៥– សទ្ធម្មដ្ឋិតិយា បដិបន្នោ ហោតិ វិនយធរភិក្ខុ បាន
ប្រតិបត្តិត្រឹមត្រូវល្អហើយ ដើម្បីញាំងព្រះសទ្ធម្មឲ្យដំកល់នៅបាន ។

៤៦–ឫ. វិន័យមានប៉ុន្មានយ៉ាងគឺអ្វីខ្លះ? ចូររាប់ហើយអធិប្បាយតែ
យ៉ាងសង្ខេបមកបានហើយ ?

៤៦–រឺ. វិន័យមាន ២ យ៉ាង គឺ: អាគារិយវិន័យ ១ អនាគា
រិយវិន័យ ១ ។ វិន័យដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតទុកមក សម្រាប់
ឲ្យពួកជនជាគ្រហស្ថ អ្នកនៅគ្រប់គ្រងគេហដ្ឋានកាន់កាប់ប្រតិបត្តិតាម
ហៅថា អាគារិយវិន័យ បានដល់កិរិយាវៀរចាកអកុសលកម្មបថ
ហើយប្រព្រឹត្តតាមកុសលកម្មបថនោះឯង; ។ វិន័យដែលព្រះអង្គទ្រង់
អនុញ្ញាតទុកមក សម្រាប់ឲ្យពួកបព្វជិត អ្នកមិនបាននៅគ្រប់គ្រងគេហ-
ដ្ឋាន គឺអ្នកដែលលះបង់គេហដ្ឋានចេញទៅបួស ទ្រទ្រង់ប្រតិបត្តិ
តាម ហៅថា អនាគារិយវិន័យ បានដល់វិន័យរបស់អ្នកដែលមិន
គ្រប់គ្រងផ្ទះនោះឯង ។

២៧–ប្រ. ផ្ទះរបស់គ្រហស្ថ នឹងកុដិលោកសង្ឃយើងសព្វថ្ងៃ ដូចគ្នាឬផ្សេងគ្នា? បើយ៉ាងហ្នឹងតើ លោកយើងសព្វថ្ងៃនៅគ្រប់គ្រងផ្ទះដូចជាគ្រហស្ថដែរ? ចូរឆ្លើយតាមសេចក្ដីយល់?

២៧–ឆ្លើ. ផ្ទះហើយនឹងកុដិដូចគ្នាឥតមានផ្សេងគ្នាទេ, ប៉ុន្តែគង់ប្លែកអំពីគ្រហស្ថដោយច្រើន ព្រោះគ្រហស្ថបើគេបានសង់ជាផ្ទះសម្រេចក្នុងកន្លែងណាមួយហើយ គេត្រូវជាឥស្សរៈជាធំត្រួតត្រាលើផ្ទះនោះ ឬបើគេចង់រុះរើទៅសង់នៅក្នុងទីដទៃវិញក៏បាន ឬក៏លក់ដូរយកថ្លៃទុនជាអម្រែសអម្រែពេញចិត្តក៏បាន ឥតមានពាក់ទាមទៅលើរបស់ទ្រព្យអ្នកណាឡើយ យ៉ាងនេះឯង ទើបបានឈ្មោះថាគេអ្នកគ្រប់គ្រងផ្ទះមែនៗ ឯពួកលោកសង្ឃ ពិតតែមានកុដិដូចជាផ្ទះរបស់គ្រហស្ថ ឬមានលំអថ្លៃថ្លាជាងគ្រហស្ថក៏មែន ប៉ុន្តែមិនមានអំណាចជាឥស្សរៈធំត្រួតត្រាលើកុដិនោះបាន, ព្រោះបើខ្លួននៅក្នុងកុដិណាមួយហើយ ក៏នៅតែខ្លួនម្នាក់ឯង មិនមានអំណាចយកប្រពន្ធកូន ឬ អ្នកដទៃក្រៅពីបព្វជិតដូចគ្នាទៅនៅផងមិនបាន,លុះដល់ខ្លួនលែងនៅហើយ ឥតមានអំណាចនឹងលក់ដូរយកកម្រៃពីកុដិនោះឡើយ, ព្រោះកុដិនុះមិនមែនជារបស់ខ្លួន សុទ្ធតែទាយកគេធ្វើ ដើម្បីឧទ្ទិសចំពោះសង្ឃដែលមកអំពីទិសទាំង ៤ មិនចំពោះរូបណាជារូបណាឡើយ, ព្រោះហេតុនោះបានជាថាលោកសង្ឃបើទុកជាមានកុដិថ្លៃថ្លាយ៉ាងណាក៏ដោយ ក៏គង់រាប់បញ្ចូលថាជាអនាគារិយ អ្នកគ្មានផ្ទះដែរ ។

២៨– ប្រ. ពួកសាមណេរមានវិន័យឬទេ? ហៅថាម៉េច? ក្នុងវិន័យទាំងពីរយ៉ាងនោះ រាប់បញ្ចូលក្នុងវិន័យណា ? ហេតុអ្វីក៏រាប់បញ្ចូលក្នុងវិន័យនោះដែរ ?

២៨– វិ. មាន, ហៅថាសាមណេរវិន័យ; បណ្ដាវិន័យទាំងពីរយ៉ាងនោះ, សាមណេរវិន័យរាប់បញ្ចូលក្នុងអនាគារិយវិន័យដែរ, បានជារាប់បញ្ចូលនោះ ព្រោះពួកសាមណេរក៏ជាបព្វជិតដូចភិក្ខុដែរ ។

២៩– ប្រ. សាមណេរវិន័យ វិន័យរបស់សាមណេរមានប៉ុន្មាន ?

២៩– វិ. វិន័យរបស់សាមណេរមាន ៣០ ។

៣០– ប្រ. ក្នុងវិន័យទាំង ៣០ នោះ បើចែកតាមឈ្មោះដើមមានប៉ុន្មានពួក ?

៣០– វិ. ក្នុងវិន័យទាំង ៣០ នោះ បើចែកតាមឈ្មោះដើមមាន ៣ ពួក គឺ សិក្ខាបទ ១០ ជាពួក ១, ទណ្ឌកម្ម ១០ ជាពួក ១, នាសនង្គ ១០ ជាពួក ១ ។

៣១– ប្រ. ចំណែកធម៌អ្វីឈ្មោះថាសិក្ខាបទ? សេចក្ដីខុសដូចម្ដេចឈ្មោះថាទណ្ឌកម្ម ? អង្គអ្វីឈ្មោះថានាសនង្គ ?

៣១– វិ. ចំណែកធម៌ដែលសាមណេរត្រូវសិក្សា ឈ្មោះថាសិក្ខាបទ, សេចក្ដីខុសដែលសាមណេរធ្វើឲ្យគេទូង គឺប្រព្រឹត្តល្មើសខុសក្នុងសិក្ខាបទ ៥ ខាងចុង ហើយភិក្ខុត្រូវធ្វើទោសមានឲ្យដងទឹកជាដើម

ដើម្បីទំនងឲ្យពងតាល ឈ្មោះថា ទណ្ឌកម្ម; អង្គនៃធម៌ដែលសាមណេរប្រព្រឹត្ត ល្មើសកន្លងសិក្ខាបទ ៥ ខាងដើម ដែលជាហេតុនាំត្រូវឲ្យសាមណេរ វិនាស គឺ ឲ្យសឹកចេញ ឈ្មោះថា នាសនង្គ ។

៣២– ប្រ. សាមណេរមានកិច្ចសិក្សាពីត្រឹមណា ទៅដល់ត្រឹមណា?

៣២– វិ. ឥតមានទីបំផុតទេ, ប៉ុន្តែបើគ្រាន់តែគបឲ្យឃើញតែ កិច្ចដែលត្រូវសិក្សាជាមុនបណ្ដើរសិននោះដូច្នេះ គឺត្រូវសិក្សាតាំងពី សិក្ខាបទ, ទណ្ឌកម្ម, នាសនង្គនិងវត្ត មានសេខិយវត្តជាដើម ។

៣៣– ប្រ. សាមណេរប្រព្រឹត្តកន្លងសិក្ខាបទ ១០ នោះ មានទោស គួរដល់នាសនង្គតើប៉ុន្មានសិក្ខាបទ? ប៉ុន្មានសិក្ខាបទគួរដល់ទណ្ឌកម្ម ?

៣៣– វិ. សាមណេរប្រព្រឹត្តកន្លងសិក្ខាបទ ១០ នោះ មាន ទោសគួរដល់នាសនង្គ ៥ សិក្ខាបទខាងដើម, គួរដល់ទណ្ឌកម្ម ៥ សិក្ខាបទខាងចុង ។

វិន័យវត្តទី ៣ ចប់

---

## ទណ្ឌកម្មវគ្គទី ៤

៣៤– ប្រ. ថ្ងៃរសៀលហើយ តែមេឃងងឹតមើលមិនឃើញ ពន្លឺថ្ងៃ សាមណេរសំគាល់ថាថ្ងៃនៅត្រង់ ហើយឆាន់បង្អាន់ទៅ ត្រូវ ទណ្ឌកម្មឬទេ? ព្រោះហេតុអ្វី?

៣៤– វិ. ត្រូវទណ្ឌកម្មពេញទី ព្រោះសិក្ខាបទនេះជាអចិត្តកៈ

សំដៅយកពេលជាប្រមាណ មិនបានសំគាល់យកចិត្តមកជាប្រមាណ ។

៣៥– ប្រ. ថ្ងៃមិនទាន់ដែតីត្រង់ទេ តែសាមណេរសំគាល់ជាថ្ងៃរសៀលហើយៗឆាន់ចង្ហាន់ទៅ ត្រូវទណ្ឌកម្មឬទេ? ព្រោះហេតុអ្វី?

៣៥– វិ. មិនត្រូវទណ្ឌកម្មឡើយ ព្រោះពេលនៅមិនទាន់ហួស ។

៣៦– ប្រ. សាមណេរកំពុងដេកលក់ ឥតមានដឹងខ្លួនប្រាណ, មានអ្នកដទៃយកភោជនាហារទៅបញ្ចុកក្នុងមាត់វេលាវិកាល ; សាមណេរនោះក៏លេបផុតបំពង់កទៅ, ត្រូវទណ្ឌកម្មឬទេ? ព្រោះហេតុអ្វី?

៣៦– វិ. សាមណេរនោះត្រូវទណ្ឌកម្មពេញទី, ព្រោះសិក្ខាបទនោះជាអចិត្តកៈ ទោះមានចិត្តក្តីមិនក្តី ដឹងស្មារតីឬមិនដឹង មិនជាប្រមាណក្នុងសិក្ខាបទនោះឡើយ, ឲ្យតែលេបរបស់ដែលជាយាវកាលិក ផុតបំពង់កទៅហើយ ក៏ចេះតែត្រូវទោសទាំងអស់ ។

៣៧– ប្រ. សាមណេរបរិភោគវត្ថុដូចម្តេច ដែលមិនត្រូវទណ្ឌកម្ម?

៣៧– វិ. សាមណេរបរិភោគតែរបស់ ដែលជាយាមកាលិក, សត្តាហកាលិក និងយាវជីវិកដោយមានហេតុគួរបរិភោគបាន ឬ សាមណេរឆ្កួត, សាមណេរដើមបញ្ញត្តិយ៉ាងនេះមិនត្រូវទណ្ឌកម្មឡើយ ។

៣៨– ប្រ. យ៉ាងម៉េចហៅថា កាលិក? មានប៉ុន្មានយ៉ាង?

គឺអ្វីខ្លះ? ចូរកត់ហើយអធិប្បាយមកមើល ។

៣៨–វិ. វត្ថុដែលបរិភោគក្នុងកាល ឬប្រកបដោយកាល ហៅថា កាលិក មាន៤ យ៉ាង គឺ យាវកាលិក១, យាមកាលិក១, សត្តាហកា-លិក១, យាវជីវិក១។ របស់ដែលទទួលប្រគេនហើយ ទុកឆាន់តាំងពីអរុណរះឡើងដរាបដល់ថ្ងៃត្រង់អស់អំណាច ហៅថា យាវកាលិក; វត្ថុដែលទទួលប្រគេនហើយទុកឆាន់បានតែត្រឹម១ថ្ងៃហៅថា យាមកា-លិក; របស់ដែលទទួលប្រគេនហើយទុកឆាន់បានតែត្រឹម ៧ ថ្ងៃផុត ហៅថា សត្តាហកាលិក; របស់ដែលទទួលប្រគេនហើយទុកទាល់តែអស់ ហៅថា យាវជីវិក ។

៣៩–ប្រ. របស់យ៉ាងណា គួរសង្គ្រោះចូលក្នុងកាលណា? ចូរឆ្លើយឲ្យសព្វគ្រប់មកមើល ?

៣៩– វិ. ខាទនីយៈនិងភោជនីយាហារ (បង្អែមនិងចំអាប) ត្រី, សាច់, អង្ករ ជាដើម នេះគួរសង្គ្រោះចូលក្នុងយាវកាលិក។ ទឹក៨ ប្រការ គឺ: អម្ពបានំ ទឹកផ្លែស្វាយ១, ជម្ពុបានំ ទឹកផ្លែព្រីង១, ចោចបានំ ទឹកផ្លែចេកមានគ្រាប់១, មោចបានំ ទឹកផ្លែចេកឥតគ្រាប់១, មធុបានំ ទឹកផ្លែស្រគំ១, មុទ្ទិកបានំទឹកផ្លែចន្ទន៍ ១, សាលុកបានំ ទឹកក្រអៅឈូក១, ផារុសកបានំ ទឹកផ្លែមាកប្រាង១, ទឹកទាំង៨ ប្រការនេះគួរសង្គ្រោះចូលក្នុងយាមកាលិក។ ថ្នាំ៥ ប្រការ គឺសប្បិ ទឹកដោះ

រាវ១, នវនីតំ ទឹកដោះខាប់១, តេលំ ប្រេង១, មធុ ទឹកឃ្មុំ១, ផាណិតំ ស្ករអំពៅ១; ថ្នាំ៥ប្រការនេះ គួររាប់ចូលក្នុងសត្តាហកាលិក ។ ភេសជ្ជៈជាថ្នាំមានថ្នាំត្រាជាដើម ទទួលប្រគេនទុកឆាន់ទាល់តែអស់ថ្នាំនោះបាន នេះគួរសង្គ្រោះចូលក្នុងយាវជីវិក ។

៤០–ប្រ. ទ្រង់អនុញ្ញាតភេសជ្ជៈជាថ្នាំនោះ តើឲ្យយករបស់អ្វីមកធ្វើជាថ្នាំបានខ្លះ? ចូរនិយាយឲ្យសព្វគ្រប់មកមើល ។

៤០–វិ. ថ្នាំដែលទ្រង់អនុញ្ញាតនោះ គឺឲ្យយកមើមរមៀត, មើមខ្ញី មើមលំពាន់, មើមប្រស់, មើមអាចម៍ត្តិះ, មើមរំដេង, មើមស្បូវក្ដាំង, មើមស្មៅក្រាញ់ជ្រូក, និងទឹកបត់កើតអំពីដើមស្ដៅ, ទឹកបត់កើតអំពីដើមក្រូចគន់ ទឹកបត់កើតអំពីដើមអម្បែងនៃថ្ង, ទឹកបត់កើតអំពីវល្លិបណ្ដូលពេជ្រ, ទឹកបត់កើតអំពីដើមទន្លាប់ ឬថ្វាន់, និងស្លឹកស្ដៅ, ស្លឹកក្រូចគន់, ស្លឹកអម្បែងនៃថ្ង, ស្លឹកម្រះព្រៅ ឬជរល័ងលាក់, ស្លឹកកប្បាសនិងផ្លែពិលង្គ, ផ្លែដីប្លី, ផ្លែម្រេច, ផ្លែសម៉, ផ្លែសម៉ពីភេក, ផ្លែកន្ទួតព្រៃ, ផ្លែក្រវាញ, និងជ័រដែលហូរចេញអំពីដើមហិង្គុ, ជ័រដែលគេយកស្លឹកនិងមែកហិង្គុមករម្ងាស់, ជ័រដែលគេយកតែស្លឹកហិង្គុតែម្យ៉ាងមករម្ងាស់, (ជ័រទាំង ៣ យ៉ាងនេះជាជាតិហិង្គុទាំងអស់) ជ័រដែលហូរចេញអំពីត្រួយឈើ, ជ័រដែលហូរចេញអំពីស្លឹកឈើ. ជ័រដែលគេបេះស្លឹកឈើយកមកធ្វើ, កំញាន, និងអំបិលកើតក្បែរឆ្នេរសមុទ្រមានបែបដូចជ

១រួប, អំបិលមានពណ៌ខ្មៅ(គឺអំបិលប្រៃ), អំបិលមានពណ៌សកើតលើភ្នំ,អំបិលមានពន្លកដុះអំពីផែនដី(គឺអំបិលដែលកើតអំពីរាបម៉ដីមានរសប្រៃ) អំបិលមានពណ៌ក្រហមដែលគេចំអិនជាមួយនឹងសម្ភារៈ ទាំងឡូង;គេសុដ្ឋះប៉ុណ្ណោះជាដើម ទ្រង់អនុញ្ញាតឲ្យទទួលហើយរក្សាទុកដរាបតាលស់បាន, កាលបើមានហេតុទើបឆាន់បាន, បើគ្មានហេតុទេ ហើយឆាន់ត្រូវទុក្កដ ។

៤១– ប្ញ. សាមណេរដើរទៅបិណ្ឌបាត ក្រឡេកមើលទៅឃើញគេលេងល្បែងហើយដើរហួសទៅ ត្រូវទុក្កដឬទេ ?

៤១– វិ. បើកាត់តាមខុទ្ទកសិក្ខាបទមិនត្រូវទុក្កដទេ, តែបើតាមន័យក្នុងសេខិយសិក្ខាបទទី ៧ នៃសារូបជាត្រូវទុក្កដពេញទី ។

៤២– ប្ញ. អ្នកផងគេតែងរាប់អានណាស់ការកំនឹងប្រៀង ចំណែកខាងព្រះបរមគ្រូរបស់យើង ហេតុដូចម្តេចក៏បានជាទ្រង់ហាមឃាត់ការកំនឹងប្រៀងនោះ? ចូរឆ្លើយតាមសេចក្តីយល់ ។

៤២– វិ. ព្រះសម្មាសម្ពុទ្ធទាំងឡាយគ្រប់ព្រះអង្គ ដែលបានត្រាស់ដឹងក្នុងលោក ព្រះអង្គឥតមានបំណងចង់ឲ្យសត្វលោកពាល់គ្នាតែកាយសប្បាយដោយកាមគុណនោះទេ ព្រោះជាហេតុនាំសត្វឲ្យលិចលង់ក្នុងសង្សារវដ្តយឺតយូរ បានជាទ្រង់ហាមឃាត់ការកំប្រៀងនោះ ក៏ដើម្បីធ្វើសត្វឲ្យគាន់តែឃ្លាតចាក រូប, សម្លេង, ក្លិន, រស, ផស្សព្វ បន្តិចម្តងៗនឹង

ចាប់បានធ្វើជាតិកំណើតឲ្យបានទៅ, ហើយដោយទ្រង់យល់ឃើញទោស
របស់ចម្រៀង ៤ យ៉ាងផងគឺ អត្តនោបិ តស្មិំ សរេ សារជ្ជតិ
សមណៈអ្នកច្រៀងត្រេកអរក្នុងសំឡេងរបស់ខ្លួននោះ ១, បរេបិ តស្មិំ
សរេ សារជ្ជន្តិ ជនទាំងឡាយដទៃរមែងត្រេកអរក្នុងសំឡេងនោះ ១,
គហបតិកាបិ ឧជ្ឈាយន្តិ គហបតីទាំងឡាយ តែងពោលទោស ១,
សរកុត្តិបិ និកាមយមានស្ស សមាធិស្ស ភង្គោ ហោតិ
បុគ្គលដែលពេញចិត្តនឹងការសូត្រលាក់លែកសម្លេង រមែងខូចសមាធិ ១
បច្ឆិមា ជនតា ទិដ្ឋានុគតិមាបជ្ជតិ ពួកជនខាងក្រោយ នឹងដើរ
នូវទិដ្ឋានុគតិ (យកជម្រាប់តាម) ១ ; ទ្រង់យល់ឃើញទោសរបស់
ការច្រៀងប៉ុណ្ណោះ បានជាទ្រង់ឃាត់ហាមអំពើនុះមិនឲ្យមាន ។

៤៣– ប្រ. ទ្រង់ហាមឃាត់មិនឲ្យមើលរាំនឹងច្រៀងខ្លួនឯងតែ
ប៉ុណ្ណោះទេឬ ឬហាមយ៉ាងម៉េចទៅទៀត ?

៤៣– វិ. ទ្រង់ហាមឃាត់ មិនឲ្យមើលរាំ ស្តាប់ច្រៀង, ស្តាប់
ប្រគំតូរ្យតន្ត្រីផ្សេងៗក្នុងលោក, រាំច្រៀងខ្លួនឯងក៏មិនបាន, ទៅមើល
ឬស្តាប់គេក៏មិនបាន ។

៤៤– ប្រ. ចូរអធិប្បាយអំពីសីលនច្ចគីត នឹងមាលាមកឲ្យ
ឃើញថាផ្សេងគ្នាដូចម្តេចខ្លះ ?

៤៤– វិ. សីលនច្ចគីតនោះ គឺហាមមិនឲ្យរាំ, ច្រៀង, ប្រគំ;

តែក្រោយលេងល្បែងទៀងបានលេងបាសកាមានក្រឡាប្រាំបី (ចត្រង្គមានក្រឡា ៨) លេងបាសកាមានក្រឡាដប់ (ចត្រង្គមានក្រឡា ១០ ឬ បាយ ១), លេងបាសកាក្នុងអាកាស (ចត្រង្គគ្មានក្តារលេងថាតែមាត់ទទេ), លេងបិទមុខបិទខ្លួន, លេងផ្ទាត់គ្រាប់មានគ្រួសជាដើម, លេងបាសកាក្នុងលានសម្រាប់លេង, លេងហ៊ុង, លេងដោយរលាស់ទឹកល័ក្តឲ្យទាយរូប, លេងអង្គញ់, លេងផ្ទុំបុំស្ទឹក, លេងខង្គ័លតូច, លេងដាំដូង, លេងកង្ហារ, លេងកល់ដីខ្ទុប (បាយខ្សុកបាយខ្សែ) លេងរថតូច, លេងធ្នូតូច, លេងសរសេរខ្យល់ឲ្យទាយ, លេងទាយចិត្ត (ស្តេចបង់) លេងកំប្លែងត្រាប់គេ, ហាត់ដំរី, ហាត់សេះ ហាត់រថ, ហាត់ធ្នូ ហាត់ដងមានដងដាវជាដើម, ... ស្រែកហោកញ្ជ្រៀវ, ទះដៃ, ចំបាប់គ្នា, ដាល់គ្នា, ហាត់គុណ, ទាត់សីជាដើម ៗ ឯសីលមាលានោះ គឺហាមមិនឲ្យសាមណេរទ្រទ្រង់នូវប្រដាប់ នឹងតាក់តែងស្អិតស្អាងរាងកាយដោយផ្កាកម្រង នឹងគ្រឿងក្រអូប នឹងគ្រឿងលាបផ្សេងៗ មានទឹកអប់នឹងម្សៅលាបមុខជាដើម នឹងហាមមិនឲ្យផាត់មុខ, ដុសខាត់មុខ, ប្រស់មុខ, ចុចមុខប្ដូមមុខ ដោយថ្មនោសិលា ឬម្សៅ,មិនឲ្យលាបខ្លួន, លាបមុខជាដើម ; សីលនច្ចគីតនឹងមាលាផ្សេងគ្នាដូចអធិប្បាយមកនេះ ៗ

៤៥– ប្រ. ទីដេកទីអង្គុយដូចម្តេចដែលហៅថា ទីសេនាសនៈ

ដ៏ខ្ពស់ហួសប្រមាណ និងទីសេនាសនៈដ៏ប្រសើរនោះ?

៤៥–វិ. ទីសេនាសនៈដ៏ខ្ពស់ហួសប្រមាណនោះ គឺគ្រែឬតាំងដែល មានជើងខ្ពស់ ឬគេជម្កល់ឲ្យខ្ពស់ជាង ៨ ធ្នាប់ព្រះសុគត ។ ទីសេនាសនៈ ដ៏ប្រសើរនោះ គឺកន្ទេលដេក ឬទីអង្គុយណាមួយដែលគេក្រាលដោយ កម្រាលដ៏វិចិត្រផ្សេងៗ មានពូកញាត់ដោយសំឡីគរ ឬកប្បាស កំពស់ ១ ចំអាម ឬ ១ ហត្ថ អង្គុយទ្រុឌចុះទៅ ក្រោកហ៉ើងឡើងជាដើមហៅ ថា ទីសេនាសនៈដ៏ប្រសើរ ។

៤៦– ឬ អាសនៈខ្ពស់អាសនៈប្រសើរនោះ តើមានប៉ុន្មាន យ៉ាង? គឺអ្វីខ្លះ?

៤៦–វិ. អាសនៈខ្ពស់អាសនៈប្រសើរនោះមាន ២០ យ៉ាងគឺ,

១ អាសន្ទិ អាសនៈដែលខ្ពស់ហួសប្រមាណ, ២ បល្លង្ក គ្រែដែល មានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ, ៣ គោណក ព្រំដែលមាន រោមវែងជាង ៤ ធ្នាប់, ៤ ចិត្តក កម្រាលដែលគេធ្វើពីរោមសត្វវិចិត្រ ដោយរូបសត្វសាហាវ, ៥ បដិក កម្រាលមានពណ៌សដែលធ្វើដោយ រោមសត្វ, ៦ បដលិក កម្រាលដែលធ្វើដោយរោមសត្វជាផ្កាចង្កោម, ៧ តូលិក កម្រាលដែលញាត់ដោយសំឡីគរ, ៨ វិកតិក កម្រាលដែល ធ្វើដោយរោមសត្វ វិចិត្រដោយរូបសត្វមានសីហ, និងខ្លាធំជាដើម, ៩ ឧទ្ធលោមិ កម្រាលដែលធ្វើដោយរោមសត្វមានរោមចេញតែម្ខាង,

១០ ឯកន្តលោមិ កម្រាលដែលធ្វើដោយរោមសត្វមានរោមចេញទាំងពីរ ខាង, ១១ កដ្ឋិស្ស កម្រាលដែលធ្វើដោយខិនមាសនឹងសូត្រ ហើយ ចាក់ស្រែះដោយកែវគត្ន, ១២ កោសេយ្យ កម្រាលដែលធ្វើដោយ សរសៃសូត្រហើយចាក់ស្រែះដោយកែវគត្ន. ១៣ កុត្តក កម្រាលដែល ធ្វើដោយរោមសត្វល្មមពួកស្រីរបាំ ១៦ នាក់ ឈររាំបាន,១៤ ហត្ថត្ថរ កម្រាលសម្រាប់ក្រាលលើខ្នងដំរី, ១៥ អស្សត្ថរកម្រាលសម្រាប់ក្រាល លើខ្នងសេះ, ១៦ រថត្ថរ កម្រាលសម្រាប់ក្រាលលើរថ, ១៧ អជិនប្ប វេណី កម្រាលដែលគេធ្វើដោយស្បែកខ្លាឃ្មុំ, ១៨ កទលិមិគបវរ បច្ចត្ថរណា កម្រាលដ៏ឧត្តមដែលគេធ្វើដោយស្បែកសត្វឈ្លូស, ១៩ សឧត្តរច្ឆទ ពិដានដែលមានពិតានក្រហមពីខាងលើ. ២០ ឧភតោ លោហិតកុបធានំ កម្រាលដែលមានខ្នើយមានពណ៌ក្រហមទាំងពីរ ខាងគឺខ្នើយក្បាលនឹងខ្នើយជើង ។

៤៧– ឬ. អាសនៈទាំង ២០ នេះ សុទ្ធតែហាមដាច់មិនឲ្យអង្គុយ មិនឲ្យដេកទាំងអស់ ឬក៏មានអនុញ្ញាតយ៉ាងណាដែរ ?

៤៧– វិ. អាសនៈទាំង ២០ លើកតែ អាសន្ទិ ១, បល្លង្ក ១. តូលិក ១, ទាំង ១៧ នេះទ្រង់អនុញ្ញាតឲ្យអង្គុយបាន ដេកមិនបាន ។ ឯអាសនៈទាំង ៣ នុះ អង្គុយក៏មិនបាន ដេកក៏មិនបាន ។

× ៤៨– ឬ. បើសាមណេរទៅអង្គុយលើផ្ទះគេ ហើយគេក្រាល

ពូកលើគ្រែកំពស់ ៧៥ សង់ទីម៉ែត្រឲ្យអង្គុយ ហើយសាមណេរអង្គុយ ទៅតើត្រូវទុក្កដកម្មឬទេ? ព្រោះហេតុអ្វី?

៤៨– វិ. មិនត្រូវទុក្កដកម្មឡើយ ព្រោះជាគិហិវិកតិគឺជាអាសនៈដំបូកសម្រាប់គ្រហស្ថ ។

៤៩– ឬ. ពូកដែលព្រះអង្គទ្រង់អនុញ្ញាត ឲ្យសាមណេរប្រើប្រាស់បាននោះតើមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូរអធិប្បាយ ។

៤៩– វិ. ពូកដែលព្រះអង្គទ្រង់អនុញ្ញាតឲ្យសាមណេរប្រើប្រាស់បាននោះមាន ៥ យ៉ាងគឺ ឧណ្ណភិសិ ពូកញាត់ដោយរោមកែះ ១, ចោឡភិសិ ពូកញាត់សំពត់ ១, វាកភិសិ ពូកញាត់សម្បកឈើ ១, តិណភិសិ ពូកញាត់ស្មៅ ១, បណ្ណភិសិ ពូកញាត់ស្លឹកឈើ ១ ។

៥០– ឬ. គ្រែ, តាំងនិងកៅអីដូចម្ដេចខ្លះ ដែលទ្រង់អនុញ្ញាតឲ្យដេក-អង្គុយបាន? ចូរអធិប្បាយ ។

៥០– វិ. គ្រែ ដែលទ្រង់អនុញ្ញាតឲ្យដេកអង្គុយបាននោះមាន ៤ យ៉ាងគឺ មសារក គ្រែដែលគេបញ្ចូលមេទៅក្នុងដំណាក់ជើង ១, ពុន្ទិកាពទ្ធ គ្រែដែលមានមេជាប់នឹងជើង ១; កុលីរបាទក គ្រែដែលមានជើងដូចជាជើងក្ដាម ១, អាហច្ចបាទក គ្រែដែលមានជើងចុះ ឬ គ្រែដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ១ ។ តាំងក៏មាន ៤ យ៉ាងគឺ មសារក តាំងដែលគេបញ្ចូលមេទៅក្នុងដំណាប់ជើង ១, ពុន្ទិកាពទ្ធ,

តាំងដែលមានបេះគេបន្ទាំជាប់នឹងជើង ១, កុលិរបាទក តាំងដែលមានជើងដូចជាជើងក្តាម ១, អាហច្ចបាទក តាំងដែលមានជើងចុច ឬតាំងដែលគេបញ្ចូលជើងទៅក្នុងដំណាប់មេ ១, ឯកៅអីនោះគឺ កៅអីដែលគេធ្វើដោយសម្បកឈើក្តី ធ្វើដោយស្បូវក្លាំងក្តី ធ្វើដោយស្មៅយាប្លង់ក្តី ធ្វើដោយសៅដំណេកទន្សាយក្តី ដែលគេរុំហើយចងភ្ជាប់គ្នាខាងក្នុងក្តី តាំងអស់នេះសុទ្ធតែទ្រង់អនុញ្ញាតឲ្យដេកឬអង្គុយបាន តែកុំតែធ្វើឲ្យខ្ពស់ហួសប្រមាណ ។

៨១– ប្រ. សាមណេរទុកដាក់ប្រាក់មាសរបស់អ្នកដទៃ ត្រូវទណ្ឌកម្មឬទេ? ព្រោះហេតុអ្វី?

៨១– វិ. មិនត្រូវទណ្ឌកម្ម, ព្រោះសាមណេរមិនមានអនាមាសទណ្ឌកម្ម ។

៨២– ប្រ. ពាក្យថាសាមណេរព្យាយាម ដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ នេះមានសេចក្តីថាម៉េច? ចូរអធិប្បាយមកមើល?

៨២– វិ. សាមណេរព្យាយាមដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយនោះសេចក្តីថា: បើទាយកគេយកបច្ច័យទាំង ៤ ណាមួយ បម្រុងនឹងប្រគេនពួកភិក្ខុឈ្មោះនេះ, សាមណេរដឹងថាទាយកគេបម្រុងនឹងប្រគេន ពួកភិក្ខុដូច្នោះហើយ ក៏ទៅខ្នះខ្នែងរកឧបាយកលនិយាយបញ្ចុះបញ្ចៀងថា: ណោះណោះ, [illegible] ពួកភិក្ខុនោះ

លោកមានបច្ច័យទាំង ៤ គ្រប់គ្រាន់ហើយ លោកមិនខ្វះខាតទេ, បើលោកអ្នកចង់បានបុណ្យច្រើននោះ គួរតែយកទៅប្រគេនពួកភិក្ខុឯណោះវិញ ព្រោះលោកជាអ្នកដាច់ដាបមិនសម្បូណ៌, ឬក៏និយាយប្រាប់គេថា លោកមិនបេះធាន់ចង្ហាន់បែបនេះទេ, លោកឯណោះទើបលោកចូលចិត្ត, ឬបើមិនដូច្នោះទេ ក៏និយាយដោយហេតុឯណានិមួយ ទាល់តែទាយកនោះខានប្រគេនរបស់នោះទៅពួកភិក្ខុនោះទៅ យ៉ាងនេះហៅថាសាមណេរព្យាយាម ដើម្បីនឹងឲ្យសាបសូន្យលាភរបស់ភិក្ខុទាំងឡាយ ។

៤៣ — ប្រ. សាមណេរព្យាយាម ដើម្បីនឹងមិនឲ្យជាប្រយោជន៍ដល់ភិក្ខុទាំងឡាយ, ប្រយោជន៍ក្នុងទីនេះសំដៅយកអ្វី ? គឺអ្វី ?

៤៣—វិ. ប្រយោជន៍ក្នុងទីនេះ តាមអដ្ឋកថាលោកសំដៅយកឧបទ្រព គឺបៀតបៀនភិក្ខុឲ្យមានភ័យអន្តរាយ គឺធ្វើឲ្យភិក្ខុបង្អៀតបង្អល់ចិត្តរករៀនសូត្រអ្វីមិនកើត ឬធ្វើការផងទាំងពួងមិនបាន ។

៤៤—ប្រ. សាមណេរព្យាយាមដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបាននូវទីលំនៅ, ចូរអធិប្បាយមកមើល សេចក្ដីយ៉ាងណា ?

៤៤—វិ. សេចក្ដីយ៉ាងនេះថា: ដូចជាភិក្ខុនៅក្នុងអាវាស ឬកន្លែងណាមួយ សាមណេរកើតចិត្តស្អប់ក្នាញ់ មិនចូលចិត្តនឹងភិក្ខុនោះ មិនចង់ឲ្យលោកនៅក្នុងទីនោះផង ក៏ស្វះស្វែងរករឿងចាក់រុក ។ បើទី

កន្ទេលនោះហេតុទាយកជាម្ចាស់ ក៏ទៅនិយាយនឹងទាយកនោះថា: លោកភិក្ខុដែលនៅនឹងទីកន្ទេលរបស់អ្នកនោះ ជាមនុស្សទុច្ចរិតមិនប្រតិបត្តិធម៌-វិន័យ, ខ្ជិលច្រអូសឥតរៀនសូត្រ, ដេកធាត់ ៗ បៀតបៀនអ្នករៀនសូត្ររកតែគេនៅផងមិនបាន គួរអ្នកបណ្ដេញលោកនេះចេញ ដើម្បីឲ្យពួកអ្នករៀនបាននៅច្រើន, ទាយកក៏បណ្ដេញលោកចេញពីទីនោះទៅ; ឬក៏ទៅទូលពិត្រលោកគ្រូមេវត្តឲ្យលោកបណ្ដេញចេញពីទីអាវាស ផ្សព្វរឿងកំរិបន្តិចបន្តួចទាល់តែលោកនេវាសិកាចារ្យនោះបណ្ដេញចាកទីកន្ទេលនោះទៅ; បើមិនយ៉ាងនោះទេ , ដូចជាភិក្ខុសុំទីកន្ទេលវត្តណាមួយបានហើយ ក៏ក្លង់ធ្វើសំបុត្រឬផ្ដាំទៅនឹងគេឯងថា សូមឲ្យលោកចៅអធិការវត្តនោះ កុំឲ្យលោកឈ្មោះនេះនៅ ព្រោះលោកនេះជាមនុស្សខិលខូចប្រព្រឹត្តអាក្រក់មិនត្រឹមត្រូវ កាលនៅឯណោះគេបណ្ដេញចេញ ព្រោះរឿងយ៉ាងនេះមួយៗ បើដូច្នោះគួរតែកុំឲ្យនៅ រករឿងទាល់តែភិក្ខុនោះខានបាននៅទៅ; ឬក៏ឃើញលោកនៅត្រង់កន្ទេលណា ក៏តាំងយករបស់ដែលមានក្លិនអាក្រក់ ទៅលបដាក់ឲ្យជិតស្អុយលោកព្រោះនៅមិនបានពុំនោះក៏យកក្រែគឬតាំងទៅក្រោលដេកនៅប៉ែរជៀតស្រែកឲ្យខ្សាឲ្យលោកធុញទ្រាន់, លោកនៅទីនោះមិនកើតលែងនៅទៅ; យ៉ាងនេះឯង ហៅថាសាមណេរព្យាយាមដើម្បីនឹងមិនឲ្យភិក្ខុទាំងឡាយបាននៅទីលំនៅ ។

៤៤– ប្រ. សាមណេរជេរប្រទេចទូវភិក្ខុទាំងឡាយ, ពាក្យដូចម្ដេចដែលហៅថា ជេរ? មានប៉ុន្មានយ៉ាង?

៤៤– វិ. ពាក្យប្រទេចផ្ដាសា មិនជាទីគាប់ចិត្ត មិនជាទីពេញចិត្ត ដែលអ្នកផងមិនត្រូវការចង់ឮ ដែលនាំឲ្យចាក់ដោតត្រចៀក, នាំឲ្យខឹងអត់ទ្រាំមិនបាន ហៅថា "ជេរ"; មាន ២ យ៉ាង គឺជេរយ៉ាងថោកទាប ១, ជេរយ៉ាងខ្ពង់ខ្ពស់ ១ ។

៤៦– ប្រ. ដូចម្ដេច ហៅថា ជេរយ៉ាងថោកទាប? ដូចម្ដេចហៅថា ជេរយ៉ាងខ្ពង់ខ្ពស់? សាមណេរជេរភិក្ខុត្រូវទោសអ្វី?

៤៦– វិ. ដែលហៅថា ជេរយ៉ាងថោកទាប គឺជេរថាលោកជាសត្វឱដ្ឋ, លោកជាសត្វពពែ, លោកជាសត្វគោ, លោកជាសត្វលា, លោកជាសត្វតិរច្ឆាន, លោកជាសត្វនរក (សត្វកើតក្នុងស្ថានគ្មានសេចក្ដីចំរើន) លោកគ្មានគតិល្អទេ លោកមានតែគតិអាក្រក់ម្យ៉ាង, ជេរដោយយ-អក្ខរៈក្ដី ដោយភ-អក្ខរៈក្ដី ដោយនិមិត្តបុរសនិងស្ត្រីក្ដី ជេរទាំងនេះហៅថាជេរយ៉ាងថោកទាប ។ ដែលហៅថា ជេរយ៉ាងខ្ពង់ខ្ពស់គឺជេរថា លោកជាបណ្ឌិត, លោកឆ្លៀវឆ្លាស, លោកជាអ្នកប្រាជ្ញ លោកជាពហុស្សូត, លោកជាធម្មកថិក, លោកគ្មានគតិអាក្រក់ទេ, លោកមានតែគតិល្អម្យ៉ាង ជេរទាំងនេះ ហៅថា ជេរខ្ពង់ខ្ពស់ ។ សាមណេរជេរភិក្ខុដោយពាក្យជេរក្នុង ២ យ៉ាងនេះណាមួយ ត្រូវទុក្កដ ។

៥៧- បុ. សាមណេរញុំាងភិក្ខុទាំងឡាយ ឲ្យបែកបាក់ភិក្ខុទាំងឡាយ; ចូរអធិប្បាយមកមើលបានសេចក្ដីថាម៉េច ?

៥៧– វិ. បានសេចក្ដីថា: ចេតនារបស់សាមណេរដែលមានចិត្តសៅហ្មងដោយលោភ ឬដោយទោសអាចញុំាងកាយបយោគ ឬ វចីបយោគ ដើម្បីនឹងញុំាងភិក្ខុដទៃឲ្យបែកបាក់គ្នា ឬដើម្បីនឹងបំបែកភិក្ខុម្ខាងយកមកធ្វើជាទីស្រឡាញ់របស់ខ្លួនឲ្យកើតឡើង ឬថា សាមណេរដែលពោលនូវពាក្យញុះញង់ស៊កសៀតនាំចុះនាំឡើង ធ្វើឲ្យភិក្ខុស្អប់ក្នាញ់គ្នាលែងរាប់អានគ្នាទៅវិញទៅមក យ៉ាងនេះហៅថាសាមណេរញុំាងភិក្ខុទាំងឡាយឲ្យបែកបាក់ភិក្ខុទាំងឡាយ ។

៥៨– បុ. ការញុះញង់ដែលនឹងកើតឡើងតើដោយអាការប៉ុន្មានយ៉ាង ?

៥៨– វិ. ការញុះញង់កើតដោយអាការ ២ យ៉ាងគឺ បិយកម្យស្ស ប៉ិងដើម្បីឲ្យគេស្រឡាញ់ខ្លួន ១, ភេទាធិប្បាយស្ស ប៉ិងដើម្បីបំបែក ១ ។

ទណ្ឌកម្មវគ្គទី ៤ ចប់

## នាសនង្គវគ្គទី ៥

៥៩– បុ. អង្គនៃសិក្ខាបទទាំងពួងមានមកសម្រាប់អ្វី ?

៥៩– វិ. អង្គនៃសិក្ខាបទទាំងពួងនោះមានមកសម្រាប់វិនិច្ឆ័យ

កាត់ទោសកូនសិក្ខាបទទាំងនោះ ដើម្បីនឹងឲ្យដឹងថា ៖ គួរមានទោស ឬគ្មានទោស ; បើមានទោសតើទោសនោះគួរដល់ទណ្ឌកម្មឬនាសនង្គ ។

៦០– ប្រ. សាមណេរទះមូសស្លាប់ត្រូវទោសអ្វី ? ព្រោះហេតុអ្វី ?

៦០– វិ. ត្រូវនាសនង្គ, ព្រោះចិត្តក្លែងសម្លាប់ ។

៦១– ប្រ. សាមណេរធ្វើពេទ្យ មើលជម្ងឺគេហើយដាក់ថ្នាំទៅខុស មនុស្សឈឺនោះក៏ស្លាប់ទៅ សាមណេរនោះត្រូវនាសនង្គឬទេ ?

៦១– វិ. សាមណេរនោះមិនត្រូវនាសនង្គទេ ព្រោះខ្វះអង្គមួយគឺ វធកចិត្តំ ; ត្រូវតែត្រឹមទណ្ឌកម្មព្រោះខ្លួនធ្វើពេទ្យ ។

៦២– ប្រ. សាមណេរឃើញសម្រាមមើលមិនច្បាស់ សំគាល់ថាសង្កើចមានចិត្តចង់ញោចសង្កើច ហើយក៏លូកដៃទៅញោចសង្កើចនោះទាល់តែបែកទៅ ទើបដឹងច្បាស់ថាជាសម្រាម ; បើយ៉ាងហ្នឹងតើសាមណេរត្រូវនាសនង្គឬទេ ? បើជាត្រូវក៏ហើយទៅ, បើជាមិនត្រូវទេតើនៅខ្វះអង្គណាទៀត ?

៦២–វិ. សាមណេរនោះនឹងកាត់ឲ្យត្រូវនាសនង្គទៅពុំបានឡើយ ព្រោះខ្វះអង្គទី ១ នៃបាណាតិបាតត្រង់ថា បាណោ សត្វមានជីវិត ។

៦៣–ប្រ. សាមណេរឃើញសង្កើចមិនច្បាស់ នឹកស្មានថាជាសម្រាមមានចិត្តចង់ទះលេង លូកដៃទៅទះសង្កើចនោះស្លាប់ទៅ បើ •

យ៉ាងនេះវិញតើសាមណេរនោះត្រូវនាសនង្គឬទេ៖ បើថាត្រូវក៏ហើយទៅ បើថាមិនត្រូវទេ តើនៅខ្វះអង្គត្រង់ណា ?

៦៣–វិ. សាមណេរនោះមិនត្រូវនាសនង្គឡើយ ព្រោះនៅខ្វះអង្គទី ២ នៃបាណាតិបាតថា បាណសញ្ញិតា សេចក្តីដឹងថាសត្វមានជីវិត៖

៦៤– បុ. សាមណេរឃើញមាន់ ១ ឈរនៅក្បែរខ្លួនមានចិត្តចង់សម្លាប់វា តែមិនទាន់បានធ្វើអ្វីវាផង វាក៏ស្លាប់ទៅក្នុងខណៈ ១ នៅពេលនោះដោយហេតុឯទៀត, ហើយសាមណេរនោះ ក៏រើសយកសាច់មាន់នោះទៅស្ងោរឆាន់ទៅ យ៉ាងនេះតើត្រូវនាសនង្គឬទេ? បើថាត្រូវក៏ហើយទៅ បើថាមិនត្រូវតើខ្វះអង្គត្រង់ណា ?

៦៤– វិ. សាមណេរនោះមិនត្រូវនាសនង្គទេ ព្រោះគ្រាន់តែគិតមិនទាន់បានព្យាយាមធ្វើវានៅឡើយ, បើគិតពីអង្គវិញក៏នៅខ្វះអង្គទី ៤ ទី ៥ នៃបាណាតិបាត ត្រង់ថា ឧបក្កមោ ព្យាយាមនឹងសម្លាប់ តេន មរណំ សត្វស្លាប់ដោយព្យាយាមនោះ ។

៦៥– បុ. សាមណេរឃើញក្អែក ១ ទំនៅលើចុងឬស្សីមិនប៉ងនឹងសម្លាប់វាទេ តែពេសដៃចាប់ដុំដីចោលលេង ក៏ត្រូវក្អែកនោះស្លាប់ទៅ, សាមណេរនោះត្រូវនាសនង្គឬទេ? បើមិនត្រូវតើនៅខ្វះអង្គត្រង់ណា ?

៦៥– វិ. សាមណេរនោះមិនត្រូវនាសនង្គទេ, ព្រោះខ្វះអង្គទី ៣ នៃបាណាតិបាត ត្រង់ថា វធកចិត្តំ គិតនឹងសម្លាប់, ប៉ុន្តែមិន

រួចផុតពីទណ្ឌកម្ម ត្រង់ ឆកាយប្បបាលកំ ទី ១៥ នៃសារូប ។

៦៦– ប្រ. សាមណេរវាយឆ្កែ ១ សន្ទប់, តែមិនស្លាប់ លុះរំលង ៣ ថ្ងៃទៅទើបឆ្កែនោះស្លាប់ ព្រោះខ្លួនវាយវានោះ ត្រូវនាសនង្គឬទេ?

៦៦– វិ. សាមណេរនោះត្រូវនាសនង្គពេញទី, ព្រោះឆ្កែនោះស្លាប់ដោយសារព្យាយាមរបស់ខ្លួន ។

៦៧– ប្រ. សាមណេរឃើញគេមកបាញ់សត្វក្នុងវត្ត ក៏នាំគេដើរបាញ់ គេក៏បាញ់សត្វសម្លាប់បាន ហើយគេយកទៅ, តើសាមណេរអ្នកនាំគេដើរបាញ់នោះត្រូវនាសនង្គឬទេ?

៦៧– វិ. សាមណេរនាំគេដើរបាញ់សត្វក្នុងវត្តនោះត្រូវនាសនង្គពេញទី គ្មានខ្វះអង្គត្រង់ណាឡើយ ។

៦៨– ប្រ. សាមណេរដុតភ្លើងឆៃព្រៃឆេះសត្វស្លាប់ ត្រូវទោសអ្វី?

៦៨– វិ. សាមណេរនោះត្រូវទណ្ឌកម្ម, នេះកាត់តាមច្បាប់ក្រិដ្ឋ ។

៦៩– ប្រ. សាមណេរបោលដុំក្រួស, ដុំថ្ម, ដុំដីលេង មិនប៉ងទីងសម្លាប់ទេ ប៉ុន្តែក្រួស, ថ្ម, ដុំដីដែលបោលទៅនោះហួសទៅត្រូវសត្វគីង្គក់ ១ ស្លាប់ទៅ តើត្រូវនាសនង្គឬទេ? បើមិនត្រូវតើខ្វះអង្គត្រង់ណា?

៦៩– វិ. សាមណេរនោះ មិនត្រូវនាសនង្គទេ, ពីព្រោះខ្វះ,

អង្គទី ៣ គឺ វធកចិត្តំ គិតនឹងសម្លាប់ ; ពិតជាសត្វនោះស្លាប់ តែមិនមានចិត្តគិតនឹងសម្លាប់ ។

៧០– ប្រ. ចោរលួចយកទ្រព្យសាមណេរទៅផុតឧបចារវត្ត ហើយសាមណេរទៅលួចយកមកវិញត្រូវទោសអ្វី

៧០– វិ. ត្រូវនាសនង្គ ។

៧១– ប្រ. សាមណេរឃើញឆ្នាំងគេ ១ គេទុកលើខ្ទមគេតែស្មានថាជាគេចោល ហើយកាន់យកទៅ ត្រូវនាសនង្គឬទេ? បើត្រូវក៏ហើយទៅ, បើមិនត្រូវទេ ខ្វះអង្គណាខ្លះ?

៧១– វិ. សាមណេរនោះ មិនត្រូវនាសនង្គទេ ព្រោះខ្វះអង្គទី ២ នឹងទី ៣ នៃអទិន្នាទានថា បរបរិគ្គហិតសញ្ញិតា នឹង ថេយ្យចិត្តំ ។

៧២– ប្រ. សាមណេរឃើញផ្លែតាសក់ ក្នុងចំការដែលម្ចាស់គេបោះបង់ចោលហើយ តែសាមណេរសំគាល់ថាម្ចាស់នៅថែរក្សាទុកមានចិត្តចង់លួច ហើយក៏បេះផ្លែតាសក់៥រៀបស្ពាយរត់មកត្រូវនាសនង្គឬទេ?

៧២– វិ. សាមណេរនោះមិនត្រូវនាសនង្គទេ ព្រោះខ្វះអង្គទី ១ នៃអទិន្នាទានថា បរបរិគ្គហិតំ ទ្រព្យដែលម្ចាស់គេហួងហែងរក្សា, ឯផ្លែតាសក់នោះឥតមានម្ចាស់ថែរក្សាទេ គេបោះបង់ចោលហើយ ។

៧៣– ប្រ. សាមណេរត្រូវទោសអទិន្នាទានយ៉ាងណា ? មានកំណត់ថ្លៃដែរឬមិនមានទេ? ចូរអធិប្បាយ ។

៧៣ – វិ. សាមណេរត្រូវទោសអទិន្នាទានផងមានកំណត់ថ្លៃ ដោយហោចទៅសូម្បីតែម្ជុលនឹងបោសទៀនទៅ ក៏ត្រូវនាសនង្គដែរ ។

៧៤ – ប្រ. សាមណេរយកច្រឡំចីពរនឹងសាមណេរគ្រូ ១ ក៏យកចីពរទៅ, សាមណេរយកក៏ចោទប្រកាន់សាមណេរគ្រូនោះ ថា លួចចីពររបស់ខ្លួន, បើយ៉ាងហ្នឹងតើយើងត្រូវកាត់ទោសយ៉ាងណា ? សាមណេរគ្រូត្រូវនាសនង្គ ឬទេ ។

៧៤ – វិ. សាមណេរគ្រូកាត់មិនឲ្យត្រូវនាសនង្គ ព្រោះខ្វះអង្គទី ៣ នៃអទិន្នាទានថា ថេយ្យចិត្តំ គិតនឹងលួចឬនឹងបន្លំយករបស់គេ ។

៧៥ – ប្រ. សាមណេរលួចលេងបៀដោយចិត្តសប្បាយត្រូវទោសអ្វី? ព្រោះហេតុអ្វី ?

៧៥ – វិ. ត្រូវនាសនង្គ ព្រោះលួចក្បត់ច្បាប់រាជការផែនដី ។

៧៦ – ប្រ. សាមណេរឆ្កួតម្នាក់, បានទៅលួចប្រាក់គេ ១ រៀល តើត្រូវនាសនង្គឬទេ ? ព្រោះហេតុអ្វី

៧៦ – វិ. សាមណេរដែលលួចប្រាក់គេនោះ មិនត្រូវនាសនង្គទេ ព្រោះគាត់ជាមនុស្សឆ្កួត, គ្មានស្មារតីមិនអាចនឹងដឹងខុសត្រូវបាន ។

៧៧ – ប្រ. ទ្រព្យគេកប់ទុក សាមណេរលួចយកផុតមកពីមាត់រណ្តៅ ម្ចាស់គេដេញទាន់ក៏ធ្លាក់ទៅក្នុងរណ្តៅវិញ ត្រូវទោសអ្វី ?

៧៧ – វិ. ត្រូវនាសនង្គ ។

៧៨–ប្រ. សាមណេរឃើញសំពត់គេជ្រុះ ហើយគេភ្លេចចោល ក៏បង្សុកូលយកមក តើត្រូវនាសនង្គឬទេ? បើត្រូវក៏ស្រាប់ទៅ បើមិនត្រូវទេ ចូរអធិប្បាយហេតុដែលមិនត្រូវមកមើល ។

៧៨– វិ. សាមណេរបង្សុកូលយករបស់គេភ្លេចនោះមិនត្រូវនាសនង្គទេ; ហេតុដែលសាមណេរកាន់យកហើយមិនត្រូវទោសនោះមាន ៨ យ៉ាងគឺ: កាន់យកដោយសំគាល់ថាជារបស់ខ្លួន១, កាន់យកដោយស្និទ្ធស្នាលនឹងគ្នា១, កាន់យកជារបស់ខ្ចីគ្នា១, កាន់យករបស់ដែលពួកប្រេតហួងហែងរក្សា១, កាន់យករបស់ដែលសត្វតិរច្ឆានហួងហែងរក្សា១, កាន់យកដោយសំគាល់ថាជារបស់បង្សុកូល១, សាមណេរឆ្កួត១, សាមណេរដើមបញ្ញត្តិ១, ទាំងអស់នេះមិនត្រូវនាសនង្គឡើយ ។

៧៩–ប្រ. ធម៌ដូចម្តេចដែលហៅថា មេថុន?

៧៩–វិ. ធម៌ដែលហៅថាមេថុននោះ គឺធម៌ដែលជារបស់អសប្បុរស ធម៌របស់អ្នកស្រុក ធម៌របស់មនុស្សថោកទាប ឬអំពើអាក្រក់ មានកិច្ចដោយទឹកជាទីបំផុត ជាអំពើដែលជន២នាក់ តែងប្រព្រឹត្តក្នុងទីកំបាំង នេះឯងហៅថាមេថុនធម៌ ។

៨០–ប្រ. យ៉ាងម៉េចហៅថា សាមណេរសេព?

៨០– វិ. សាមណេរឯណា ឲ្យនិមិត្តខ្លួនចូលទៅដោយនិមិត្តគេ, ឲ្យអង្គកំណើត ( ខ្លួន ) ចូលទៅដោយអង្គកំណើតគេ ដោយហោចទៅ

សូម្បីតែអស់ទីត្រឹមតែ ១ គ្រាប់ល្ង សាមណេរនោះហៅថា សេព ។

៨១– ប្រ. ស្រី, ឧភតោព្យញ្ជនកៈ និងបណ្ឌកៈមានប៉ុន្មានពួកគឺអ្វីខ្លះ? ចូររាប់ហើយប្រែខ្លះផង ។

៨១– វិ. ស្រីមាន ៣ ពួកគឺ ស្រីមនុស្ស ១, ស្រីអមនុស្ស ១, សត្វតិរច្ឆានញី ១ ។ ឧភតោព្យញ្ជនកៈគឺជនដែលមានភេទពីរមាន ៣ ពួកគឺ មនុស្សមានភេទពីរ ១, អមនុស្សមានភេទពីរ ១, តិរច្ឆានមានភេទពីរ ១ ។ បណ្ឌកៈគឺជនខ្ទើយមាន ៣ ពួកគឺ មនុស្សខ្ទើយ ១, អមនុស្សខ្ទើយ ១, តិរច្ឆានខ្ទើយ ១ ។ ប្រុសមាន ៣ ពួក គឺ មនុស្សប្រុស ១, អមនុស្សប្រុស ១, តិរច្ឆានឈ្មោល ១ ។

៨២– ប្រ. ទ្វារមគ្គដែលសេពទៅត្រូវទោសមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូររាប់ឲ្យគ្រប់មកមើល ។

៨២– វិ. ទ្វារមគ្គដែលសេពទៅត្រូវទោសមាន ៣០ , ទ្វារមគ្គទាំង ៣០ នោះចែកជាទ្វារមនុស្ស ១០, អមនុស្ស ១០, តិរច្ឆាន ១០ ។ ទ្វារមគ្គមនុស្សនោះគឺ ស្រីមានទ្វារ ៣ គឺ វច្ចមគ្គ ទ្វារធំ ១, បស្សាវមគ្គ ទ្វារតូច ១, មុខមគ្គ ទ្វារមាត់ ១; ប្រុសមានទ្វារ ២ គឺ វច្ចមគ្គ ១, មុខមគ្គ ១; ឧភតោព្យញ្ជនកៈ មានទ្វារ ៣ ដូចមនុស្សស្រី, បណ្ឌកៈមានទ្វារ ២ ដូចមនុស្សប្រុស, ផ្សំគ្នាត្រូវជាទ្វារមគ្គរបស់មនុស្ស ១០ ។ ឯទ្វារមគ្គរបស់អមនុស្សនោះក៏ចាត់ជាស្រីមានទ្វារ៣, ប្រុស

មានទ្វារ ២, ឧភតោព្យញ្ជនកៈមានទ្វារ ៣, បណ្ឌកៈ មានទ្វារ ២; ផ្សំគ្នាត្រូវជាទ្វាររបស់មនុស្ស ១០ ។ ទ្វារសត្វតិរច្ឆាននោះក៏ចាត់ជា ញីមានទ្វារ ៣, ឈ្មោលមានទ្វារ ២, ឧភតោព្យញ្ជនកៈមានទ្វារ ៣, សត្វបណ្ឌកៈមានទ្វារ ២ ផ្សំគ្នាត្រូវជាទ្វាររបស់សត្វតិរច្ឆាន ១០ ។ ទ្វារមគ្គរបស់មនុស្ស ១០, អមនុស្ស ១០, សត្វតិរច្ឆាន ១០, រួមត្រូវជា ៣០ ។

៨៣– ប្ុ. ចូរអធិប្បាយពាក្យដែលថា “ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា” នោះមកមើល មានកំណត់ចុះដែរឬយ៉ាងណា ?

៨៣– វិ. ពាក្យដែលថាញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នានោះគឺ បញ្ចូលអង្គជាតរបស់ខ្លួនឲ្យចូលទៅក្នុងទ្វារកំណើតរបស់អ្នកដទៃ ឬឲ្យចូលទៅក្នុងទ្វារមគ្គទាំង ៣០ ទ្វារណាមួយ ចំនួនប្រមាណប៉ុនចុងសក់ ឬប៉ុនគ្រាប់ល្ង ក្នុងកន្លែងទ្វារដែលខ្យល់បក់មកមិនត្រូវមិនប៉ះពាល់ដល់នោះ យ៉ាងនេះឯងហៅថា “ញ៉ាំងមគ្គនឹងមគ្គឲ្យដល់គ្នា” ។

៨៤– ប្ុ. សាមណេរកំពុងដេកលក់ មានអ្នកដទៃមកលបសេពមេថុនធម្ម, ដោយមិនដឹងខ្លួន ស្រាប់តែភ្ញាក់ឡើងឃើញប្រឡាក់ស្បង់ តើត្រូវនាសនង្គឬទេ ?

៨៤– វិ. មិនត្រូវនាសនង្គទេ ព្រោះមិនដឹងខ្លួន ។

៨៥– ប្ុ. អង្គជាតគួរដល់កម្ម (ប្រដាប់រឹង) ដោយអាការប៉ុន្មាន យ៉ាង?

៨៥– វិ. អង្គជាតគួរដល់កម្មដោយអាការ ៥ យ៉ាង គឺដោយតម្រេក១, ដោយអាចម៍១, ដោយទឹកមូត្រ១, ដោយខ្យល់១, ដោយសត្វកន្ទួបអាលពេល ១ ៕

៨៦– ប្រ. សាមណេរព្រមឲ្យអ្នកដទៃសេពមេថុនធម្មនឹងទ្វារមគ្គរបស់ខ្លួន ហើយត្រេកអរត្រូវនាសនង្គឬទេ? បើមិនត្រេកអរព្រមដោយសារគេបង្ខំ ត្រូវនាសនង្គឬទេ ?

៨៦– វិ. បើព្រមឲ្យអ្នកដទៃសេពដោយគេជួលឲ្យគ្រឿ ឬដោយគេវៃចង់ដោយពាក្យប្រកបដោយកាមផ្សេងៗ ឬក៏ដោយអផ្សុកហើយត្រេកអរចង់ឲ្យគេសេពត្រូវនាសនង្គ, បើមិនត្រេកអរទេគេមកកំហែងបង្ខំ, មានទះតប់ជន្ទូកាំបិតជាដើម ហើយក៏បណ្តោយឲ្យសេពទៅ ដោយសេចក្តីខ្លាចដោយមិនត្រេកអរ មិនត្រូវនាសនង្គឡើយ ៕

៨៧– ប្រ. ការសេពមេថុនធម្មសុទ្ធតែមានទោសគ្រប់កន្លែងទាំងអស់ឬ ឬក៏សេពយ៉ាងម៉េចមិនត្រូវទោសដែរ? បើសុទ្ធតែត្រូវទោសក៏ហើយទៅ បើមានមិនត្រូវទោសដែរនោះចូររាប់មកមើលមានប៉ុន្មានយ៉ាង?

៨៧– វិ. ការសេពនោះមិនមែនសុទ្ធតែមានទោសទាំងអស់ទេ, មានមិនត្រូវខ្លះដែរ; សាមណេរ៥ពួក គឺសាមណេរមិនដឹងខ្លួន១, សាមណេរឆ្កួត១, សាមណេរមានចិត្តរវើរវាយ១, សាមណេរដែលវេទនាគ្របសង្កត់១, សាមណេរដើមបញ្ញត្តិ១, សាមណេរទាំងនេះមិនត្រូវនាសនង្គឡើយ ៕

៨៨–ប្រ. ដូចម្ដេចដែលហៅថា ពោលនូវពាក្យកុហក ?

៨៨–ឆ្លើ. ដែលហៅថាពោលនូវពាក្យកុហកនោះ បានដល់វាចា, សំដី, គន្លងពាក្យ, វចីភេទ, វិញ្ញត្តិប្រព្រឹត្តទៅក្នុងវាចារបស់បុគ្គល ដែលធ្វើគំនិតនឹងពោលឲ្យខុសជាប្រធាន នឹងវោហារមិនមែនរបស់ព្រះអរិយៈ ៨ យ៉ាងគឺការដែលមិនឃើញនិយាយថាអញឃើញ១, មិនឮនិយាយថាអញឮ១, មិនបានពាល់ត្រូវនិយាយថាអញពាល់ត្រូវ១, មិនដឹងច្បាស់និយាយថាអញដឹងច្បាស់១, ឃើញនិយាយថាអញមិនឃើញ១, ឮនិយាយថាអញមិនឮ១, បានពាល់ត្រូវនិយាយថាអញមិនបានពាល់ត្រូវ១, ដឹងច្បាស់និយាយថាអញមិនដឹងច្បាស់១ ។

៨៩–ប្រ. មានពាក្យ១ម៉ាត់គេកុហកគ្នាមក, សាមណេរនឹកស្មានថាជាពាក្យពិត ហើយក៏នាំរឿងនោះទៅនិយាយតទៅទៀត, បើយ៉ាងហ្នឹងតើត្រូវនាសនង្គឬទេ?

៨៩–ឆ្លើ. មិនត្រូវនាសនង្គទេ ព្រោះស្មានថាជាគេនិយាយពិតហើយ, ហើយខ្វះអង្គទី ២ នៃមុសាវាទផង ថា "វិសំវាទនចិត្តំ គិតនឹងនិយាយឲ្យខុស"; ប្រសិនជាបានដឹងថាពាក្យនោះជាសំដីមិនមែនប្រាកដ ហើយនៅតែនិយាយទៅទើបត្រូវនាសនង្គ ។

៩០– ប្រ: សាមណេរឈ្លោះនឹងគេ ហើយជេរគេដោយរឿងមិនពិត; ដូចគេមិនលួចក្របីគេទេ ខ្ញុំជេរគេថា "អាចោរលួចក្របី

គេ " ដូច្នេះត្រូវនាសន្ទគ្គុទេ ?

៩០– វិ. មិនត្រូវនាសន្ទគ្គទេ ត្រូវតែត្រឹមទណ្ឌកម្មដោយអំណាចផ្ទុស្រាវទប៉ុណ្ណោះ ។

៩១– ប្រ. ចេតនារបស់អ្នកនិយាយកុហក នឹងចេតនារបស់អ្នកដែលដេរគេដោយរឿងមិនពិត ; ចេតនាទាំងពីរនេះតើខុសគ្នាយ៉ាងណា ? ចូរអធិប្បាយ ។

៩១– វិ. ចេតនារបស់អ្នកនិយាយកុហក នឹងចេតនារបស់អ្នកដែលដេរគេដោយរឿងមិនពិតនោះ ខុសគ្នាយ៉ាងនេះ; អ្នកនិយាយកុហកនោះ ចិត្តចាប់ឈោងយករបស់ពិតមែនមកនិយាយប្រាប់គេថាមិនពិតថាមិនមែន, ទាញយករបស់ណាដែលមិនពិតមិនមែនមកថាជារបស់ពិតមែនទៅវិញ ហើយថែមបញ្ជាក់សេចក្តីនោះ ឲ្យទាល់តែអ្នកស្តាប់ចូលចិត្តជឿតាមខ្លួន ; និយាយយ៉ាងនេះឈ្មោះថាចេតនាកុហក ។ ចំណែកខាងចេតនាដែលដេរគេនោះ មិនបានឈោងយករបស់ដែលពិតនឹងមិនពិតនោះមកនិយាយទេ គឺដេរចេញទៅដោយអំណាចកំហឹងខ្លាំង ឬដោយ គ្មានស្មារតីនឹកឮកសព្វគ្រប់, ដោយមិនបានប្រុងស្មារតី, ដោយមិនបានជាគិតវែងឆ្ងាយហើយក៏ដេរចេញទៅយ៉ាងនេះហៅថាចេតនាដេរគេ ។

៩២– ប្រ. បើគេមកនិយាយខ្វះ ឬនិយាយសូមសៀវភៅរបស់សាមណេរ, សាមណេរនោះមានដៃវែតប្រាប់គេថាគ្មានទេដោយចិត្ត

កំណាញ់មិនចង់ឲ្យ បើយ៉ាងហ្នឹងតើត្រូវនាសនង្គឬទេ?

៩២– វិ. ត្រង់នេះគាត់ឲ្យត្រូវនាសនង្គតែម្តងមិនបាន, បើយ៉ាងហ្នឹងត្រូវសួរបញ្ជាក់រកត្រង់ពាក្យថា “ គ្មានទេ ” នោះ ; គ្មានសៀវភៅមែនឬមានដែរ, បើសាមណេរនោះឆ្លើយថាមានដែរ តែជាសៀវភៅសម្រាប់ខ្លួនតែម្នាក់ឯង, ឯសៀវភៅដែលទុកសម្រាប់ឲ្យខ្ចីឬឲ្យគេសុំនោះគ្មានទេ បើចេតនាគិតយ៉ាងនេះឬសំដីថា យ៉ាងនេះមិនត្រូវនាសនង្គឡើយ ៗ

៩៣– ប្រ. សាមណេរដូចម្តេចដែលពោលពាក្យកុហកហើយមិនត្រូវនាសនង្គ? ចូររាប់មកមើល ៗ

៩៣– វិ. សាមណេរនិយាយកុហក ហើយមិនត្រូវនាសនង្គនោះមាន ៤ ពួកគឺ សាមណេរដែលពោលដោយញាប់មាត់ គឺពោលដោយរហ័ស ១, សាមណេរពោលដោយភ្លាត់មាត់ គឺសាមណេរគិតថាអញនឹងពោលពាក្យដទៃ ហើយត្រឡប់ពោលពាក្យដទៃក្រៅពីគិតនោះវិញ ១, សាមណេរឆ្កួត ១, សាមណេរដើមបញ្ញត្តិ ១ ៗ.

៩៤– ប្រ. សុរានឹងមេរ័យនោះដូចគ្នាឬផ្សេងគ្នា? ចូរអធិប្បាយ

៩៤– វិ. ផ្សេងគ្នា, សុរាគេធ្វើដោយវត្ថុមានម្សៅជាដើម ឯមេរ័យនោះគឺគេយកវត្ថុមានផ្កាឈើជាដើមមកត្រាំធ្វើឲ្យជូរជាដើម ៗ

៩៥– ប្រ. សុរាមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? មេរ័យមានប៉ុន្មានយ៉ាង? ដូចម្តេចខ្លះ? ចូររាប់នឹងអធិប្បាយមកមើល ៗ

៩៥– វិ. សុរាមាន ៥ យ៉ាងគឺ បិដ្ឋសុរា សុរាធ្វើដោយម្សៅ ១, បូវសុរា សុរាធ្វើដោយនំ ១, ឱទនសុរា សុរាធ្វើដោយបាយ ១, កិណ្ណបក្ខិត្តា សុរាដែលគេដាក់ពូជសុរា ១, សម្ភារសំយុត្តា សុរាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗមានគ្រាប់ម្រេចនិងគ្រាប់ស្ពៃជាដើម ១ ។ ឯមេរ័យក៏មាន ៥ យ៉ាងគឺ បុប្ផាសវោ ទឹកស្រាដែលគេធ្វើដោយផ្កាឈើ ១, ផលាសវោ ទឹកស្រាដែលគេធ្វើដោយផ្លែឈើ ១, មធ្វាសវោ ទឹកស្រាដែលគេធ្វើដោយផ្លែចន្ទន៍ឬគេធ្វើដោយទឹកឃ្មុំ ១, គុឡាសវោ ទឹកស្រាដែលគេធ្វើដោយទឹកអំពៅ ១, សម្ភារសំយុត្តោ ទឹកស្រាដែលគេប្រកបព្រមដោយគ្រឿងផ្សំផ្សេងៗ ( មានផ្លែសម៉និងផ្លែកន្ទួតព្រៃជាដើម ) ១ ។

៩៦–ប្រ. ត្រង់ពាក្យថា "ផឹក" នោះមានកំណត់ថា ផឹកប៉ុន្មានទើបត្រូវនាសនង្គ ?

៩៦--វិ. ត្រង់ពាក្យថា "ផឹក" នោះមិនមានកំណត់ឡើយ ដោយហោចទៅសូម្បីតែសាមណេរផឹកប៉ុនចុងស្បូវក៏ត្រូវនាសនង្គដែរ ឲ្យតែឈ្មោះថាផឹក ហើយឥតមានរួចទោសទេ ។

៩៧–ប្រ. ទឹកស្រវឹងសាមណេរសំគាល់ថាមិនមែនទឹកស្រវឹង ហើយផឹកទៅត្រូវនាសនង្គឬទេ , ព្រោះហេតុអ្វី ? បើភិក្ខុវិញត្រូវអាបត្តិឬទេ ? ព្រោះហេតុដូចម្តេច ? សុរាបស់ភិក្ខុនិងសាមណេរផ្សេងគ្នាយ៉ាងណា ?

៩៧–វិ· ទឹកស្រវឹងសាមណេរសំគាល់ថាមិនមែនទឹកស្រវឹងហើយ ផឹកមិនត្រូវនាសនង្គទេ, ព្រោះសិក្ខាបទនុ៎ះជាសចិត្តកៈ, ដែលផឹកនេះគឺផឹកដោយសារច្រឡំ; បើភិក្ខុវិញត្រូវអាបត្តិបាចិត្តិយ ព្រោះហេតុសិក្ខាបទនោះ បើភិក្ខុត្រឡប់ទៅជាអចិត្តកៈ ទោះមានចិត្តក្នុងផឹកក្តី មិនមានក្តី សុទ្ធតែត្រូវទោសទាំងអស់ សុរាបស់ភិក្ខុជាអចិត្តកៈ, សាមណេរជាសចិត្តកៈ ฯ

៩៨–ប្រ· សាមណេរជក់អាភៀន, ជក់កញ្ឆា ត្រូវនាសនង្គឬទេ? ព្រោះហេតុអ្វី?

៩៨–វិ. សាមណេរជក់អាភៀនក្តី ជក់កញ្ឆាក្តី ជក់គ្រឿងឯទៀតក្រៅពីនេះក្តី ឲ្យតែជាគ្រឿងស្រវឹងហើយ សុទ្ធតែត្រូវនាសនង្គទាំងអស់, ព្រោះរបស់ទាំងនោះក៏រាប់ចូលក្នុងគ្រឿងស្រវឹងដែរ ฯ

៩៩–ប្រ· សាមណេរយកទឹកទន្ទេមកក្នុងធ្វើជាសុរាបបួលគ្នាផឹកលេងកើតសេចក្តីរីករាយសប្បាយចិត្ត តើត្រូវនាសនង្គឬទេ?

៩៩–វិ· មិនត្រូវនាសនង្គទេ ព្រោះមិនមែនជាជាតិទឹកស្រវឹង ฯ

១០០–ប្រ. សាមណេរមានជម្ងឺ ពេទ្យលាយថ្នាំនឹងសុរាឲ្យផឹក សាមណេរក៏ផឹកទៅត្រូវនាសនង្គឬទេ?

១០០–វិ. បើសាមណេរផឹកត្រូវនាសនង្គហើយ ព្រោះគ្មានអនុញ្ញាតឲ្យធ្វើថ្នាំបែបនោះ ฯ

១០១–ប្រ. សាមណេរកំពុងដេកលក់, ឥតមានដឹងខ្លួន មានអ្នកដទៃយកសុរាទៅចាក់បង្អុកក្នុងមាត់ សាមណេរនោះក៏លេបចូលផុតបំពង់កទៅ តើត្រូវនាសនង្គឬទេ? បើត្រូវក៏ហើយទៅ បើមិនត្រូវទេព្រោះហេតុអ្វី? បើភិក្ខុវិញយ៉ាងម៉េច?

១០១–វិ. សាមណេរដែលគេយកសុរាទៅបង្អុកកំពុងដេកលក់ នោះមិនត្រូវនាសនង្គទេ ព្រោះសិក្ខាបទសុរានោះជាសចិត្តកៈ ធ្វើដោយចិត្តក្លែងទើបត្រូវទោស, បើឥតមានចិត្តក្លែងទេ មិនត្រូវទោសឡើយ ។ បើភិក្ខុវិញត្រូវអាបត្តិបាចិត្តិយ ព្រោះសុរារបស់ភិក្ខុជាអចិត្តកៈ ទោះមានចិត្តក្លែងក្ដី មិនក្លែងក្ដី ឲ្យតែលេបចូលផុតបំពង់កទៅហើយ ចេះតែត្រូវទោសទាំងអស់ ។

១០២–ប្រ. សាមណេរបបួលគ្នា យកសុរាចំនួន ១ ភាគ, ទឹកទទេចំនួន ៧ ភាគ មកលាយនឹងសុរានោះទាល់តែបាត់ធុំក្លិនទៅ ហើយនាំគ្នាផឹកល្បងមើល, ត្រូវនាសនង្គឬទេ? ចូរអធិប្បាយ ។

១០២–វិ. ត្រូវនាសនង្គពេញទី ឥតមានរួច, ព្រោះព្រះបរមគ្រូជាម្ចាស់ មិនបានអនុញ្ញាត, កុំថាតែសុរា ១ ភាគទឹក ៧ ភាគនោះឡើយ, សូម្បីសុរា ១ ភាគលាយនឹងទឹក ១០០ ភាគក៏គង់ផឹកពុំបានដែរ ។

១០៣–ប្រ. ចុះសាមណេរផឹកទឹកដូចម្ដេចខ្លះ ដែលមិនត្រូវនាសនង្គ មានប៉ុន្មានយ៉ាង? គឺណាមួយៗ?

១០៣–វិ. សាមណេរផឹកទឹកដែលមិនត្រូវនាសន្គក្នុងសិក្ខាបទនេះ មាន៨យ៉ាងគឺ សាមណេរផឹកទឹកមិនស្រវឹងតែទឹកនោះមានពណ៌ដូចជាទឹកស្រវឹង មានក្លិនដូចជាទឹកស្រវឹង មានរសដូចជាទឹកស្រវឹង១, ទឹកស្រវឹងដែលគេចំអិនលាយនឹងសម្ល១, ទឹកស្រវឹងដែលគេចំអិនលាយនឹងសាច់១, ទឹកស្រវឹងដែលគេចំអិនលាយនឹងប្រេង ១, ទឹកអំពៅដែលគេត្រាំនឹងផ្លែកន្ទួតព្រៃ ១, សាមណេរផឹកទឹកអរិដ្ឋមិនស្រវឹង (ថ្នាំដែលគេធ្វើដោយរសនៃផ្លែឈើមានផ្លែកន្ទួតព្រៃជាដើម) ១, សាមណេរឆ្កួត ១, អ្នកដើមបញ្ញត្តិ១ ។

១០៤–បុ. ជេរនឹងតិះដៀលឬពោលទោសខាងណាធ្ងន់ជាង ?

១០៤–វិ. ជេរធ្ងន់ជាង, ឯតិះដៀលឬពោលទោសនោះបន្ទាប់បន្ថយមិនជាធ្ងន់ណាស់ណា ។

១០៥–បុ. សាមណេរតិះដៀលឬពោលទោស, ចំពោះព្រះពុទ្ធជាបរមគ្រូនោះតើតិះដៀលថាម៉េច ត្រូវទោសអ្វី ? ចូរនិយាយពាក្យនោះមកមើល សូមស្មាលាទោស !

១០៥–វិ. សូមស្មាលាទោស ! ពោលតិះដៀលឬពោលទោសចំពោះព្រះបរមគ្រូនោះដូចពាក្យថា: ព្រះពុទ្ធជាបុគ្គលឆ្មើងឆ្មៃមិនចេះសំពះ មិនចេះក្រោកទទួលពួកជនដែលចាស់ត្រាំត្រា ជាព្រឹទ្ធាចារ្យមានអាយុច្រើនជាង រស់នៅបានយូរនោះទេ; ព្រះពុទ្ធមិនមែនជាត្រាស់ដឹង

ដោយព្រះអង្គឯងពិតប្រាកដនោះទេ គង់តែនៅមានគេបេះលើសជាងព្រះអង្គទៅទៀត, ប្រសិនបើត្រាស់ដឹងសព្វគ្មានបន្ទោះមែន ដូចម្តេចក៏មិនឃើញមាននិយាយអំពីទឹកដីឲ្យពិតប្រាកដ; ព្រះពុទ្ធជាមនុស្សល្ងង់ដឹកនាំគេឯងឲ្យល្ងង់តាមព្រះពុទ្ធមានទៅបេះដឹងអ្វីប៉ុន្មាន មិនដល់នឹងអ្នកប្រាជ្ញគេសព្វថ្ងៃនេះផង ។ ប៉ុន្តែសម័យនោះមនុស្សល្ងង់ច្រើនជាងគោជិ ហើយឃើញអ្នកណាបេះដឹងបន្តិចបន្តួចក៏នាំគ្នាលើកសរសើរថា ជាព្រះពុទ្ធដឹងគ្មានបន្ទោះទៅៗ ឯអ្នកប្រាជ្ញសព្វថ្ងៃនេះបានពេញហៅថាបេះមែន, ព្រោះគេស្ទង់មើលទឹកដីដឹងថាចំនួនប៉ុណ្ណោះគីឡូប៉ុណ្ណោះយោជន៍បាន ដឹងថាទីនៃះមានប្រាក់មាស, មានប្រេងមានដែកជាដើម, សំដីនិយាយបន្តុះបង្អាប់ប៉ុណ្ណោះជាដើមហៅថាពោលតិះដៀលនូវព្រះពុទ្ធ សាមណេរត្រូវនាសនង្គ

១០៦ — ប្រ. សាមណេរពោលតិះដៀលនូវព្រះធម៌ ត្រូវទោសអ្វី? តិះដៀលដូចម្តេច? ចូរនិយាយមកមើល ។

១០៦— វិ. សាមណេរពោលតិះដៀលនូវព្រះធម៌ ត្រូវនាសនង្គ, ពាក្យតិះដៀលនោះថា : ធម៌សំដែងថា : អ្នកណាប្រព្រឹត្តល្អបានល្អ, អ្នកណាប្រព្រឹត្តអាក្រក់បានអាក្រក់ , ឯខ្លួនអញនេះជាអ្នកប្រព្រឹត្តល្អណាស់ ចុះហេតុអ្វីក៏មកប្រទះតែនឹងសេចក្តីទុក្ខអេះ ! មិនតែប៉ុណ្ណោះ កាលពីដើមអញមិនទាន់បួស មាតាបិតារបស់អញនៅជួបជុំគ្នាទាំងអស់, លុះអញមកបួសកាលណា មាតាបិតារបស់អញស្លាប់ព្រាត់ប្រាសគ្នាអស់;

ធម៌មិនមែនជាពាក្យប្រដៅខ្លួនល្អទេ ពិតជាពាក្យបោកប្រាស , អ្នកណាកាន់ធម៌នេះទាំងប៉ុន្មាន អ្នកនោះឈ្មោះថាបាញ់បញ្ឆោតគេ ; ឬពោលថាប្រទេសណាដែលកាន់ព្រះពុទ្ធសាសនាទាំងប៉ុន្មាន ប្រទេសនោះសុទ្ធតែខ្ញុំគេទាំងអស់ ; ពាក្យថាធម៌នោះសុទ្ធតែជាពាក្យបោកបញ្ឆោតរបស់ជាតិគ្រិស្គ , ពួកគ្រិស្គប្រសប់ខាងឯតែងច្បាប់បោកបញ្ឆោតឲ្យគេជឿណាស់, ឱ ! អ្នកណាហ្ន៎ ! សំដែងធម៌មកទាំងប៉ុន្មាន ឈ្មោះជាពន្យល់ប្រាប់ពាក្យកុហកមកទាំងអស់ ឥតមានពិតប្រាកដទេ, ធម៌ជាបំណះថោកទាប អ្នកណាបានរៀនហើយ អ្នកនោះនឹងឆ្កួតខូចខ្លួន ខូចទ្រព្យសម្បត្តិ , ពាក្យបន្តុះបង្អាប់បំណោះជាដើម ហៅថា ពោលតិះដៀលនូវព្រះធម៌ ។

១០៧– ប្រ. សាមណេរពោលតិះដៀលនូវព្រះសង្ឃនោះ តើតិះដៀលថាម៉េច ? ត្រូវទោសអ្វី ?

១០៧– វិ· សាមណេរពោលតិះដៀលនូវព្រះសង្ឃនោះថា សមណៈជាសក្យបុត្រគ្មានសេចក្ដីអៀនខ្មាស, ជាអ្នកទ្រុស្ដសីល, និយាយកុហក, មិនប្រព្រឹត្តនូវធម៌, មិនមានសេចក្ដីប្រព្រឹត្តស្មើតាមប្រក្រតី, មិនប្រព្រឹត្តនូវធម៌ដ៏ប្រសើរ, និយាយបោកប្រាសឆកុហក, ភាវៈនៃសាមណៈរបស់លោកទាំងនេះគ្មានទេ, ភាវៈនៃធម៌ដ៏ប្រសើររបស់លោកទាំងនេះគ្មានទេ, សាមញ្ញគុណរបស់លោកទាំងនេះវិនាសអស់ហើយ, ព្រហ្មញ្ញគុណរបស់

លោកទាំងនេះ វិនាសអស់ហើយ; ឬពោលថា ពួកលោកត្រើលទាំងនេះ សុទ្ធតែជាមេបោកមេបញ្ឆោត អ្នកណាមួយចូលទៅសេពគប់ហើយ អ្នកនោះគង់ហិនហោចទ្រព្យសម្បត្តិមិនខាន; អ្នកណាបេះទៅនិយាយជេញជោលឲ្យឈ្មោះលោកសង្ឃនោះបាន, បើពួកនោះបានស៊ីស្រាប់ស៊ីហើយដេករកនឹកៗបាយកល នឹងមកនិយាយបំបិតភ្នែកគេឯងគ្រប់គ្នា; ពួកលោកទាំងនេះសុទ្ធតែជាមេខ្ជិលទាំងអស់ ឥតមានធ្វើការងារអ្វីទេ គាំងតែបានស៊ីស្រាប់, បើសិនណាជាគិតធ្វើការងារអ្វីឡើង ក៏គាំងតែរៃអង្គាសផ្ញាក់យកឈាមគេទាំងរស់យកទៅធ្វើការនោះ, ហើយនិយាយបំបិតភ្នែកគ្នាថា បានផលយ៉ាងនេះៗ បានអានិសង្សយ៉ាងនុ៎ះៗ; លោកទាំងនោះសុទ្ធតែជាមេករ មេកុហក មេបោកប្រាស; អ្នកណាដែលយកបាយទឹកទៅឲ្យពួកនោះស៊ី ដូចជាគេយកទៅចាក់ចោលក្នុងទឹកទន្លេ បើទុកឲ្យកូនប្រពន្ធរាស៊ីវិញមានប្រយោជន៍ជាង; ពួកត្រើលទាំងនោះជាមេល្ងង់នាំឲ្យជាតិថោកទាបខ្ញុំក្ញុះគេ, ស្រុកដែលត្រឡប់ទៅជាខ្ញុំក្ញុះគេព្រោះតែមានមេបោកប្រាសច្រើន បើកុំមានមេបោកប្រាសប្រហែលជាមិនអីទេ; ពាក្យពោលប៉ុណ្ណោះជាដើម ហៅថាពោលតិះដៀលនូវព្រះសង្ឃ, ត្រូវទោសនាសនគ្គ ។

១០៨–ឫ. សាមណេរពោលតិះដៀលនូវព្រះសង្ឃដូចជាត្រូវនាសនគ្គហើយ; បើសាមណេរជេរប្រទេចព្រះសង្ឃវិញត្រូវទោសអ្វី ?

១០៨–វិ. ពោលតិះដៀលព្រះសង្ឃជាពាក្យស្រាលម្តេចក៏ត្រូវនាសនគ្គ, បំណាច់បើជេរប្រទេចជាពាក្យធ្ងន់ជាងនោះរឹតតែត្រូវនាសនគ្គណាស់ទៅហើយ, នេះដោយសារគ្មានទោសអ្វីធ្ងន់ជាងនេះទៅទៀត ប្រសិនបើមានទោសធ្ងន់ជាង មុខជានឹងត្រូវទោសនោះមិនខាន ។

១០៩ – បុ. ក្រែងភិក្ខុហ្នឹង ឬ ដែលហៅថាសង្ឃ? ឬអ្នកណាផ្សេងទៅទៀតទេ? មានប៉ុន្មានពួក?

១០៩ – វិ. អ្នកដែលបានឧបសម្បទាដោយញត្តិចតុត្ថកម្មវាចា ហើយហៅថាភិក្ខុក្នុងសម័យនេះ, ភិក្ខុ ១ រូបចង់ហៅថាភិក្ខុយ៉ាងហ្នឹងក៏បាន ហៅថាបុគ្គលឬជន ក៏កើត,ភិក្ខុត្រឹម ២ រូបឬ ៣ រូបហៅថាគណៈ, យ៉ាងតិចតាំងពីត្រឹម ៤ រូបឡើងទៅ រហូតទៅទល់នឹងប្រមាណមិនបាន ហៅថាសង្ឃ ; មានពីរពួកគឺភិក្ខុជាបុថុជ្ជនរាប់ពីត្រឹម ៤ រូបឡើងទៅហៅថា សម្មតិសង្ឃ « សង្ឃកើតឡើងដោយសារសន្មត », លោកដែលបានសម្រេចមគ្គផល តាំងពីត្រឹមសោតាបត្តិមគ្គជាដើម, សូម្បីតែ ១ អង្គក៏ហៅថា អរិយសង្ឃ ដែរ ។

១១០ – បុ. សាមណេរពោលតិះដៀលឬជេរប្រទេចសង្ឃពួកណាដែលត្រូវនាសនគ្គនោះ?

១១០ – វិ. តាមតែសង្ឃពួកណាក៏ដោយចុះឲ្យតែពោលតិះដៀលឬជេរប្រទេចហើយ សុទ្ធតែត្រូវនាសនគ្គទាំងអស់ ។

១១១ - ប្រ. ពាក្យដែលថា « សាមណេរជេរប្រទេចនូវភិក្ខុទាំងឡាយ » ក្នុងទណ្ឌកម្មទី ៩ នឹងពាក្យថា «ជេរប្រទេចនូវព្រះសង្ឃ» ក្នុងទីនេះផ្សេងគ្នាដូចម្ដេច? បានជាក្នុងទីឯណោះឲ្យត្រូវត្រឹមទណ្ឌកម្ម, មកក្នុងទីនេះបែរជាឲ្យត្រូវនាសនង្គវិញ ចូរនិយាយឲ្យសមគួរមកមើល ។

១១១ - វិ. ផ្សេងគ្នាដូច្នេះ ពាក្យដែលថា « សាមណេរជេរប្រទេចនូវភិក្ខុទាំងឡាយ » នោះគឺជេរប្រទេចចំពោះភិក្ខុ ១ រូបៗ, ឬចំពោះភិក្ខុ ២ រូប ៣ រូប មានពាក្យថា « លោកឯងជាវត្តខ្ចបានជាធ្វើនិទិតៈយ៉ាងហ្នឹង? លោកឯងជាមនុស្សគ្មានពូជអម្បូរ? លោកជាមនុស្សអត់ត្រកូល, លោកឯងសមតែដាក់ទីងដើងធ្ងន់, អាចោរត្រអាលិតតសីល, ឯងបួសកុំឲ្យតែចៃខាំក្បាល, អាចង្រៃឯងសមតែសម្លាប់ចោល» យ៉ាងនេះជាដើមហៅថាជេរប្រទេចនូវភិក្ខុទាំងឡាយ; ជេរចំពោះភិក្ខុប៉ុប្ពុនទ១រូបៗ ដូច្នេះបានជាត្រូវត្រឹមទណ្ឌកម្ម ។ ឯពាក្យដែលថា « ជេរប្រទេចនូវព្រះសង្ឃ » នោះគឺសំដៅយកពាក្យដែលជេរមិនមែនចំពោះរូបណាៗរូបណា ជេររួមទាំងអស់មិនមានវៀរ មិនមានរើសមុខ ដូចជាជេរថា « អាលោកសង្ឃ អានេះសុទ្ធតែជាមេបោកប្រាសបញ្ចុះបញ្ចូលគេស៊ី; អាដែងត្រដោលទាំងអស់នេះសមតែបាញ់ចោលអាចង្រៃ» ជេរមើយ៉ាងនេះហៅថាជេរព្រះសង្ឃ; ឬជេរចំពោះព្រះអរិយៈ សូម្បីតែ ១ អង្គ ក៏ហៅថាជេរព្រះសង្ឃដែរ » បាន

វាត្រូវដល់នាសនគ្គ ព្រោះផេះព្រះសង្ឃ ។

១១៦-ប្រ. សាមណេរ ១ រូបទៅបិណ្ឌបាត ដល់ណ្តើមមិនឈ្នះ លាភវត្ថុមកុដកន្ត្រៃ, កើតសេចក្តីក្តៅចិត្តទើបជេរផ្តាសាថា "អាលោកស្ដូមកុដកន្ត្រៃទាំងអស់នេះ ឬកមារយាទអាក្រក់ណាស់ហ្ន៎ ! ដល់ណ្តើមបាយគ្នាដូចខ្លែ, អាអស់ទាំងហ្នឹង សមតែកាប់ក្បាល" យ៉ាងនេះតើសាមណេរនោះគួរដល់ទណ្ឌកម្ម ឬនាសនគ្គ ?

**១១៦-វិ.** សាមណេរជេររូបលោកសង្ឃទាំងមួយវគ្គ បែបនេះឈ្មោះថា "ជេរប្រទេចព្រះសង្ឃ" មិនឈ្មោះថា "ជេរប្រទេចនូវភិក្ខុទាំងឡាយ" ទេ កាលបើជេរចំពោះសង្ឃយ៉ាងនេះហើយ ត្រូវនាសនគ្គពេញទី ។

១១៧-ប្រ. សាមណេរតាំងពី ៤ រូប ឬ ៥ រូបឡើងទៅហៅថាសង្ឃបានឬទេ ? ព្រោះហេតុអ្វី? សព្ទថា មហាសក្កុណាសង្ឃោ ប្រែថាម៉េច? ព្រោះហេតុអ្វី ?

១១៧-វិ. សាមណេរតាំងពី ៤ រូបឬ ៥ រូប ហៅថាសង្ឃពុំបានឡើយ ឬក៏ច្រើនរូបរហូតដល់១អសង្ខេយ្យទៅ ក៏ហៅថាសង្ឃមិនបានដែរ, ព្រោះសាមណេរជាកូនរបស់ភិក្ខុ មិនមានកិច្ចដោយសង្ឃកម្មផ្សេងៗមាន៖ ឧបោសថកម្ម, ញត្តិចតុត្ថកម្មជាដើម គឺថាមិនអាចនឹងញ៉ាំងសង្ឃកម្មទាំងនោះឲ្យសម្រេចបាន, ដែលថានេះគឺនិយាយតាមវិន័យសម្មតិ,សព្ទ

ថាមហាសកុណសង្ឃ ដែលប្រែថា “ហ្វូងនៃសត្វស្លាប” ព្រោះសង្ឃសព្ទនេះប្រែបានច្រើនយ៉ាងគឺប្រែថា “ហ្វូង, ពួក, គណៈ, ប្រជុំ, បន, ក្រុម” ជាដើម ដែលនិយាយនេះគឺថាតាមរូបសព្ទ តាមលោកវោហារ ដែលធ្លាប់ហៅធ្លាប់ថាមក ។

១១៨–ប្រ. សាមណេរមានទិដ្ឋិខុស, ទិដ្ឋិដូចម្ដេចដែលខុស ? ត្រូវទោសអ្វី ?

១១៨–វិ. សាមណេរមានទិដ្ឋិខុសនោះ, គឺមានគំនិតយល់ឃើញខុសក្រៅធម្មវិន័យរបស់ព្រះដ៏មានព្រះភាគ ត្រូវទោសនាសនង្គ ។

១១៩–ប្រ. ចូរអធិប្បាយអំពីគំនិតយល់ឃើញខុសចាកធម្មវិន័យរបស់ព្រះដ៏មានព្រះភាគមកមើល, មានរឿងរ៉ាវកាលពីដើមយ៉ាងម៉េចខ្លះដែរឬ ? បើល្មមនឹងនាំមកបានក៏ចូរនាំមកមើល ។

១១៩–វិ. កាលព្រះដ៏មានព្រះភាគគង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯងកណ្ដកសមណុទ្ទេសមានទិដ្ឋិអាក្រក់ គឺមានគំនិតយល់ខ្វេងចាកធម្មវិន័យរបស់ព្រះដ៏មានព្រះភាគ មានសភាពយ៉ាងនេះកើតឡើងដូច្នេះថា “ខ្ញុំដឹងច្បាស់នូវធម៌ដែលព្រះដ៏មានព្រះភាគសំដែងហើយ គឺធម៌ទាំងឡាយឯណាដែលព្រះដ៏មានព្រះភាគសំដែងថា ជាធម៌ធ្វើសេចក្ដីអន្តរាយ, ធម៌ទាំងឡាយនោះ មិនអាចធ្វើសេចក្ដីអន្តរាយ ដល់បុគ្គលអ្នកសេពនោះទេ” ។ ភិក្ខុជាច្រើន

រូបបានឮដំណឹងថា កណ្ដកសមណុទ្ទេសមានទិដ្ឋិអាក្រក់ មានសភាព យ៉ាងនេះកើតឡើង ក៏នាំគ្នាចូលទៅនិយាយនឹងសមណុទ្ទេសនោះថា “នែអាវុសោ កណ្ដកៈ! ឮថាអ្នកឯងមានទិដ្ឋិអាក្រក់យ៉ាងនោះមែន ? សមណុទ្ទេសក៏ឆ្លើយថាករុណាម្ចាស់ ! ហើយភិក្ខុទាំងនោះក៏និយាយ ដាស់តឿនក្រើនរំឭកថា “នែអាវុសោ កណ្ដកៈ! អ្នកកុំនិយាយ យ៉ាងនេះឡើយ, កុំពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ, ការពោល បង្កាច់ព្រះដ៏មានព្រះភាគមិនល្អទេ, ព្រះដ៏មានព្រះភាគមិនត្រាស់យ៉ាង នេះទេ, នែអាវុសោ កណ្ដកៈ! ធម៌ទាំងឡាយធ្វើសេចក្ដីអន្តរាយ ដែល ព្រះដ៏មានព្រះភាគសំដែងហើយ ដោយបរិយាយជាច្រើន ធម៌ទាំង ឡាយនោះ អាចធ្វើសេចក្ដីអន្តរាយដល់បុគ្គលអ្នកសេពមែន, ព្រះដ៏មាន ព្រះភាគសំដែងហើយថា: កាមទាំងឡាយមានសេចក្ដីសុខតិច មានទុក្ខ ច្រើន មានសេចក្ដីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះ មានច្រើន, ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមានឧបមា ដោយកង់ឆ្អឹង ..., មានឧបមាដោយដុំសាច់..., មានឧបមាដោយគប់ ភ្លើងធ្វើពីស្មៅ ..., មានឧបមាដោយរងើកភ្លើង.., មានឧបមាដោយអ្នក យល់សប្តិ...., មានឧបមាដោយរបស់ខ្ចីគេ...., មានឧបមាដោយផ្លែឈើ មានឧបមាដោយកាំបិតនឹងជ្រញ់...., មានឧបមាដោយលំពែងនឹងដែក ស្រួច...., ព្រះដ៏មានព្រះភាគសំដែងហើយថា កាមទាំងឡាយមាន

ទុប្បរាដោយក្បាលពស់ មានទុក្ខច្រើន មានសេចក្តីចង្អៀតចង្អល់ច្រើន ទោសក្នុងកាមទាំងឡាយនេះមានច្រើន, កណ្តកសមណុទ្ទេស កាលដែលភិក្ខុទាំងឡាយពោលយ៉ាងនេះ ក៏នៅតែប្រកាន់ទិដ្ឋិអាក្រក់នោះយ៉ាងមាំ ហើយពោលយ៉ាងនោះដដែល, ភិក្ខុទាំងឡាយនោះ មិនអាចដោះកណ្តកសមណុទ្ទេសចេញពីទិដ្ឋិនោះបាន ហើយក៏ចូលទៅក្រាបទូលសេចក្តីនុ៎ះ ចំពោះព្រះដ៏មានព្រះភាគ; ព្រះអង្គក៏ទ្រង់ប្រជុំភិក្ខុសង្ឃ ត្រាស់សួរកណ្តកសមណុទ្ទេសនោះដោយសព្វគ្រប់ ទើបទ្រង់ប្រៀនប្រដៅពន្យល់ណែនាំឲ្យលះបង់ ទិដ្ឋិនោះចេញ, តែសមណុទ្ទេសនោះមិនព្រមលះបង់ចេញ, ព្រះអង្គក៏មានបន្ទូលថា «ម្នាលភិក្ខុទាំងឡាយ! បើដូច្នោះ សង្ឃចូរញ៉ាំងកណ្តកសមណុទ្ទេសឲ្យវិនាសចុះ, ម្នាលភិក្ខុទាំងឡាយ! កណ្តកសមណុទ្ទេសនោះ ភិក្ខុទាំងឡាយត្រូវឲ្យវិនាសយ៉ាងនេះថា "នែអាវុសោកណ្តក:! កាលមានថ្ងៃនេះជាដើម អ្នកឯងមិនត្រូវអាងព្រះដ៏មានព្រះភាគអង្គនោះ ថាជាសាស្តារបស់អ្នកឡើយ, សមណុទ្ទេសទាំងឡាយដទៃ ដែលបានទទួលកិរិយាដេករួមឯណា អស់រាត្រីពីរនឹងរាត្រីបីជាមួយនឹងភិក្ខុទាំងឡាយ កិរិយាដេកនៅរួមនោះមិនមានដល់អ្នកទេ, នែមនុស្សគ្រោតគ្រាត! អ្នកឯងចូរចៀសចេញ, អ្នកចូរវិនាសទៅ" ក្នុងកាលនោះឯង សង្ឃបានឲ្យកណ្តកសមណុទ្ទេសវិនាសហើយ; ទិដ្ឋិអាក្រក់ដូចកណ្តកសមណុទ្ទេសនេះឯងហៅថាទិដ្ឋិខុសក្រៅ

ចាកធម្មវិន័យរបស់ព្រះដ៏មានព្រះភាគ ។

១១៦– ប្ញ. សាមណេរប្រទូស្តទីឯនាងភិក្ខុនី, ប្រទូស្តដូចម្តេចទៅ? ដាល់តប់ទៅឬយ៉ាងណាទៅវិញទេ, ត្រូវទោសអ្វី?

១១៦– វិ. សាមណេរប្រទូស្តទីឯនាងភិក្ខុនីនោះមិនមែនដាល់ទះតប់ទេ, ប្រទូស្តក្នុងទីនេះសំដៅយកការធ្វើអសទ្ធម្ម គឺសេពមេថុនធម្មក្នុងទ្វារមគ្គទាំងបីទ្វារឯណាមួយ របស់នាងភិក្ខុនី, ត្រូវនាសនង្គ ។

១១៧– ប្ញ. នាសនង្គទីប៉ុន្មាន ដែលសាមណេរបង់ប្រព្រឹត្តឲ្យកន្ទួនតែមិនកន្ទួន? ព្រោះហេតុអ្វី?

១១៧– វិ. នាសនង្គទី ១០ សាមណេរបង់ប្រព្រឹត្តឲ្យកន្ទួនមិនកន្ទួនទេ, ព្រោះសម័យឥឡូវនេះមិនមាននាងភិក្ខុនី ។

នាសនង្គវគ្គទី ៥ ចប់

## បយោគ វគ្គទី៦

១១៨– ប្ញ. ប្រយោគនៃសិក្ខាបទទាំងពួង មានមកប្រយោជន៍អ្វី?

១១៨– វិ. ប្រយោគនៃសិក្ខាបទទាំងពួង មានមកប្រយោជន៍នឹងឲ្យដឹងថា សិក្ខាបទពួកណាខ្លះដែលគេប្រុសដោយខ្លួនឯង ទើបបានឈ្មោះថាកន្ទួន, សិក្ខាបទពួកណាខ្លះដែលប្រើអ្នកដទៃឲ្យធ្វើទើបបានឈ្មោះថាកន្ទួន ។

១១៩– ប្រ. សាហត្ថិកបយោគនិងអាណត្តិកបយោគ សេចក្ដីខុសគ្នាដូចម្ដេច ?

១១៩–វិ. សាហត្ថិកបយោគនិងអាណត្តិកបយោគនោះមាន សេចក្ដីខុសគ្នាដូច្នេះ: សាហត្ថិកបយោគអ្នករកប្រព្រឹត្តខុស ដោយខ្លួនឯងទើបត្រូវទោស, ប្រើអ្នកដទៃឲ្យធ្វើ មិនបានឈ្មោះថាកខ្វង់ទេ; ឯអាណត្តិកបយោគនោះអ្នករកប្រព្រឹត្តខុសដោយខ្លួនឯង ក៏ត្រូវទោស, ប្រើអ្នកដទៃឲ្យធ្វើក៏ឈ្មោះថាមានទោសដូចគ្នា ។

១២០– ប្រ. សិក្ខាបទទីប៉ុន្មានខ្លះជាសាហត្ថិកបយោគ, ទីប៉ុន្មានខ្លះជាអាណត្តិកបយោគ ?

១២០–វិ សិក្ខាបទទី ៣, ទី ៤, ទី ៥, ទី ៦, ទី ៧, ទី ៨, និងទី ៩, ទាំង ៧ សិក្ខាបទនេះជាសាហត្ថិកបយោគ, សិក្ខាបទទី ១, ទី ២ និងទី ១០ ទាំង ៣ សិក្ខាបទនេះជាអាណត្តិកបយោគ ។

១២១– ប្រ. សាមណេរប្រើគេឲ្យសម្លាប់សត្វ ឲ្យលួចទ្រព្យអ្នកដទៃត្រូវនាសនទណ្ឌឬទេ ? បើថាមិនត្រូវក៏ហើយទៅ, បើថាត្រូវតើ ព្រោះសិក្ខាបទទាំងពីរនោះជាបយោគអ្វី ?

១២១–វិ. សាមណេរប្រើគេឲ្យសម្លាប់សត្វ, ឲ្យលួចទ្រព្យអ្នកដទៃនោះត្រូវនាសនទណ្ឌពេញទី , ព្រោះសិក្ខាបទទាំងពីរនោះជាអាណត្តិកបយោគ ធ្វើឲ្យកន្លងដោយខ្លួនឯងក៏ត្រូវទោស ប្រើអ្នកដទៃឲ្យធ្វើក៏ត្រូវទោស ។

១៦២– ប្រ. សាមណេរប្រើគេឲ្យទៅសេពមេថុនធម្ម នឹងអ្នកដទៃ ត្រូវនាសនង្គឬទេ ? ព្រោះហេតុអ្វី ?

១៦២– វិ. សាមណេរប្រើគេឲ្យទៅសេពមេថុនធម្ម នឹងអ្នកដទៃ មិនត្រូវនាសនង្គទេ ព្រោះសិក្ខាបទនុ៎ះជាសាហត្ថិកបយោគ, អ្នកប្រើឲ្យគេធ្វើមិនត្រូវទោស, ត្រូវទោសតែអ្នកទទួលបង្គាប់ទៅធ្វើ ។

១៦៣– ប្រ. សាមណេរចាក់សុរាឲ្យគេផឹក, គេមិនព្រមផឹកក៏បង្ខំឲ្យគេផឹកទាល់តែគេផឹកទៅ ត្រូវនាសនង្គឬទេ ? ព្រោះហេតុអ្វី ?

១៦៣ - វិ. សាមណេរចាក់សុរាឲ្យគេផឹក មិនត្រូវនាសនង្គទេ, ព្រោះសិក្ខាបទនុ៎ះក៏ជាសាហត្ថិកបយោគដែរ ។

១៦៤– ប្រ. សាមណេរប្រើគេឲ្យច្រៀង, រាំ. លេងល្បែង ត្រូវទណ្ឌកម្មឬទេ ? ព្រោះហេតុអ្វី ?

១៦៤– វិ. សាមណេរប្រើគេឲ្យច្រៀង, រាំ, លេងល្បែងមិនត្រូវទណ្ឌកម្មទេ, ព្រោះសិក្ខាបទនុ៎ះជាសាហត្ថិកបយោគ ។

១៦៥– ប្រ. សាមណេរដេញចាប៉ុស្ដាប់ត្រូវទណ្ឌកម្មឬទេ ? បើថាមិនត្រូវក៏ហើយទៅ បើថាត្រូវតើព្រោះហេតុអ្វី ?

១៦៥– វិ. សាមណេរដេញចាប៉ុស្ដាប់នោះ ត្រូវទណ្ឌកម្មពេញទី, ពីព្រោះបយោគនេះជាសាហត្ថិកបយោគ ។

១៦៦– ប្រ. សាមណេរប្រើគេឲ្យទុកលុយកាក់ ដើម្បីប្រយោជន៍

ខ្លួនត្រូវទណ្ឌកម្មឬទេ? ព្រោះហេតុអ្វី?

១៦៦- វិ. សាមណេរប្រើគេឲ្យទុកលុយកាក់ ដើម្បីប្រយោជន៍ខ្លួនត្រូវទណ្ឌកម្ម, ព្រោះសិក្ខាបទនុ៎ះជាអាណត្តិកប្រយោគ, ទុកដាក់ដោយខ្លួនឯងក៏ត្រូវទោស (វៀរលែងតែទុកដាក់ឲ្យអ្នកដទៃ), ប្រើគេឲ្យទុកដាក់ ដើម្បីខ្លួនឯងក៏ត្រូវទោសមកលើខ្លួន ។

បយោគវគ្គទី ៦ ចប់

---

## អាវរណកម្មវគ្គទី ៧

១៦៧- បុ. សាមណេរមានទោសខុសគួរដល់ទណ្ឌកម្មហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ឲ្យភិក្ខុជាឧបជ្ឈាយ៍ឬអាចារ្យ, ធ្វើដូចម្ដេចទៅ? ហៅថាអ្វី? ចូរអធិប្បាយ ។

១៦៧- វិ. ព្រះអង្គទ្រង់អនុញ្ញាតឲ្យធ្វើអាវរណកម្ម។ នោះទ្រង់ត្រាស់បង្គាប់ឲ្យហាមប្រាមដល់សាមណេរទាំងឡាយ, ដែលមានសេចក្ដីខុសគួរដល់ទណ្ឌកម្ម ។

១៦៨- បុ. ការហាមប្រាមដល់សាមណេរនោះត្រូវហាមដូចម្ដេច? ចូរអធិប្បាយឲ្យសព្វគ្រប់ ។

១៦៨- វិ. ការដែលហាមនោះដូច្នេះគឺបើសាមណេរនោះនៅក្នុងទីណា, តែងនឹងដើរចូលទៅក្នុងទីណា, ត្រូវហាមកុំឲ្យនៅក្នុងទីនោះ កុំឲ្យដើរចូលទៅក្នុងទីនោះ, ឯកិច្ចដែលនឹងហាមនោះត្រូវហាមដោយ

ពាក្យថា «អ្នកកុំនៅក្នុងទីនេះ, អ្នកកុំដើរចូលទៅក្នុងទីនោះ» ។

១២៩–ប្រ. បើព្រះឧបជ្ឈាយ៍ឬអាចារ្យហាមសាមណេរមិនឲ្យនៅក្នុងទីអាវាសទាំងមូល, បង្អត់មិនឲ្យបរិភោគអាហារយ៉ាងនោះគួរឬទេ ? បើគួរក៏ហើយទៅ បើមិនគួរតើយ៉ាងម៉េចទៅ ?

១២៩–វិ. ព្រះឧបជ្ឈាយ៍ឬអាចារ្យលោកហាមយ៉ាងនុះមិនគួរទេ ព្រះសម្មាសម្ពុទ្ធទ្រង់បញ្ញត្តមិនឲ្យហាមបែបនេះឡើយ, បើនៅតែហាមយ៉ាងហ្នឹង លោកត្រូវអាបត្តិទុក្កដ ។

១៣០–ប្រ. ទណ្ឌកម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យធ្វើ នឹងទណ្ឌកម្ម ដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយបញ្ញត្តថែមឡើង មានសេចក្ដីដូចគ្នាឬប្លែកគ្នា ? ចូរអធិប្បាយមកមើល ។

១៣០–វិ. ទណ្ឌកម្មដែលព្រះសម្មាសម្ពុទ្ធទ្រង់អនុញ្ញាតឲ្យធ្វើ នឹងទណ្ឌកម្មដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយ លោកបញ្ញត្តថែមឡើងនោះ មានសេចក្ដីប្លែកគ្នា គឺទណ្ឌកម្មដែលព្រះអង្គអនុញ្ញាតឲ្យធ្វើនោះ គ្រាន់តែឲ្យភិក្ខុហាមមិនឲ្យសាមណេរនៅក្នុងទីដែលធ្លាប់នៅ នឹងហាមមិនឲ្យចេញចូលក្នុងទីដែលធ្លាប់ចេញចូលតែម្យ៉ាងប៉ុណ្ណោះ ; ឯទណ្ឌកម្មដែលព្រះធម្មសង្គាហកត្ថេរទាំងឡាយលោកបញ្ញត្តថែមនោះ គឺលោកបង្គាប់ថាឲ្យដាក់ទណ្ឌកម្មដោយកិច្ច គឺឲ្យដងទឹក, រែកឧស, ជញ្ជូនដីខ្សាច់ ច្រើនឬតិចតាមទោសដែលធ្វើខុស, តែថាដែលនឹងឲ្យធ្វើដូច្នេះនោះ

លុះតែឲ្យធ្វើដោយសេចក្ដីករុណា ប្រាថ្នានឹងឲ្យវៀរចាកសេចក្ដីខុសនោះ ទើបគួរ នឹងធ្វើដោយចិត្តអាក្រក់ គិតចង់ឲ្យសាមណេរនោះសឹកចេញ នោះមិនគួរទេ សេចក្ដីប្លែកគ្នាដូច្នេះ ។

១៣១– ប្រ. បើសាមណេរមានទោសខុសគួរដល់ទណ្ឌកម្ម ហើយ, អ្នកណាខ្លះគួរដាក់ទណ្ឌកម្មដល់សាមណេរ? សាមណេរនឹងសាមណេរដាក់ទណ្ឌកម្មដល់គ្នានឹងគ្នា បានឬទេ?

១៣១–វិ. បើសាមណេរមានទោសគួរដល់ទណ្ឌកម្មហើយ, ត្រូវព្រះឧបជ្ឈាយ៍ឬអាចារ្យរបស់សាមណេរនោះដាក់ទណ្ឌកម្មឲ្យ, បើព្រះឧបជ្ឈាយ៍ឬអាចារ្យមិននៅ ត្រូវភិក្ខុដែលឧបជ្ឈាយ៍ឬអាចារ្យបានផ្ដាំផុកផ្ដាក ឲ្យមើលថែទាំនោះដាក់ឲ្យ; សាមណេរនឹងសាមណេរដូចគ្នា ដាក់ទណ្ឌកម្មដល់គ្នានឹងគ្នាពុំបានឡើយ ។

១៣៦–ប្រ. បើសាមណេរខូចជាងគេព្រះឧបជ្ឈាយ៍លោកដាក់ទណ្ឌកម្មឲ្យប្រោសកុជអត់បាយទាល់តែហើយ ទើបឲ្យឆាន់យ៉ាងនេះតើគួរ ឬមិនគួរ? ប្រគប ។

១៣៦–វិ. ព្រះឧបជ្ឈាយ៍លោកធ្វើយ៉ាងនោះ ក៏គួរដែរ, ព្រោ សាមណេរដែលវិលខូចពេក, លោកប្រដៅបានដោយកម្រនោះ ល្ម តែធ្វើយ៉ាងហ្នឹងទើបកងចាលតទៅមុខទៀត ។

១៣៧–ប្រ. កិច្ចដែលឲ្យសាមណេរវិនាសនោះមានប៉ុន្មានយ៉ាង

១៣៣–វិ. កិច្ចដែលឲ្យសាមណេរវិនាសនោះមានបីយ៉ាងគឺ: សំវាសនាសនា វិនាសទីកន្លែងខានបាននៅរួមជាមួយនឹងសង្ឃ, ឬត្រូវថយចេញផុតពីទីកន្លែងរបស់សង្ឃ១, លិង្គនាសនា វិនាសចាកភេទគឺត្រូវផ្សឹកចេញ១. ទណ្ឌកម្មនាសនា វិនាសដោយត្រូវទណ្ឌកម្មមានមិនឲ្យដេកនៅរួមនឹងភិក្ខុអស់ពីរ-បីរាត្រីជាដើម១ ។

១៣៤–បុ. កិច្ចដែលឲ្យសាមណេរវិនាសនេះមានវិធីខុសគ្នាដែរឬទេ ? បើខុសគ្នាតើលោកចែកជាពួកដូចម្ដេច ?

១៣៤–វិ. កិច្ចដែលឲ្យសាមណេរវិនាសនោះមានវិធីខុសគ្នាចែកចេញជា៤ពួកគឺ: តាំងពីនាសនង្គទី១ ដល់ទី៥ ជាពួក១, តាំងពីទី ៦ដល់ទី ៨ ជាពួក១, ទី ៩ ជាពួក១, ទី១០ជាពួក១; វិធីធ្វើនោះយ៉ាងនេះ បើសាមណេរឯណាប្រព្រឹត្តធ្វើឲ្យកន្លងក្នុងសិក្ខាបទ៥ខាងដើម នោះព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវឲ្យសាមណេរនោះសឹកចេញ ក្នុងខណៈដែលប្រព្រឹត្តធ្វើឲ្យកន្លងសីលនោះ, សាមណេរឯណាមួយដឹងថាខ្លួនប្រព្រឹត្តនោះខុសហើយៗបានប្រាប់ដល់ព្រះឧបជ្ឈាយ៍ ឬ អាចារ្យ ដើម្បីនឹងលន់តួទោសនោះ ព្រះឧបជ្ឈាយ៍ឬអាចារ្យមិនត្រូវផ្សឹកសាមណេរនោះទេ, ត្រូវឲ្យសរណគមន៍ជាថ្មីទៀត;បើសាមណេរប្រព្រឹត្តខុសហើយមិនបានដឹងខ្លួនទេ, ដោយប្រព្រឹត្តនោះអាក្រក់ជ្រុលហួសប្រមាណពេកណាស់ផងនោះ ត្រូវអបលោកន៍ប្រាប់សង្ឃឲ្យដឹង ហើយឲ្យសឹកចេញ,បើសឹកចេញហើយ

ចូលមកសូមបួសទៀត, នោះក៏គប្បីអបលោកន៍ប្រាប់សង្ឃឲ្យដឹង ហើយឲ្យ
បួសទៀតចុះ ១ ៗ

បើសាមណេរប្រព្រឹត្តធ្វើឲ្យគន្លងក្នុងនាសនង្គទី ៦, ទី ៧, ទីង ទី ៨ នោះព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវសំដែងទោស ប្រាប់សាមណេរនោះថា " ការពោលតិះដៀលព្រះរត្នត្រ័យយ៉ាងនេះ មានទោសជាទម្ងន់ណាស់ អ្នកពោលតិះដៀលព្រះរត្នត្រ័យដូច្នេះមិនត្រូវទេ, ក្រោយ ៗ កុំពោលយ៉ាងហ្នឹងទៀត,, បើបានហាមប្រាមដូច្នេះហើយ សាមណេរព្រមលះបង់អំពើអាក្រក់នោះចេញ ក៏គប្បីដាក់ទណ្ឌកម្មរួចហើយឲ្យសំដែងទោសក្នុងកណ្ដាលជំនុំសង្ឃ, ហើយត្រូវឲ្យព្រះត្រៃសរណគមន៍និងសីលជាថ្មីទៀត ១ ៗ

បើសាមណេរប្រព្រឹត្តធ្វើឲ្យគន្លងក្នុងនាសនង្គទី៩ នោះព្រះឧបជ្ឈាយ៍ ឬអាចារ្យ ត្រូវសំដែងទោសមិច្ឆាទិដ្ឋិប្រាប់សាមណេរនោះឲ្យលះបង់ទិដ្ឋិនោះចេញ, បើព្រមលះបង់ក៏ត្រូវដាក់ទណ្ឌកម្ម រួចឲ្យសំដែងទោសក្នុងកណ្ដាលជំនុំសង្ឃរួចហើយ ត្រូវឲ្យព្រះត្រៃសរណគមន៍និងសីលជាថ្មីទៀត, បើមិនព្រមលះបង់ទិដ្ឋិនោះចេញទេត្រូវផ្ដើតចេញ, បើមានប្រាថ្នាចង់បួសវិញត្រូវអបលោកន៍ប្រាប់សង្ឃហើយឲ្យបួសទៀតចុះ ១ ៗ

បើសាមណេរមានទោសខុសក្នុងនាសនង្គទី ១០ នោះត្រូវព្រះឧបជ្ឈាយ៍ ឬអាចារ្យផ្ដើតសាមណេរនោះចេញតែម្យ៉ាង, បើទុកជាមាន

ប្រាថ្នានឹងចង់បួសទៀត ក៏មិនត្រូវបំបួសទៀតឡើយ, រួមត្រូវជាវិធីធ្វើទោសមាន ៤ សង្កាត់ ។

១៣៥– ប្រ. ពាក្យដែលថា សាមណេរត្រូវនាសនង្គ ហើយរម្ងាប់នោះតើរម្ងាប់អ្វីខ្លះ ?

១៣៥– វិ. ពាក្យដែលថា សាមណេរត្រូវនាសនង្គ ហើយរម្ងាប់នោះគឺរម្ងាប់សរណគមន៍១, រម្ងាប់ព្រះឧបជ្ឈាយ៍១, រម្ងាប់ទីនៅ១, គឺថាមិនមានសរណគមន៍, មិនមានឧបជ្ឈាយ៍នឹងមិនមានទីសេនាសនៈ ។

១៣៦– ប្រ. សាមណេរត្រូវនាសនង្គហើយបិទបាំងទុក នឹងសាមណេរដែលត្រូវហើយដឹងទោសខ្លួន រ៉ាសរវើរទៅសូមព្រះត្រៃសរណគមន៍ទៀត សាមណេរទាំងពីររូបនេះតើមានសេចក្ដីវិសេសប្លែកគ្នា ដូចម្ដេច ?

១៣៦– វិ. សាមណេរទាំងពីររូបនោះមានសេចក្ដីវិសេសប្លែកគ្នាដូច្នេះ គឺសាមណេរដែលបិទបាំងទោសទុកនោះ បើព្រះឧបជ្ឈាយ៍ឬអាចារ្យដឹងហើយ ត្រូវផ្សឹកសាមណេរនោះចេញ ។ ចំណែកខាងសាមណេរដែលបានដឹងទោសរបស់ខ្លួននោះ ព្រះឧបជ្ឈាយ៍ឬអាចារ្យគ្រាន់តែដាក់ទណ្ឌកម្មដល់សាមណេរនោះ ហើយឲ្យព្រះត្រៃសរណគមន៍ជាថ្មីទៀតទៅ មិនបាច់ផ្សឹកឡើយ, វិធីប្លែកគ្នាយ៉ាងនេះ ។

១៣៧– ប្រ. ថ្ងៃចូលវស្សាមានប៉ុន្មាន ? គឺអ្វីខ្លះ ?

✕ ១៣៧– វិ. ថ្ងៃចូលវស្សាមានពីរ គឺថ្ងៃបុរិមិកាវស្សា ( ថ្ងៃចូល

វស្សាមុន)១, ថ្ងៃបច្ឆិមិកាវស្សា (ថ្ងៃចូលវស្សាក្រោយ) ១ ។

១៣៨–ប្រ. បុរិមិកាវស្សា នឹង បច្ឆិមិកាវស្សា មានកំណត់ថ្ងៃដែលចូលដូចម្ដេច ? ថ្ងៃដែលត្រូវចេញវិញ តើថ្ងៃណា ?

× ១៣៨–វិ. បុរិមិកាវស្សា នឹង បច្ឆិមិកាវស្សានោះ មានកំណត់ថ្ងៃចូលនឹងថ្ងៃចេញផ្សេងគ្នាដូច្នេះ គឺ បុរិមិកាវស្សា ត្រូវចូលក្នុងថ្ងៃបន្ទាប់នៃថ្ងៃពេញបូណ៌មីខែអាសាឍ គឺថ្ងៃ ១ រោចខែអាសាឍត្រូវចេញនៅថ្ងៃពេញបូណ៌មីខែអស្សុជ, បច្ឆិមិកាវស្សាត្រូវចូលក្នុងថ្ងៃដែលគន្លងហួសមួយខែ អំពីថ្ងៃពេញបូណ៌មីខែអាសាឍ គឺថ្ងៃ១រោចខែស្រាពណ៍, ត្រូវចេញនៅថ្ងៃពេញបូណ៌មីខែកត្តិក ។

១៣៩– ប្រ. សាមណេរដែលបានចូលបុរិមិកាវស្សា, នឹងសាមណេរដែលចូលបច្ឆិមិកាវស្សា, នឹងសាមណេរដែលដាច់វស្សា, សាមណេរទាំង ៣ រូបនុ៎ះ សាមណេរណាគួរបានសង្ឃលាភដូចម្ដេច ?

× ១៣៩–វិ. សាមណេរដែលបានចូលបុរិមិកាវស្សានោះ ត្រូវបានសង្ឃលាភស្មើនឹងភិក្ខុទាំងឡាយដែរ, ឯសាមណេរដែលចូលបច្ឆិមិកាវស្សា នឹងសាមណេរដែលដាច់វស្សានោះ មិនត្រូវបានលាភដែលកើតឡើងដល់សង្ឃនោះទេ, លុះតែសង្ឃបានធ្វើអបលោកនកម្មហើយចែកឲ្យសាមណេរនោះផងទើបបាន; ឯវស្សាវាសិកលាភនោះ បើទាយកគេបានបវារណាទុកស្រេចហើយ មិនបាច់ធ្វើអបលោកនកម្ម ក៏ចែកឲ្យបានដែរ ។

១៤០– ប្រ. កាលចីវរដែលកើតឡើងដល់សង្ឃនោះតើកើតឡើងក្នុងថ្ងៃណា? នឹងមានកំណត់ដូចម្ដេច?

១៤០– វិ. កាលចីវរដែលកើតឡើងដល់សង្ឃនោះមានកំណត់កាលថា "បើសង្ឃមិនបានក្រាលគ្រងកឋិនទេ កើតឡើងតាំងពីថ្ងៃ ១ រោចខែអស្សុជ ដរាបដល់ថ្ងៃពេញបូណ៌មីខែកត្តិក, បើសង្ឃបានក្រាលគ្រងកឋិនហើយ កាលចីវររាប់តាំងពីថ្ងៃ ១ រោចខែអស្សុជតទៅទល់នឹងថ្ងៃ ១៥ កើតខែផល្គុន" ។

១៤១– ប្រ. ភិក្ខុ-សាមណេរដែលចូលវស្សាហើយបើមានកិច្ចធុរៈត្រូវទៅស្រុកឆ្ងាយបានខ្លះឬទេ? វស្សានោះដាច់ឬមិនដាច់? ព្រោះហេតុអ្វី?

១៤១– វិ. ភិក្ខុសាមណេរដែលចូលវស្សាហើយ បើមានកិច្ចធុរៈជាទម្ងន់ ត្រូវទៅស្រុកឆ្ងាយក៏បាន, វស្សាដែលចូលនោះមិនដាច់ទេ, ព្រោះព្រះសម្ពុទ្ធជាម្ចាស់ទ្រង់អនុញ្ញាតឲ្យលើកសត្តាហកិច្ចបាន ៧ ថ្ងៃ ។

១៤២– ប្រ. សត្តាហកិច្ចនោះមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូរអធិប្បាយ ។

១៤២– វិ. សត្តាហកិច្ចនោះមានពីរយ៉ាង គឺចូលវស្សាបាន ១ ថ្ងៃ ២ ថ្ងៃ ឬក្នុងថ្ងៃដែលចូលវស្សានោះ បានចូលពីពេលល្ងាចដរាបទៀបនឹងអរុណរះ បើមានកិច្ចត្រូវទៅដោយសត្តាហកិច្ចនោះ ត្រូវលើកទៅបាន, លុះទៅហើយបានញុំាងកិច្ចដែលខ្លួនត្រូវធ្វើនោះឲ្យអស់ ៦ ថ្ងៃនៅខាងក្រៅនោះ ហើយត្រឡប់មកឲ្យបានទាន់មុនអរុណរះនៃថ្ងៃទី៧ គឺឲ្យគិតពីថ្ងៃដែលខ្លួនចេញទៅនោះជា ១ ថ្ងៃ ហើយត្រឡប់មកកាន់វត្តដែលខ្លួនចូលវស្សានោះ

បានកាន់ក្នុងវេលាយប់មុនអរុណរះតិចៗ គ្រាន់តែអរុណរះឡើង ក៏រាប់ថាជាថ្ងៃទី៧, ក្នុងថ្ងៃដែលចូលនោះ បើចូលពីល្ងាចភ្លាមលើកភ្លាមមិនបានទេ, លុះតែចង្អុលឲ្យដល់អរុណរះសិនទើបលើកបាន នេះហៅថា បឋមសត្តាហៈ ១ ។ នៅ៧ថ្ងៃទៀតនឹងចេញវស្សាគឺថ្ងៃ៨កើតខែអស្សុជឬ៨កើតខែកត្តិក, បើមានកិច្ចត្រូវទៅដោយសត្តាហៈនោះត្រូវលើកទៅបាន, តែត្រូវតាំងចិត្តថា អញនឹងត្រឡប់មកវិញក្នុងចន្លោះនៃថ្ងៃទី៧ឲ្យទាន់, បើទៅហើយ មិនអាចនឹងសម្រេចកិច្ចឲ្យទាន់ក្នុងចន្លោះនៃសត្តាហៈនោះទេ នឹងបកវេណាជាមួយនឹងវត្តនៅក្បែរនោះទៅក៏បានមិនបាច់ត្រឡប់ឡើយ, វស្សានៅពេញទីមិនដាច់, តែបើមុននឹងចេញពីវត្តបានតាំងចិត្តថា: អញនឹងមិនត្រឡប់វិញទេ យ៉ាងនេះវស្សាដាច់តាំងពីដំហានទីពីរ ដែលឈានផុតពីវត្តនោះ យ៉ាងនេះហៅថា បច្ឆិមសត្តាហៈ ១ ។ ព្រះអដ្ឋកថាលោកប្រាប់បញ្ជាក់ថា:

"នវមិតោ បដ្ឋាយ គន្តុំ វដ្ដតិ, អាគច្ឆតុ វា, មា' គច្ឆតុ វា, អនាបត្តិ ន ទុក្កដារហោ វ ហោតិ"

សេចក្តីថា បើនៅ៧ថ្ងៃទៀតនឹងចេញវស្សា ភិក្ខុលើកសត្តាហៈទៅបានដោយមានកិច្ច បើត្រឡប់មកវិញក៏បាន មិនត្រឡប់ក៏បាន, ហើយគ្មានអាបត្តិ មិនគួរនឹងឲ្យត្រូវអាបត្តិទុក្កដឡើយ» ។

១៤៣– បុ: កាលពីសម័យព្រះបរមគ្រូគង់ព្រះជន្មនៅឡើយ មានរឿងអ្វីដូចម្ដេច? បានជាទ្រង់អនុញ្ញាតឲ្យភិក្ខុលើកសត្តាហៈ !

ពេលនោះទ្រង់គង់នៅក្នុងទីណា ? ប្រារព្ធនឹងអ្នកណា ? ចូរធ្វើបេឲ្យសព្វគ្រប់មកមើល ។

x ១៤៣- វិ កាលព្រះដ៏មានព្រះភាគគង់នៅវត្តជេតវនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ក្នុងកោសលជនបទ មានឧបាសកឈ្មោះឧទេន បានឲ្យគេធ្វើវិហារចំពោះសង្ឃ ។ ឧបាសកនោះក៏បានបញ្ជូនបម្រើទៅក្នុងសំណាក់ភិក្ខុទាំងឡាយថា “ សូមឲ្យលោកម្ចាស់ទាំងឡាយនិមន្តមក ដ្បិតខ្ញុំព្រះករុណាប្រាថ្នានឹងថ្វាយទានផង ស្តាប់ធម៌ផង នឹងបានឃើញភិក្ខុទាំងឡាយផង ” ។ ពួកភិក្ខុក៏តបវិញថា “ នែឧបាសក! ព្រះដ៏មានព្រះភាគបានបញ្ញត្តហើយថា ភិក្ខុទាំងឡាយចូលវស្សាហើយ មិនបាននៅចាំបុរិមិកាវស្សាអស់ ៣ ខែ ឬ បច្ឆិមិកាវស្សាអស់ ៣ ខែទេ មិនត្រូវដើរទៅកាន់ចារិកឡើយ, សូមឲ្យឧទេនឧបាសកបង្អង់ចាំសិន ទំរាំតែភិក្ខុទាំងឡាយនៅចាំវស្សារួច លុះចាំវស្សារួចហើយមុខជានឹងទៅ; បើឧបាសកនោះមានការត្រូវធ្វើជាប្រញាប់សូមឲ្យធ្វើវិហារទុកក្នុងសំណាក់ភិក្ខុទាំងឡាយដែលនៅក្នុងអាវាសក្នុងទីនោះសិនចុះ ” ។ ឯឧទេនឧបាសក ក៏ពោលទោសតិះដៀលបន្តុះបង្អាប់ថា “ លោកម្ចាស់ទាំងឡាយ កាលបើអញបញ្ជូនពាក្យបណ្តាំទៅហើយ មិនសមបើមិននិមន្តមកសោះ ដ្បិតអញជាទាយក ជាកប្បិយការកៈ ជាឧបដ្ឋាករបស់សង្ឃ ” ។ ពួកភិក្ខុក៏នាំសេចក្តីនុ៎ះទៅក្រាបបង្គំទូលចំពោះព្រះដ៏មានព្រះ

ដំណឹងថាមានធុរៈហើយ មិនបាច់បញ្ជូនបម្រើមកក៏ទៅបានដែរ, ជនដទៃក្រៅពីនេះគឺ ឧបាសក, ឧបាសិកា, បងប្អូនប្រុស, បងប្អូនស្រី, ញាតិ, អ្នកធ្វើការឈ្នួលរបស់ភិក្ខុលុះតែបញ្ជូនបម្រើមកទើបទៅបាន, បើឥតមានឲ្យបម្រើមកទេ ភិក្ខុទៅពុំបានឡើយ ។

១៤៥– ប្រ. ដែលថាជនទាំងនោះមានធុរៈ ហើយភិក្ខុគួរលើកសត្តាហៈទៅបាននោះ តើធុរៈដូចម្តេចខ្លះ ? ចូរទាញមួយពីរមកមើល ។

១៤៥– វិ. ធុរៈមានច្រើនជាអនេក មិនអាចនឹងពណ៌នាបាន, តែបើទាញមកចំពោះតែធុរៈ ដែលមានជាញឹកញាប់នោះ ក៏គឺជនទាំងនោះគេត្រូវការចង់ធ្វើទាន, ស្តាប់ធម្មទេសនា, ត្រូវការចង់ឃើញ ។ មួយវិញទៀត គេមានកិច្ចឯណានិមួយក្តី មានកិច្ចត្រូវខានពុំបានក្តី ឬក៏មានជម្ងឺក្តី ឬក៏គ្រាន់តែអផ្សុកបន្តិចបន្តួចក្តី ប៉ុណ្ណោះជាដើម រមែងហៅថាធុរៈ ។ កាលបើមានធុរៈដូច្នេះហើយ បើចំពោះជនដែលទ្រង់អនុញ្ញាតឲ្យទៅ ក៏ភិក្ខុគួរទៅបានដោយមិនបាច់បញ្ជូនបម្រើមក, ឯពួកជនក្រៅនេះ លុះតែបញ្ជូនបម្រើមកទើបទៅបាន ។

១៤៦– ប្រ. ពួកភិក្ខុណាខ្លះ ដែលធ្វើឲ្យកន្លងសត្តាហៈហើយ វស្សាដាច់តែមិនត្រូវអាបត្តិ ?

១៤៦– វិ. ពួកភិក្ខុទាំងនេះគឺ ភិក្ខុដែលមានសត្វសាហាវ, សត្វមានពិសមកបៀតបៀន មកបោមបង្អើល, ពួកចោរ, បិសាចបៀត

ទៀន, ភ្លើងនេះស្រុកជាទីគោចរ, នេះទីសេនាសនៈ; ទឹកដងលិច ស្រុកជាទីគោចរ, មិនបានភោជនសៅហ្មង ឬ ខុត្តមល្មមឆ្អែត ពេញលេញ, មិនបានភោជនជាទីសប្បាយ, មិនបានភេសជ្ជៈជាទី សប្បាយ, មិនបានឧបដ្ឋាកឲ្យសមគួរ ភិក្ខុត្រូវតាំងចិត្តថា « អាវាស នេះមានសេចក្តីអន្តរាយ, ហើយចៀសចេញទៅ; មានស្រីមក ប្រលោម. ស្រីផ្កាមាស ស្រីចាស់ក្រមុំ, ខ្ទើយ, ពួកញាតិ, ពួកស្តេច ពួកចោរ, ពួកអ្នកលេងមកប្រលោមថា «បពិត្រលោកដ៏ចំរើន! សូម លោកម្ចាស់និមន្តមក យើងខ្ញុំប្រគេនប្រាក់ មាស, ស្រែ, ចំការ, គោឈ្មោល,គោញី,ខ្ញុំប្រុស, ខ្ញុំស្រី, កូនស្រីដើម្បីជាភរិយា. នាំយកស្រី ដទៃមកឲ្យជាភរិយាលោកម្ចាស់,ឬបានឃើញកំណប់ទ្រព្យឥតមានម្ចាស់; ភិក្ខុនោះត្រូវតាំងចិត្តថា «ចិត្តជាធម្មជាតតែងប្រែប្រួលរហ័ស ក្រែងមាន សេចក្តីអន្តរាយដល់ព្រហ្មចរិយធម៌ របស់អាត្មាអញ » ដូច្នេះហើយត្រូវ ចៀសចេញទៅបាន, ឬបានឃើញភិក្ខុ ភិក្ខុនីច្រើនរូបកំពុងព្យាយាម ដើម្បីបំបែកសង្ឃ, បានឮដំណឹងថាភិក្ខុច្រើនរូបព្យាយាមបំបែកសង្ឃ ភិក្ខុនោះក៏តាំងចិត្តថា "អញនឹងគេចចេញពីទីនេះ អញនឹងទៅកាន់អាវាស ឯណោះ ដើម្បីនឹងនិយាយសម្រុះសម្រួលមិនឲ្យភិក្ខុជាមិត្តត្តី មិនមែនជា មិត្តត្តិ បំបែកសង្ឃ, ភិក្ខុទាំងនោះមុខជានឹងស្តាប់តាមបង្គាប់របស់អញ មិនខាន» គិតដូច្នេះហើយក៏ចៀសចេញទៅ; ពួកភិក្ខុទាំងនេះឯង

បើធ្វើឲ្យកន្លងសត្តាហៈទៅវស្សាដាច់ តែអាបត្តិមិនមាន ។

១៤៧–ប្រ. សាមណេរ វរេរសោ នឹងសាមណេរបុណ្ណកសោ បបួលគ្នាចេញពីវត្តគេនាល័យ ទៅរៀនព្រះបរិយត្តិធម៌នៅវត្តនាគវង្ស; ដល់ពេលចូលវស្សាបាន១០ថ្ងៃ សាមណេរបុណ្ណកសោក៏កើតរោគស្អឹក, សាមណេរវរេរសោក៏ចាំមើលថែទាំរកថ្នាំប្រកបណាស់ដែរ តែរោគនោះមិនបានសះស្បើយ រឹងរឹតតែធ្ងន់លើសដើម, វរេរសោក៏លើកសត្តាហៈនាំបុណ្ណកសោត្រឡប់មកគេនាលយាកមវិញ, មកដល់ហើយរវល់តែទំនុកបម្រុងថ្នាំឲ្យបុណ្ណកសោ សត្តាហៈនុះក៏ហួសទៅត្រឡប់វិញមិនទាន់; បើយ៉ាងហ្នឹងតើសាមណេរទាំងពីររូបនោះដាច់វស្សាឬទេ? ត្រូវទណ្ឌកម្មដែរឬ? បើភិក្ខុវិញតើយ៉ាងដូចម្តេច?

១៤៧–វិ. វស្សារបស់សាមណេរទាំងពីររូបនុះឈ្មោះថាដាច់ស្រឡះហើយ, តែទណ្ឌកម្មមិនត្រូវ; បើភិក្ខុវិញក៏ដូច្នោះ, វស្សាដាច់ តែមិនត្រូវអាបត្តិ ។

១៤៨–ប្រ. រាជការបានបង្គាប់ថា ឲ្យលោកនេវាសិកាចារ្យវត្តកញ្ញារង្សីនិមន្តមកដើម្បីធ្វើបុណ្យបញ្ចុះចេតិយក្នុងពេលវស្សា, លោកក៏បានលើកសត្តាហៈមកតាមបង្គាប់, លុះមកដល់បានចាត់ចែងក្នុងការបុណ្យនោះទៅ សត្តាហៈក៏ហួសព្រោះត្រឡប់ទៅវិញមិនទាន់, លោកនេវាសិកាចារ្យនោះដាច់វស្សាឬទេ? ត្រូវអាបត្តិដែរឬ?

១៤៨–វិ. វស្សារបស់លោកនោះសិក្ខាចារ្យនោះដាច់ហើយ, តែអាបត្តិមិនត្រូវ ។

១៤៩– ប្រ. ហេតុនៃការដាច់វស្សាតែមិនត្រូវអាបត្តិមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

១៤៩– វិ. ហេតុនៃការដាច់វស្សាតែមិនមានអាបត្តិមាន ៤ យ៉ាង គឺសង្ឃបែកគ្នា ១, ភិក្ខុទាំងឡាយប្រាថ្នាបំបែកសង្ឃ ១, មានអន្តរាយដល់ជីវិត ១, មានអន្តរាយដល់ព្រហ្មចរិយៈ ១ ។

១៥០– ប្រ. វិធីលើកសត្តាហៈនោះត្រូវលើកដូចម្តេច? មានបាលីថាដែរឬគ្មានទេ? ចូរស្រូតមកមើល ។

១៥០– វិ. វិធីលើកសត្តាហៈនោះដូច្នេះ ភិក្ខុឬសាមណេរមុនដែលនឹងចេញទៅស្រុកឆ្ងាយ ក្នុងវស្សានោះ ត្រូវតាំងចិត្តថា «អញនឹងត្រឡប់មកក្នុងចន្លោះនៃថ្ងៃទី ៧» ដូច្នេះ ហើយចេញទៅមិនបាច់ស្រូតបាលីក៏បាន, បាលីមានដែរបើចង់ស្រូតឲ្យប្រាកដក៏រឹតតែស្រួល, តែគួរស្រូតក្នុងទីចំពោះមុខភិក្ខុ, គណៈ ឬសង្ឃ, បើពុំនោះទេទៅស្រូតចំពោះព្រះភក្ត្រព្រះពុទ្ធរូបក៏បានហើយ ត្រូវថាបីដងដូច្នេះ ៖

សចេ មេ អន្តរាយោ នត្ថិ, សត្តាហព្ភន្តរេ អហំ បុន និវត្តិស្សាមិ ទុតិយម្បិ តតិយម្បិ បើសេចក្តីអន្តរាយរបស់ខ្ញុំមិនមានទេ ខ្ញុំនឹងត្រឡប់មកវិញក្នុងចន្លោះនៃថ្ងៃទី ៧, អស់វារៈ ២ ៣ ដងផង» ។

១៩១–ប្រ. ក្នុងនាសនង្គទាំង១០នោះ, នាសនង្គប៉ុន្មានដែល សាមណេរត្រូវហើយសឹកចេញ បួសវិញបាន, នាសនង្គប៉ុន្មានដែល ត្រូវហើយត្រូវសឹកចេញបួសវិញមិនបាន ?

១៩១–វិ. ក្នុងនាសនង្គទាំង១០នោះ, តាំងពីនាសនង្គទី១រហូតដល់ទី៩នេះត្រូវហើយ, ត្រូវសឹកចេញតែបួសវិញបាន, នាសនង្គទី១០ មួយនេះឯង តែត្រូវហើយត្រូវតែសឹកចេញ បួសវិញពុំបានជាដាច់ខាត ។

១៩២–ប្រ. ភិក្ខុនីនោះតើគឺស្រីដូចម្តេច? មានវត្តប្រតិបត្តិយ៉ាងណា? មានសិក្ខាបទប៉ុន្មាន? ចូរអធិប្បាយឲ្យល្អមស្តាប់ ។

១៩២–វិ. ស្រីបព្វជិតដែលបានឧបសម្បទាអំពីសំណាក់សង្ឃទាំងពីរពួក គឺភិក្ខុសង្ឃ និងភិក្ខុនីសង្ឃ ហៅថា «ភិក្ខុនី» ។ នេះមានកិច្ចវត្តប្រតិបត្តិនិងសង្ឃកម្មទាំងពួង ប្រហែលគ្នានឹងភិក្ខុក៏មាន ផ្សេងច្រើនជាងភិក្ខុតឹងជាងភិក្ខុទៅទៀតក៏មាន បើរាប់សិក្ខាបទរបស់ភិក្ខុនីដែលមានក្នុងបាតិមោក្ខរួមទាំងអធិករណសមថៈ ៧ ផង មាន ៣១១ សិក្ខាបទ គឺបារាជិក ៨, សង្ឃាទិសេស ១៧, និស្សគ្គិយបាចិត្តិយៈ៣០, សុទ្ធិកបាចិត្តិយៈ១៦៦, បាដិទេសនីយៈ ៨, សេខិយវត្ត ៧៥, អធិករណសមថៈ ៧ រួមត្រូវជា ៣១១ សិក្ខាបទ ។

១៩៣–ប្រ. ក្នុងអព្រហ្មចរិយសិក្ខាបទ ព្រះបរមគ្រូទ្រង់ហាមមិនឲ្យសេពក្នុងទ្វារមគ្គទាំង៣ រួចទៅហើយ, ចុះហេតុអ្វីបានជាហាមមិន

ឲ្យបើកទ្វារបត្តភិក្ខុនីទៀត? ទ្វារនោះតើ ផ្សេងគ្នា ឬ ដូចគ្នាទេ ?

១៩៣– វិ. ទ្វារនោះមិនផ្សេងគ្នាទេ ដូចគ្នា, ប៉ុន្តែបានជាទ្រង់ហាមថែមទៀត នឹងឲ្យមានទោសធ្ងន់ជាងនោះ ព្រោះភិក្ខុនីមិនមែនដូចស្រីធម្មតា ជាស្រីបព្វជិតមានគុណសម្បត្តិដ៏ខ្ពស់នៅក្នុងខ្លួន; ធម្មតាមនុស្សដែលមានគុណសម្បត្តិច្រើន , ជនណាមួយប្រព្រឹត្តកន្លងល្មើសលើ ប្រមាថមើលងាយមនុស្សនោះ, ជននោះតែងមានទោសធ្ងន់ជាដរាប, ទាំងច្បាប់រាជការផែនដីក៏ដូច្នោះ

អាវរណវគ្គទី ៧ ចប់

---

# បកិណ្ណកវគ្គទី ៨

១៩៤– ប្ញ. អនាគារិយវិន័យមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ក្នុងយ៉ាងនិមួយៗ មានប៉ុន្មានយ៉ាងទៀតទៅ? ចូររាប់ហើយអធិប្បាយតែសង្ខេបមកបានហើយ ។

១៩៤– វិ. អនាគារិយវិន័យមាន ៤ យ៉ាង គឺ សំវរវិន័យ ១ បហានវិន័យ ១, សមថវិន័យ ១, បញ្ញត្តិវិន័យ ១ ។

សំវរវិន័យមាន ៥ យ៉ាងគឺ សីលសំវរ សេចក្ដីសង្រួមក្នុងបាតិមោក្ខ ១, សតិសំវរ សេចក្ដីសង្រួមក្នុងឥន្ទ្រិយទាំងប្រាំមួយ ១, ញាណសំវរ សេចក្ដីបិទបាំងតណ្ហាដោយប្រាជ្ញា ១, ខន្តិសំវរ សេចក្ដី

អត់ធន់នឹងក្តៅត្រជាក់ ១, វីរិយសំវរ ការប្រឹងប្រែងមិនឲ្យវិតក្កៈបួលបៀតបៀន ១ ។

បហានវិន័យ មាន ៥ យ៉ាងគឺ តទង្គប្បហាន បានដល់ការលះកិលេសជាខណៈៗ ១, វិក្ខម្ភនប្បហាន បានដល់ការឈ្មុចឈ្មីនីវរណៈឲ្យស្ងប់រម្ងាប់ ១, សមុច្ឆេទប្បហាន បានដល់អរិយមគ្គដែលលះកិលេស ១, បដិប្បស្សទ្ធិប្បហាន បានដល់អរិយផលដែលលះកិលេស ១, និស្សរណប្បហាន បានដល់ព្រះនិព្វានដែលលះកិលេស ១ ។ សមថវិន័យ បានដល់សមថកម្មដ្ឋានទាំង ៤០ ។ បញ្ញត្តិវិន័យ បានដល់បញ្ញត្តិទាំង ៩ យ៉ាង គឺ បញ្ញត្តិ ១, អនុប្បញ្ញត្តិ ១, អនុប្បន្នប្បញ្ញត្តិ ១, សព្វត្ថប្បញ្ញត្តិ ១, បទេសប្បញ្ញត្តិ ១, សាធារណប្បញ្ញត្តិ ១, អសាធារណប្បញ្ញត្តិ ១, ឯកតោបញ្ញត្តិ ១, ឧភតោបញ្ញត្តិ ១, ។

១៥៥– បុ. នាសនង្គទី ១០ បើសាមណេរប្រព្រឹត្តកន្លងហើយ ព្រះឧបជ្ឈាយ៍ឬអាចារ្យត្រូវផ្សឹកចេញ បើទុកជាប្រាថ្នាបួសវិញ ក៏មិនត្រូវបំបួសដែរ នុះមិនមានសំស័យទេ ចាំយ៉ាងហ្នឹងទៅចុះ ៗ តែនឹកឆ្ងល់ថា ត្រែងនៅមាននាសនង្គទីប៉ុន្មានទៀតដែរ, ដែលសាមណេរត្រូវហើយត្រូវតែផ្សឹកចេញបួសវិញមិនបានដូចជានាសនង្គទី ១០ ដែរនោះ ៗ បើគ្មានក៏ហើយទៅមិនបាច់ឆ្លើយឲ្យវែងទេ, បើមានតើនាសនង្គ

ទីប៉ុន្មានខ្លះ? រាប់បញ្ចូលក្នុងទោសអ្វី? ចូរអធិប្បាយ ។

១៥៥– វិ. មាន, គឺនាសនង្គទី ១ នឹងទី ២ ។ នាសនង្គទី១ សាមណេរសម្លាប់សត្វតិរច្ឆានយ៉ាងតូច មានស្រមោចជាទីបំផុត យ៉ាងធំត្រឹមដំរី, សម្លាប់មនុស្ស នឹងអមនុស្ស មានព្រះឥន្ទព្រះព្រហ្មជាដើម នេះសុទ្ធតែត្រូវនាសនង្គទាំងអស់ តែបើត្រូវការចង់បួសវិញក៏បាន មិនមានហាម; បើសម្លាប់ជនបីពួក គឺមាតុឃាត សម្លាប់មាតា ១, បិតុឃាត សម្លាប់បិតា ១, អរហន្តឃាត សម្លាប់ព្រះអរហន្ត ១; សម្លាប់ជនទាំង ៣ ពួកនេះ ព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវផ្សឹកចេញ ហើយមិនត្រូវបំបួសវិញទេ ទោសសម្លាប់ជន ៣ ពួកនេះ រាប់បញ្ចូលក្នុងអនន្តរិយកម្ម ។ សាមណេរលួចទ្រព្យគេយ៉ាងតិចមានម្ជុល១ ឬពេស១ សរសៃថ្នាំ ១ បារី ឬស្លឹកសង្កែ ១ សន្លឹកជាទីបំផុត, យ៉ាងច្រើនត្រឹមនគរ ១ ទាំងមូល នេះសុទ្ធតែត្រូវនាសនង្គទាំងអស់, តែបើចង់បួសវិញក៏មិនបានហាម. តែបើលួចគេដែលហៅថា ថេយ្យសំវាសកោ មនុស្សលួចសំវាស គឺមិនមែនជាភិក្ខុ ហើយក្លែងខ្លួនជាភិក្ខុ ធ្វើសង្ឃកម្មជាមួយនឹងភិក្ខុបរិស័ទ ក្លែងប្រាប់លំដាប់វស្សា, ត្រេកអរនឹងការក្រាបសំពះថ្វាយបង្គំពីសំណាក់ភិក្ខុមែនទែនជាដើមនេះមានទោសជាទម្ងន់ ព្រះឧបជ្ឈាយ៍ ឬអាចារ្យត្រូវផ្សឹកចេញជាប្រញាប់, បើចង់បួសវិញក៏មិនត្រូវបំបួស, មនុស្សនោះទុកជាអភព្វបុគ្គល បួសជាភិក្ខុឬសាមណេរមិនឡើងឡើយ។

បើមានឹងច្បាប់កេណាចក្រវិញទុកជាក្បត់ពជការផែនដី ។

១៥៦– ប្រ. សាមណេរវឹងវីងគេទៅលួចដុតផ្ទះគេចោល ត្រូវទោសអ្វី ?

១៥៦–វិ. សាមណេរវឹងវីងគេទៅលួចដុតផ្ទះគេចោលត្រូវទណ្ឌកម្ម ។

១៥៧ – ប្រ. សាមណេរលួចទ្រព្យគេកប់ទុក, ម្ចាស់ទ្រព្យស្លាប់ចោលទៅ, សាមណេរយកទ្រព្យនោះមកលាក់ទុកជារបស់ខ្លួន តើត្រូវទោសអ្វី? ព្រោះហេតុអ្វី?

១៥៧– វិ. ត្រូវនាសនង្គ, ព្រោះទុកដូចជាលួចកំណប់ស្តេចផែនដី ។

១៥៨– ប្រ. សាមណេរមានទោសចិត្ត ក៏យសត្វស្លាប់ស្រាប់ ត្រូវទោសអ្វី ?

១៥៨–វិ. ត្រូវទណ្ឌកម្ម ។

១៥៩– ប្រ. សាមណេរទិញទំនិញចិន ដឹងថាចិនថែមលុយឲ្យលើសមកហើយក៏យកមក ត្រូវទោសអ្វី?

១៥៩– វិ. ត្រូវនាសនង្គ ។

១៦០–ប្រ. សាមណេរដាច់សីលដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ?

១៦០–វិ. សាមណេរដាច់សីលដោយហេតុ២យ៉ាងគឺ[illegible]ណៈ១, ប្រព្រឹត្តកន្លងសិក្ខាបទ១ ។

១៦១–ឬ. សីលមានលក្ខណៈដូចម្តេច? លក្ខណៈនោះគេមានប៉ុន្មានយ៉ាង ?

១៦១–វិ. សីលមានកិរិយាទ្រទ្រង់ ឬដំកល់ទុកនូវកម្មមានកាយកម្មជាដើមដោយប្រពៃ គឺពាំងមិនឲ្យធ្វើនូវអំពើទុច្ចរិតនិងរក្សាថែទាំទុកនូវកុសលធម៌ទាំងពួង មិនឲ្យវិនាសទៅជាលក្ខណៈ សីលនេះទោះបីជាប់ចុះផ្សាយដោយប្រការច្រើនក៏ដោយ ក៏គង់តែមានកិរិយាទ្រទ្រង់ជាលក្ខណៈតែម្យ៉ាង ។

១៦២–ឬ. សីលដែលនឹងស្ថិតនៅនោះ អាស្រ័យដោយហេតុប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូររាប់ហើយអធិប្បាយ ។

១៦២–វិ. សីលដែលស្ថិតនៅនោះអាស្រ័យដោយធម៌ ២ យ៉ាង គឺៈ ហិរិ១, ឱត្តប្បៈ១, ហិរិបានដល់សេចក្តីខ្មាសបាប, ឱត្តប្បៈបានដល់សេចក្តីក្តៅក្រហាយ ឬសេចក្តីតក់ស្លុតនឹងបាប, កាលបើធម៌ទាំងពីរ ២ ប្រការនេះ តាំងនៅក្នុងខ្លួនសត្វនោះហើយ សីលរមែងស្ថិតនៅជាធម្មតា ។

១៦៣–ឬ. ប្រព្រឹត្តតាមពុទ្ធានុញ្ញាតហៅថាសីលអ្វី តាមពុទ្ធប្បញ្ញត្តិហៅថាសីលអ្វី ?

១៦៣–វិ. ប្រព្រឹត្តតាមពុទ្ធានុញ្ញាត ហៅថា ចារិតសីល ប្រព្រឹត្ត[illegible]ប្បញ្ញត្តិហៅថា វារិតសីល ។

១៦៤-ប្រ. ដូចម្ដេចហៅថាទោស? ទោសនោះមានប៉ុន្មានយ៉ាង គឺអ្វី? ចូរអធិប្បាយ ។

១៦៤-វិ. សេចក្ដីប្រព្រឹត្តល្មើសនឹងវិន័យបញ្ញត្តិ ប្រព្រឹត្តកន្លងនូវសិក្ខាបទតូចធំណាមួយ ហៅថាទោស; មាន២យ៉ាងគឺ លោកវជ្ជ ទោសសម្រាប់លោក១ បណ្ណត្តិវជ្ជ ទោសព្រោះសេចក្ដីបញ្ញត្តិ ១ ។

១៦៥-ប្រ. ហេតុជាទីឲ្យកើតទោសមានប៉ុន្មានយ៉ាង? គឺអ្វីខ្លះ? ចូររកឲ្យសព្វគ្រប់មកមើល ។

១៦៥-វិ. ហេតុជាទីឲ្យកើតទោសបើនិយាយតាមវិន័យមាន ៦ យ៉ាង គឺ អស្សទ្ធា មិនជឿវិន័យបញ្ញត្តិ ១, អក្ខន្តិ មិនចេះអត់ធន់នឹងពាក្យប្រៀនប្រដៅជាដើម ១, អញ្ញាណ មិនស្គាល់សេចក្ដីបញ្ញត្តិ ១, អជ្ឈស្សតិ ភ្លេចស្មារតី ១, កុសីត ខ្ជិលច្រអូស ១, បើនិយាយតាមព្រះសូត្រវិញក៏មាន ៦ យ៉ាងដែរ គឺ អាលស្យ សេចក្ដីខ្ជិលច្រអូស ១, បមាទ សេចក្ដីធ្វេសប្រហែស ១, អនុដ្ឋាន សេចក្ដីទ្រមក់មិនក្រវិនក្រើន ១, អសញ្ញម មិនសង្រួមឥន្ទ្រិយ ១, និទ្ទា និទ្រ ប្រែទ គឺល្មោភដេក ១, តន្ទិ សេចក្ដីប្រថុយប្រថានការងដល់ហេតុ ៦ យ៉ាង គឺ អតិសីតំ ត្រជាក់ពេក, អតិឧណ្ហំ ក្ដៅពេក, អតិបាតោ ព្រឹកពេក, អតិសាយំ ល្ងាចពេក, អតិច្ឆាតោ ឃ្លា[illegible]ពេក, អតិបិបាសិតោ ស្រេកទឹកពេក ។

១៦៦ — ប្រ. អ្វីហៅថាសិក្ខាបទ? ព្រោះហេតុអ្វី?

១៦៦ — វិ. មូលបញ្ញត្តិ គឺសេចក្ដីហាមដែលទ្រង់តាំងទុកជាដម្បូងនិងអនុបញ្ញត្តិ គឺសេចក្ដីហាមដែលទ្រង់តាំងបន្ថែមខាងក្រោយ រួមទាំងពីរយ៉ាងនេះហៅថាសិក្ខាបទ ព្រោះជាផ្លូវជាគន្លងលំកាន់ច្បាប់ដែលអ្នកបួសត្រូវសិក្សា ។

១៦៧ — ប្រ. សីលនិងសិក្ខាបទផ្សេងគ្នា ឬដូចគ្នា? ចូរអធិប្បាយដោយសេចក្ដីសព្វគ្រប់ ។

១៦៧ — វិ. ផ្សេងគ្នា, សីលបានដល់សេចក្ដីសង្រួមកាយវាចាចិត្ត ឲ្យរាបសាដោយប្រពៃ, ឯសិក្ខាបទបានដល់មូលបញ្ញត្តិ គឺសេចក្ដីហាមប្រាមដែលទ្រង់តាំងទុកជាដម្បូងនិងអនុបញ្ញត្តិ គឺសេចក្ដីហាមប្រាមដែលទ្រង់តាំងបន្ថែមខាងក្រោយ ។

បកិណ្ណកវគ្គទី ៨ ចប់

សួរឆ្លើយក្នុងសាមណេរវិន័យ ៣០ ចប់តែប៉ុណ្ណេះ